ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ផែនការប្រើប្រាស់ដី នៅក្នុងឃុំ ត្បែង
ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ
ឆ្នាំ២០១៧ ដល់ ២០៣២

រៀបចំដោយ : ក្រុមហ៊ុនផ្តល់សេវាកម្មSBK R&D

សម្របសម្រួលដោយ : ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីស្រុកកំពង់ស្វាយ

គាំទ្របច្ចេកទេសដោយ : អង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ(NIO-MLMUPC) និងថ្នាក់ខេត្ត(PIO)

ឧបត្ថម្ភថវិកាដោយ : រាជរដ្ឋាភិបាលកម្ពុជា (RGC) , ADB_Loan , GAFSP_Grant និងSCF_ADB

មាតិកា

អារម្ភកថា VII
សេចក្តីផ្តើម 1
ជំពូក ១៖ ព័ត៌មានស្តីពីស្ថានភាពឃុំត្បែង 3
១.១.ស្ថានភាពឃុំ 3
១.១.១.ទីតាំងរដ្ឋបាលឃុំ 3
១.១.២.ប្រជាសាស្ត្រ 5
ក.ចំនួនប្រជាជន 5
ខ.អត្រាកំណើន ដង់ស៊ីតេ និងរបាយប្រជាជន 7
គ.ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់ 8
ឃ.របររកទទួលទាន 8
ង.ចំណូលស្រុក និងចំណាកស្រុក 10
១.១.៣.ស្ថានភាពសេដ្ឋកិច្ច 11
ក.ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ 11
ខ.កម្រិតជីវភាពរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ 12
គ.ស្ថានភាពបំណុលសរុប និងអត្រាការប្រាក់ 13
ឃ.ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬក្រោមរូបភាពផ្សេងៗ 14
ង.ចំណូលពីប្រភពផ្សេងៗ 14
១.១.៤.ស្ថានភាពសិក្សាធិការ 14
ក.ស្ថានភាពអប់រំ 14
ខ.ស្ថានភាពអក្ខរកម្ម 15
គ.ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត 16
១.១.៥.ស្ថានភាពសុខាភិបាល 17
១.១.៦.ស្ថានភាពយេនឌ័រ 19
១.២.ស្ថានភាពភូមិសាស្ត្រ 21
១.២.១.ទីតាំងភូមិសាស្ត្រ 21
១.២.២.អាកាសធាតុ (ពិពណ៌នាតាមរដូវកាល) 27
១.២.៣.ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន 28
១.២.៤.បរិក្ខាសាធារណៈ 30
ក.ស្ថានភាពប្រើប្រាស់អគ្គិសនី 30

ខ.ប្រព័ន្ធទឹកស្អាត 30
១.៣.ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន 31
១.៣.១.ស្ថានភាពការកាន់កាប់ និងគ្រប់គ្រង 31
ក.ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ 33
ខ.ដីកសិកម្ម 35
ខ.១.ដីស្រែវស្សា 35
ខ.២.ដីស្រែប្រាំង និងស្រែវស្សា 36
ខ.៣.ដីចម្ការ 37
គ.ដីព្រៃ/គម្របព្រៃឈើ 38
ឃ.ផ្ទៃទឹក និងខ្សែទឹក 38
១.៣.២.ផលិតកម្ម កសិកម្ម 40
ក.ផលិតកម្មដំណាំស្បៀង 40
ខ.ផលិតកម្មដំណាំរួមផ្សំ 41
គ.ផលិតកម្មខ្វស្សាហកម្ម 41
១.៣.៣.ធនធានធម្មជាតិ 42
ក.ធនធានព្រៃឈើ 42
ខ.ធនធានជលផល 42
១.៣.៤.ធនធានរ៉ែ 43
១.៤.ទីផ្សារ និងខ្សែសង្វាក់ផលិតផល 43
១.៤.១.ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ 43
១.៤.២.ខ្សែសង្វាក់ និងចរាចរផលិតផល 43
១.៤.៣.ឧបសគ្គ និងឱកាស 46
ជំពូក ២៖ ការវិភាគ តម្រូវការ សក្តានុពល និងឧបសគ្គសម្រាប់អនាគត 47
២.១.តម្រូវការសម្រាប់អនាគត 47
២.១.១.ផែនការអភិវឌ្ឍ ឃុំ 47
ក.ផែនការអភិវឌ្ឍឃុំ៥ឆ្នាំ(២០១៨-២០២២) 47
ខ.គម្រោងអភិវឌ្ឍផ្សេងៗទៀតដែលបានអនុម័តរួច 51
២.១.២.ចំណោលប្រជាសាស្ត្រគិតទៅដល់ឆ្នាំ២០៣២ 51
២.១.៣.តម្រូវការដីជាមូលដ្ឋាន 53

ក.ដីលំនៅឋាន 53
ខ.ដីកសិកម្ម 54
គ.ដីព្រៃឈើ 54
ឃ.សម្រាប់ធនធានទឹក 55
ង.ហេដ្ឋារចនាសម្ព័ន្ធសង្គម និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត 55
ង.១.វិស័យអប់រំ 55
ង.២.សម្រាប់វិស័យសុខាភិបាល 57
ង.៣.អគ្គិសនី 57
ង.៤.ទីលានចាក់សំរាម 57
ង.៥.ដីកប់ខ្មោច 58
ង.៦.ស្រះ និងអណ្តូងទឹក 58
២.២.តំបន់សេដ្ឋកិច្ច 59
២.៣.ការប្រឈម 60
២.៣.១.ការប្រឈមដោយធម្មជាតិ 60
ក.កំណើនប្រជាជន 60
ខ.គ្រោះធម្មជាតិ ការរេចរឹលនៃធម្មជាតិ 60
២.៣.២.ការប្រឈមដោយ ការអភិវឌ្ឍដែលពុំមាននិរន្តរភាព 60
២.៤.ឱកាស 61
២.៤.១.ដោយអំណោយផលពីធម្មជាតិ 61
២.៤.៣.ដោយគម្រោងវិនិយោគ 62
២.៥.បញ្ហា មូលហេតុ និងដំណោះស្រាយ 62
ជំពូក ៣៖ ផែនការប្រើប្រាស់ដីសម្រាប់ពេលអនាគតឆ្នាំ២០១៧-២០៣២ 66
៣.១.តម្រូវការ ស្ថានភាព និងសក្តានុពលដីជាក់ស្តែង 66
៣.១.១.តម្រូវការដីទៅតាមប្រភេទ 66
៣.១.២.ស្ថានភាពនៃដីធ្លី និងសក្តានុពល 66
៣.២.ការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់ 67
៣.២.១.ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ 67
៣.២.២.ផែនទីប្រើប្រាស់ដីអនាគត 70
៣.២.៣.សេចក្តីអត្ថាធិប្បាយ 72
ក.ដីលំដីលំនៅឋាន ភូមិ 72

ខ.ដីស្រែវស្សា 73
គ.ដីស្រែប្រាំងនិងស្រែវស្សា 74
ឃ.ដីចម្ការ 74
ង.ព្រៃល្បោះ 75
ច.ព្រៃដាំឡើងវិញ 75
ឆ.ស្ទឹង 75
ជ.ស្រះ 76
៣.៣.ដំណោះស្រាយផ្សេងៗ ក្នុងករណីខ្វះខាតដីធ្លី 76
៣.៤.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព 76
៣.៤.១.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព 76
ក.ការគ្រប់គ្រងប្រព័ន្ធកសិកម្ម 77
ខ.ការគ្រប់គ្រងព្រៃឈើ ជលផល និង ធនធានសំខាន់ៗផ្សេងៗទៀត 78
៣.៤.២.គម្រោងគាំទ្រចាំបាច់ សម្រាប់គាំទ្រនិរន្តរភាព 79
៣.៥.សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់២០៣២) 80

បញ្ជីតារាង

តារាង 1៖ ស្ថានភាពទូទៅនៃឃុំ 3
តារាង 2៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្តាភូមិ 6
តារាង 3៖ ស្ថិតិប្រជាជនតាមក្រុមអាយុ 7
តារាង 4៖ ស្ថិតិប្រជាជនតាមបណ្តាឆ្នាំ និងការគណនាអត្រាកំណើនមធ្យម 8
តារាង 5៖ តារាងមុខរបរ 8
តារាង 6៖ តារាងមុខរបរបន្ទាប់បន្សំ 10
តារាង 7៖ ស្ថិតិប្រជាជនផ្លាស់ប្តូរទីលំនៅក្នុងឆ្នាំ២០១៦-២០១៧ 11
តារាង 8៖ ស្ថិតិប្រជាជនចំណាកស្រុក 11
តារាង 9៖ តារាងកម្រិតជីវភាពរបស់ប្រជាជន 12
តារាង 10៖ ស្ថិតិសាលារៀន ស្ថានភាពអប់រំ និងសិក្សាធិការក្នុងឃុំឆ្នាំ២០១៧ 15
តារាង 11៖ ស្ថិតិអ្នកមិនចេះអក្សរ 16
តារាង 12៖ ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត 16
តារាង 13៖ សុខភាពមាតានិងទារក 17
តារាង 14៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព 18
តារាង 15៖ ការវិភាគលើតួនាទីយេនឌ័រ 20
តារាង 16៖ ដ្យាក្រាមពំនុះកាត់ទទឹង ឃុំត្បែង ស្រុកកំពង់ស្វាយ 23
តារាង 17៖ ប្រព័ន្ធធារាសាស្ត្រ 26

តារាង 18៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ 28
តារាង 19៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន 29
តារាង 20៖ ស្ថិតិអ្នកប្រើប្រាស់អគ្គិសនី 30
តារាង 21៖ ស្ថិតិអ្នកប្រើប្រាស់ការប្រើប្រាស់ទឹក 30
តារាង 22៖ តារាងរាយលម្អិតតាមប្រភេទនៃការប្រើប្រាស់ដីបច្ចុប្បន្ន 33
តារាង 23៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស 40
តារាង 24៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស 41
តារាង 25៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស 41
តារាង 26៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស 42
តារាង 27៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស 42
តារាង 28៖ ស្ថិតិផលិតផលស្រូវ និងតម្លៃ 43
តារាង 29៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស 46
តារាង 30៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍ និងជម្រើសនៃការប្រាស់ដីធ្លីអនាគត 47
តារាង 31៖ ចំណោលប្រជាសាស្ត្រនៃចំនួនគ្រួសារ និងប្រជាជនសរុប (០៥ឆ្នាំ) 52
តារាង 32៖ ចំណោលប្រជាសាស្ត្រតាមក្រុមអាយុ (០៥ឆ្នាំ) 52
តារាង 33៖ តម្រូវការដីសម្រាប់លំនៅឋានក្នុងឆ្នាំ២០៣២ 53
តារាង 34៖ តម្រូវការដីសម្រាប់កសិកម្មក្នុងឆ្នាំ២០៣២ 54
តារាង 35៖ កំណើនកុមារ តម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១៨ ដល់ឆ្នាំ ២០៣២ 56
តារាង 36៖ បញ្ហាប្រឈម និងសក្តានុពល(ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ) 62
តារាង 37៖តារាងប្រើប្រាស់ដីនាពេលអនាគត 68
តារាង 38៖តារាងផែនការផ្អែកហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត 69
តារាង 39៖ តារាងផែនការផ្អែកសេវាកម្មនាពេលអនាគត 69

បញ្ជីដ្យាក្រាម

ដ្យាក្រាម 1៖ ស្ថិតិប្រជាជនឆ្នាំ ២០១៧ 6
ដ្យាក្រាម 2៖ ចម្ងាយជាមធ្យម ពីភូមិទៅមណ្ឌលសុខភាព 19
ដ្យាក្រាម 3៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ 28

បញ្ជីផែនទី

ផែនទី 1៖ បង្ហាញទីតាំងឃុំត្បែង 4
ផែនទី 2៖ ព្រំប្រទល់រដ្ឋបាលឃុំត្បែង 5
ផែនទី 3៖ ផែនទីរយៈកម្ពស់ដីឃុំត្បែង 22
ផែនទី 4៖ ប្រព័ន្ធក្សេត្រ-បរិស្ថាន ឃុំត្បែង 22
ផែនទី 5៖ ប្រព័ន្ធធារាសាស្ត្រឃុំត្បែង 27
ផែនទី 6៖ ផែនទីហេដ្ឋារចនាសម្ព័នឃុំត្បែង 29
ផែនទី 7៖ ផែនទីប្រើប្រាស់ដីសាមញ្ញក្នុងឃុំត្បែង 31

ផែនទី 8៖ ផែនទីប្រើប្រាស់ដីលម្អិតក្នុងឃុំត្បែង 32
ផែនទី 9៖ គម្រោងវិនិយោគអាទិភាពឃុំត្បែង 51
ផែនទី 10៖ តំបន់រសើបឃុំត្បែង 59
ផែនទី 11៖ បញ្ហា មូលហេតុ និងដំណោះស្រាយ 65
ផែនទី 12៖ ផែនទីប្រើប្រាស់ដីអនាគត 71

បញ្ជីរូបភាព

រូបភាព 1៖ សាលារៀន 14
រូបភាព 2៖ មណ្ឌលសុខភាពព្រៃប្រស់ 18
រូបភាព 3៖ ប្រព័ន្ធធារាសាស្ត្រ 26
រូបភាព 4៖ ប្រព័ន្ធគមនាគមន៍ 29
រូបភាព 5៖ លំនៅឋានភូមិ 34
រូបភាព 6៖ ស្រូវវស្សា 36
រូបភាព 7៖ ដីស្រែប្រាំងនិងស្រែវស្សា 37
រូបភាព 8៖ ដីចម្ការ 38
រូបភាព 9៖ ព្រៃល្បោះ 38
រូបភាព 10៖ ស្ទឹងព្រៃប្រស់ 39
រូបភាព 11៖ ស្រះទឹក 39

អារម្ភកថា

ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ គឺ ជាឧបករណ៍មួយដ៏សំខាន់ក្នុងការជួយទៅដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ផ្ទាល់ ក៏ដូចជា ទៅដល់អ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបទៅដោយចីរភាព និងសមធម៌ ជាពិសេសការគ្រប់គ្រងនិងប្រើប្រាស់ដី ដែលជាកត្តាស្នូលនៃការអភិវឌ្ឍសេដ្ឋកិច្ច និងលើកស្ទួយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ដូច្នេះ ក្រោយពេលមានផែនការប្រើប្រាស់ដីនេះ អាជ្ញាធរគ្រប់ផ្នែកនៅថ្នាក់ក្រោមជាតិ ជាពិសេសអាជ្ញាធរដែនដី នឹងមានមូលដ្ឋានកាន់តែគ្រប់ជ្រុងជ្រោយនៅក្នុងការរៀបចំបញ្ចូលផែនការប្រើប្រាស់នៅក្នុងឃុំ/សង្កាត់នេះទៅក្នុងផែនការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចនៅថ្នាក់មូលដ្ឋាន ដោយធ្វើសមាហរណកម្មផែនការនៅថ្នាក់ស្រុក និងការអនុម័តនៅថ្នាក់រាជធានី/ខេត្ត តាមនីតិវិធីដូចដែលធ្លាប់អនុវត្តក្នុងការកសាងផែនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច កន្លងមក ដោយមានគ្រប់ភាគីពាក់ព័ន្ធចូលរួមធ្វើការសម្រេច។ ក្នុងទឹកចិត្តសោមនស្សរីករាយជាអនេក យើងខ្ញុំមានកិត្តិយសសូមបង្ហាញនូវរបាយការណ៍បច្ចេកទេសស្តីពីផែនការប្រើប្រាស់ដីនៅក្នុងឃុំត្បែង មានចក្ខុវិស័យរហូតទៅដល់ឆ្នាំ២០៣២ ដែលក្រុមការងារបានប្រឹងប្រែងសិក្សាស្រាវជ្រាវ និងរៀបចំឡើងអស់រយៈពេលជាងពីរឆ្នាំកន្លងមកនេះ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ធនាគារអភិវឌ្ឍអាស៊ី (ADB) និងកម្មវិធីកសិកម្ម និងសន្តិសុខស្បៀងពិភពលោក (GAFSP) ដែលបានជួយគាំទ្រឧបត្ថម្ភថវិកា ក្រុមហ៊ុនផ្តល់សេវាកម្មមកជួយសិក្សារៀបចំផែនការនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលបានជួយទទួលគ្រប់គ្រងគម្រោង និងគាំទ្របច្ចេកទេស រដ្ឋបាលខេត្តកំពង់ធំនិងរដ្ឋបាលស្រុកកំពង់ស្វាយ ដែលបានសម្របសម្រួលដល់កិច្ចដំណើរការរបស់គម្រោងនិងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមនៅក្នុងដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំត្បែងនេះ។ ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ផែនការប្រើប្រាស់ដីនៅក្នុងឃុំត្បែងនេះ នឹងចូលរួមចំណែកដល់ការអភិវឌ្ឍឃុំប្រកបទៅដោយចីរភាព ថែមទាំងត្រូវបានប្រើប្រាស់ដោយមានការចូលរួមនិងគាំទ្រយ៉ាងពេញទំហឹងពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់៕

ថ្ងៃ [illegible]កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅឃុំត្បែង ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០២០

ប្រធានក្រុមប្រឹក្សាឃុំ និងជា

មេឃុំត្បែង

កែ ផៃ

សេចក្តីផ្តើម

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ដោយការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋនិងការគោរពសិទ្ធិមនុស្សនៅក្រោមដំបូលរដ្ឋធម្មនុញ្ញនិងច្បាប់ រាជរដ្ឋាភិបាល ដែលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ ក្នុងគោលដៅបង្កើននិងកែលម្អការផ្តល់គុណភាពសេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

ផ្អែកតាមយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលកម្ពុជា នៅក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដាក់ចេញនូវគោលនយោបាយជាតិ ស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា សំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍតាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្រ្តរៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាន ឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្រ្តនីមួយៗ។

ឃុំត្បែង ជាឃុំមួយក្នុងចំណោមឃុំចំនួន១១ ស្ថិតក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ មានតំបន់លំនៅឋានមួយផ្នែក និងមួយផ្នែកទៀតជាតំបន់កសិកម្ម ដែលមានផ្ទៃដីសរុបចំនួន ១៥ ៩៣៨,០៦ ហិកតា ដោយព្រំប្រទល់ខាងជើង ជាប់នឹង ឃុំដំរីស្លាប់ និង ឃុំនីពេជ ខាងត្បូង ជាប់នឹង ឃុំកំពង់គោ ខាងកើត ជាប់នឹងឃុំត្រពាំងឫស្សី និងខាងលិច ជាប់នឹងឃុំសាន់គ មានប្រជាជនសរុប ១ ៥៦៤០ នាក់ នៅក្នុងនោះស្រ្តី ៨ ៧១០ នាក់ ហើយប្រជាពលរដ្ឋប្រហែល ៨៥,៤ ភាគរយ ជាកសិករ។ ឃុំត្បែង មានទំហំផ្ទៃដីស្រែសរុប ១០ ៥១៨,១៣ ហិកតា គឺជាផ្ទៃដីដែលមានទំហំធំទូលាយមានវិសាលភាពស្រួបអស់ ៧៤ ភាគរយ នៃផ្ទៃដីសរុបរបស់ឃុំ ដែលជាបង្អែកដ៏មានសក្តានុពលតែមួយគត់សម្រាប់ការអភិវឌ្ឍន៍ឃុំត្បែង ប្រកបដោយចីរភាព។

ក្នុងគោលដៅធានាការគ្រប់គ្រង និងអភិវឌ្ឍឃុំត្បែង ប្រកបដោយចីរភាពនេះ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកំពង់ធំនិងស្រុកកំពង់ស្វាយ ព្រមទាំងក្រុមប្រឹក្សាឃុំត្បែង ក្រោមការទទួលសិទ្ធិផ្តល់សេវាកម្មរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំត្បែង ដោយក្រុមហ៊ុន SBK Co.LTd និងមានការគ្រប់គ្រង គាំទ្របច្ចេកទេសដោយអង្គភាពអនុវត្តគម្រោងថ្នាក់ខេត្ត (PIO) និងអង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ (NIO) នៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ព្រមទាំងមានការគាំទ្រនិងឧបត្ថម្ភថវិកាពីរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍអាស៊ីបានរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំត្បែង មានចក្ខុវិស័យឆ្នាំ ២០៣២ សម្រាប់តម្រង់ទិសដល់ការអភិវឌ្ឍឃុំពាក់ព័ន្ធការប្រើប្រាស់ដីនៅក្នុងឃុំត្បែងឆ្លើយតបទៅនឹងកំណើនប្រជាសាស្រ្ត ដើម្បីជាមូលដ្ឋានជួយដល់ក្រុមប្រឹក្សាឃុំត្បែងផ្ទាល់ ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចិរភាព និងសមធម៌ ដែលនៅក្នុងនោះការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដែលជាកត្តាស្នូលនៃការអភិវឌ្ឍឃុំ ធ្វើឱ្យជីវភាពប្រជាពលរដ្ឋ មានភាពប្រសើរឡើងរួចផុតពីភាពក្រីក្រ ជាពិសេសការប្រើប្រាស់ដីកសិកម្មក្នុងឃុំត្បែង ឱ្យអស់សក្តានុពលដែលមាន ក្នុងការផលិតស្រូវ ដើម្បីបង្កើនការនាំចេញអង្ករឱ្យបានច្រើននៅពេលខាងមុខ ដើម្បីឆ្លើយតបបានទៅនឹងគោលនយោបាយ ស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្កររបស់រាជរដ្ឋាភិបាល ដែលនៅសល់ពីការហូបចុក តាមរយៈការប្រើប្រាស់ផែនការប្រើប្រាស់ដីនៅក្នុងឃុំត្បែងនេះ ធ្វើជាមូលដ្ឋានបង្អែក សម្រាប់រៀបចំផែនការអភិវឌ្ឍឃុំនៅតាមអណត្តិនីមួយៗរបស់ខ្លួន។

ផែនការប្រើប្រាស់ដីនៅក្នុងឃុំត្បែង ត្រូវបានរៀបចំឡើង ដោយមានការសិក្សាស្រាវជ្រាវច្បាស់លាស់ទៅលើកត្តាភូមិសាស្រ្ត សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន ព្រមទាំងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួន ដែលពាក់ព័ន្ធនឹងការរៀបចំដែនដី និងនគរូបនីយកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានជាអាទិ៍ ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង

ធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ និងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ។ ចំពោះនីតិវិធីនៃការរៀបចំផែនការនេះវិញ ត្រូវបានរៀបចំឡើង ដោយផ្អែកលើអនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ ព្រមទាំងប្រកាសរួមស្តីពីនីតិវិធីលម្អិតសម្រាប់ការរៀបចំ និងអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់និងឯកសារណែនាំអនុវត្តស្តីពីការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ដែលមានដំណើរការរៀបចំផែនការដូចមានសង្ខេបក្នុងដ្យាក្រាមខាងក្រោម។

ដ្យាក្រាម៖ ដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់



សម្គាល់៖ ប្រអប់បង្ហាញទំហំការងារដែលត្រូវអនុវត្តតាមឯកសារណែនាំ

ជំពូក ១៖ ព័ត៌មានស្តីពីស្ថានភាពឃុំត្បែង

១.១.ស្ថានភាពឃុំ

កាលពីដើមឡើយនៅក្នុងឃុំត្បែង មានបឹងមួយ ហើយនៅក្នុងបឹងនោះមានគងមួយយ៉ាងធំនៅក្នុងនោះ តែដោយសារគងនោះមានទំហំធំ ហើយធ្ងន់ពេកធ្វើឱ្យអ្នកស្រុកមិនអាចស្រង់យកមកលើគោកបាន ដើម្បីធ្វើការរក្សាទុក។ ពេលនោះពួកអ្នកស្រុកបានស្វែងរកវិធីសាស្ត្រផ្សេងៗ ដើម្បីយកគងនោះចេញពីបឹង ដោយពួកគាត់បានត្បាញខ្សែមួយយ៉ាងធំនិងមាំយកទៅចងនឹងគងនោះ រួចអូសទាញយកចេញពីបឹងមករក្សាទុកនៅទីតាំងដែលមានសុវត្ថិភាព រួចមកអ្នកស្រុកបាននាំគ្នាហៅបឹងនោះថាបឹងបាគង និងដាក់ឈ្មោះវត្តនៅទីនោះថាវត្តបាគងដែរ។ មកដល់ជំនាន់ក្រោយៗទៀតពាក្យសែងគងក៏បានក្លាយទៅជាពាក្យសាន់គ រហូតដាក់ឈ្មោះភូមិនៅតំបន់នោះថាភូមិសាន់គ ចំណែកកន្លែង ដែលអ្នកស្រុកត្បាញខ្សែចងគងនោះ ក៏បានក្លាយទៅជាភូមិត្បែង និងឃុំត្បែងរហូតដល់សព្វថ្ងៃ។

១.១.១.ទីតាំងរដ្ឋបាលឃុំ

ឃុំត្បែង ជាឃុំមួយក្នុងចំណោមឃុំទាំង ១១ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ ឃុំនេះមាន១៥ភូមិ គឺភូមិត្រាច ភូមិតារាម ភូមិឫស្សីជះ ភូមិពោធិ៍ ភូមិព្រៃប្រស់ ភូមិបឹងអណ្តែង ភូមិតាអាំ ភូមិត្បែង ក ភូមិត្បែង ខ ភូមិបាគង់ ភូមិត្រាំខ្លា ភូមិស្រង៉ែ ភូមិអូរអំបែង ភូមិក្លូង និងភូមិឈើទាល ហើយឃុំនេះមានផ្ទៃដីសរុបចំនួន ១៤ ១៣៩,៣៧ ហិកតា និងមានព្រំប្រទល់ជាប់នឹង៖

- ខាងជើង ជាប់នឹង ឃុំដំរីស្លាប់ និង ឃុំនីពេជ
- ខាងត្បូង ជាប់នឹង ឃុំកំពង់គោ
- ខាងកើត ជាប់នឹង ឃុំត្រពាំងឫស្សី
- ខាងលិច ជាប់នឹង ឃុំសាន់គ

តារាង 1៖ ស្ថានភាពទូទៅនៃឃុំ

ខេត្ត	កំពង់ធំ	លេខកូដខេត្តៈ៦
ស្រុក	កំពង់ស្វាយ	លេខកូដស្រុកៈ ៦០២
ឃុំ	ត្បែង	លេខកូដឃុំៈ ៦០ ២០៨
ចំនួន១៥ភូមិ	១. ភូមិត្រាច	លេខកូដភូមិៈ ៦ ០២០ ៨០១
	២. ភូមិតារាម	លេខកូដភូមិៈ ៦ ០២០ ៨០២
	៣. ភូមិឫស្សីជះ	លេខកូដភូមិៈ ៦ ០២០ ៨០៣
	៤. ភូមិពោធិ៍	លេខកូដភូមិៈ ៦ ០២០ ៨០៤
	៥. ភូមិព្រៃប្រស់	លេខកូដភូមិៈ ៦ ០២០ ៨០៥
	៦. ភូមិបឹងអណ្តែង	លេខកូដភូមិៈ ៦ ០២០ ៨០៦
	៧. ភូមិតាអាំ	លេខកូដភូមិៈ ៦ ០២០ ៨០៧
	៨. ភូមិត្បែង ក	លេខកូដភូមិៈ ៦ ០២០ ៨០៨
	៩. ភូមិត្បែង ខ	លេខកូដភូមិៈ ៦ ០២០ ៨០៩
	១០. ភូមិបាគង	លេខកូដភូមិៈ ៦ ០២០ ៨១០

	១១. ភូមិត្រាំខ្លា	លេខកូដភូមិៈ ៦ ០២០ ៨១១
	១២. ភូមិស្រង៉ែ	លេខកូដភូមិៈ ៦ ០២០ ៨១២
	១៣. ភូមិអូរអំបែង	លេខកូដភូមិៈ ៦ ០២០ ៨១៣
	១៤. ភូមិភ្លង	លេខកូដភូមិៈ ៦ ០២០ ៨១៤
	១៥. ភូមិឈើទាល	លេខកូដភូមិៈ ៦ ០២០ ៨១៥

ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ត្បែង ខែមេសា ឆ្នាំ២០១៨

ផែនទី 1៖ បង្ហាញទីតាំងឃុំត្បែង



ផែនទី 2៖ ព្រំប្រទល់រដ្ឋបាលឃុំត្បែង



១.១.២.ប្រជាសាស្ត្រ

ក.ចំនួនប្រជាជន

នៅក្នុងឃុំត្បែង ចែកចេញជា ១៥ ភូមិ ដែលមានគ្រួសារសរុបចំនួន ២ ៨៧០ គ្រួសារ ប្រជាជនសរុប ១៥ ៦៤០ នាក់ និងស្ត្រីចំនួន ៨ ៧១០ នាក់ នៅក្នុងនោះប្រជាជនមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ មានចំនួន ៨ ២០៧ នាក់ មានស្ត្រី ៤ ១៨៧ នាក់។ នៅក្នុងឃុំត្បែង ភូមិដែលមានប្រជាជនច្រើនជាងគេ គឺភូមិឈើទាល មាន ២១១ គ្រួសារ ស្មើនឹង ៧,៤ភាគរយ និងប្រជាជនសរុប ១ ៩៩៧នាក់ នៅក្នុងនោះស្ត្រីមាន ១ ៣៥៥នាក់។ ប្រជាជនមានអាយុ១៨ឆ្នាំឡើងចំនួន ៥៤២ នាក់ នៅក្នុងនោះស្ត្រីមានចំនួន ២៦៦ នាក់។ ចំណែកភូមិ ដែលមានប្រជាជនតិចជាងគេ គឺភូមិត្រាច ដែលមាន ៧៣ គ្រួសារ មនុស្សសរុបចំនួន ៤៣៣ នាក់ នៅក្នុងនោះស្ត្រី ២២៧ នាក់ ហើយប្រជាជនអាយុចាប់ពី១៨ឆ្នាំឡើងទៅមានចំនួន ២២៤ នាក់ ក្នុងនោះស្ត្រីចំនួន ១២៥ នាក់។ ទន្ទឹមនេះ ក៏សង្កេតឃើញប្រជាជននៅក្នុងឃុំ ស្ត្រីមានចំនួនច្រើនជាងបុរស ដូចមាន ក្នុងតារាងដែលក្រុមការងារបានរៀបចំសង្ខេបខាងក្រោម។

តារាង 2៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្តាភូមិ

ឈ្មោះភូមិ	គ្រួសារ	គិតជា%	មនុស្ស			១៨ឆ្នាំឡើង		
			សរុប	ប្រុស	ស្រី	សរុប	ប្រុស	ស្រី
ត្រាច	៧៣	២,៥	៤៣៣	២០៦	២២៧	២២៤	៩៩	១២៥
តារាម	៣៣៤	១១,៦	១៧៤០	៨៦៣	៨៧៧	៩៤៣	៤៥៦	៤៨៧
ឫស្សីជះ	២៦៥	៩,២	១២១០	៥៨៨	៦២២	៧៩០	៣៨៥	៤០៥
ពោធិ៍	២១១	៧,៤	១១៤១	៤៩៥	៦៤៦	៥២០	១៧០	៣៥០
ព្រៃប្រស់	១៧៨	៦,២	៩៧៩	៥០២	៤៧៧	៦៣៩	៣១៦	៣២៣
បឹងអណ្តែង	១៨៤	៦,៤	១១៧១	៦៩៥	៤៧៦	៥២៦	២៥៥	២៧
តាអាំ	៨៧	៣,០	៤៥៩	២២៣	២៣៦	២១៣	១១៥	៩៨
ត្បែង ក	២៦២	៩,១	១៥១៩	៧១៥	៨០១	៧៨៧	៣០១	៤៨៦
ត្បែង ខ	២៥៩	៩,០	១៣៦៣	៥៩៣	៧៧០	៧៧៩	៣៨១	៣៩៨
បាគង	២៥៧	៩,០	១៤៩៦	៧៥៦	៧៤០	៨៣៥	៣៤៦	៤៨៩
ត្រាំខ្លា	១៩៧	៦,៩	១០០៨	៤៨៩	៥១៩	៤៤៣	១៩៨	២៤៥
ស្រង៉ែ	៩៥	៣,៣	៤៤៦	២១២	២៣៤	២៧៧	១២១	១៥៦
អូរអំបែង	១០២	៣,៦	៥៩៥	៣០០	២៩៥	២៥៨	១៤៧	១១១
ភ្លូង	១៥៥	៥,៤	៨៣	៤០៤	៤៣៥	៤៣១	២១០	២២១
ឈើទាល	២១១	៧,៤	១៩៩៧	៦៤២	១៣៥៥	៥៤២	២៧៦	២៦៦
សរុប	**២៨៧០**	**១០០**	**១៥៦៤០**	**៧៦៨៣**	**៨៧១០**	**៨២០៧**	**៣៧៧៦**	**៤១៨៧**

ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ត្បែង ខែមេសា ឆ្នាំ២០១៨

ដ្យាក្រាម 1៖ ស្ថិតិប្រជាជនឆ្នាំ ២០១៧



ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ត្បែង ខែមេសា ឆ្នាំ២០១៨

យោងទៅតាមតារាស្ថិតិប្រជាជនតាមក្រុមអាយុនៅក្នុងឆ្នាំ ២០១៧ ក្នុងឃុំត្បែងបានបង្ហាញឱ្យឃើញថា ប្រជាជនពេញកម្លាំងពលកម្ម ដែលមានអាយុចាប់ពី ២៥ ឆ្នាំ ដល់ ៦០ ឆ្នាំ មានចំនួន ៥ ២៧១ នាក់ ស្មើប្រហាក់ប្រហែល ៣២ ភាគរយ នៃប្រជាជនសរុប ក្រៅពីនេះមានអាយុពីកើតដល់ ២៤ ឆ្នាំ មានចំនួន ៩ ៩១២ នាក់ ស្មើប្រហាក់ប្រហែល ៦០ ភាគរយ នៃប្រជាជនសរុប និងប្រជាជនមានអាយុចាប់ពី ៦១ ឆ្នាំឡើង ដែលជាអ្នកចូលនិវត្តន៍បាត់បង់សមត្ថភាពការងារ មានចំនួន ១ ២១០ នាក់ ស្មើប្រហាក់ប្រហែល ៧ ភាគរយ នៃប្រជាជនសរុប។ ដូច្នេះសន្និដ្ឋានបានថា នៅក្នុងឃុំត្បែង មនុស្សពេញកម្លាំងពលកម្មមួយនាក់អាចរកចំណូល បានគិតជាមធ្យមត្រូវចិញ្ចឹមមនុស្សជិតពីរនាក់បន្ថែម។

តារាង ៣៖ ស្ថិតិប្រជាជនតាមក្រុមអាយុ

តាមក្រុមអាយុ	**២០១៧**			**ផ្សេងៗ**
	សរុប	**ប្រុស**	**ស្រី**	
អាយុពី០-២ឆ្នាំ	៦៧៩	៣៤៤	៣៣៥	កុមារ
អាយុពី៣-៤	៧៦៩	៣៨១	៣៨៨	អាយុចូលរៀនសាលាមត្តេយ្យ
អាយុពី៥ឆ្នាំ	៩៧៤	៥៩៧	៣៧៧	អាយុចូលរៀនសាលាមត្តេយ្យ
អាយុពី៦ឆ្នាំ	៨៣៨	៤២៥	៤១៣	អាយុចូលរៀនសាលាបឋម
អាយុពី៧-១១ឆ្នាំ	២៤០៩	៨៤៩	១៥៦០	អាយុចូលរៀនសាលាបឋម
អាយុពី១២-១៤ឆ្នាំ	១២៤៦	៦២៨	៦១៨	អាយុចូលរៀនអនុវិទ្យាល័យ
អាយុពី១៥-១៧ឆ្នាំ	១២៧១	៦៨៣	៥៨៨	អាយុចូលរៀនវិទ្យាល័យ
អាយុពី១៨-២៤ឆ្នាំ	១៧២៦	៧៧៩	៩៤៧	អាយុចូលរៀនមហាវិទ្យាល័យ
អាយុពី២៥-៣៥ឆ្នាំ	២០៤២	៩៨៤	១០៥៨	អាយុពេញពលកម្ម
អាយុពី៣៦-៤៥ឆ្នាំ	១៦៦០	៧៤៨	៩១២	អាយុពេញពលកម្ម
អាយុពី៤៦-៦០ឆ្នាំ	១៥៦៩	៧៣៧	៨៣២	អាយុពេញពលកម្ម
អាយុពី៦១ឆ្នាំឡើង	១២១០	៥២៨	៦៨២	អាយុចូលនិវត្តន៍
សរុប	**១៦៣៩៣**	**៧៦៨៣**	**៨៧១០**	

ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ត្បែង ខែមេសា ឆ្នាំ២០១៨

ខ.អត្រាកំណើន ដង់ស៊ីតេ និងបម្លាយប្រជាជន

ដោយយោងតាម CDB ឆ្នាំ២០១៧ បានឱ្យដឹងថា អត្រាកំណើនប្រជាជនជាមធ្យមក្នុងអំឡុងពេលចន្លោះពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៧ មានចំនួន ២,២០ ភាគរយ ដោយសង្កេតឃើញថា មានការធ្លាក់ចុះខ្លាំងនៅឆ្នាំ ២០១៣ ដែលមានចំនួន -0,០៧ ភាគរយ មូលហេតុនៃការធ្លាក់ចុះនេះ ដោយសារមានការផ្លាស់ប្តូរលំនៅឋានចេញ ការពន្យាកំណើត មរណភាពកុមារ និងដោយសារកត្តាគ្រោះថ្នាក់ចរាចរណ៍ ជម្ងឺ។ល។ ប៉ុន្តែអត្រាកំណើននៅឆ្នាំ២០១៧ មានការកើនឡើងខ្លាំងជាងគេវិញ គឺមានចំនួន ៧,៤៦ ភាគរយ ដែលការកើនឡើងនេះ ដោយសារមានការផ្លាស់ប្តូរទីលំនៅចូលតាមរយៈអាពាហ៍ពិពាហ៍ និងការកើតថ្មី។ តែបើពិនិត្យលើជំរឿនទូទៅប្រជាជនឆ្នាំ ២០១៩ បានឱ្យដឹងថា អត្រាកំណើនជាមធ្យមអំឡុង ១០ឆ្នាំ (២០០៨-២០១៨) នៅខេត្តកំពង់ធំ មានចំនួន ០,៦ ភាគរយ ប្រហាក់ប្រហែលអត្រាកំណើនខាងលើដែរ។ ដូច្នេះ យើងបានកំណត់យកអត្រាកំណើនប្រជាជនជាមធ្យមប្រចាំឆ្នាំ នៅក្នុងឃុំត្បែង ចំនួន ២,២០ ភាគរយ ជាបានការដើម្បីប្រើប្រាស់ក្នុងការព្យាករណ៍កំណើនប្រជាជននៅក្នុងឃុំ។

នៅក្នុងឃុំត្បែង ក្នុងឆ្នាំ២០១៧ មានដង់ស៊ីតេប្រជាជនរស់នៅ ១០៧,៨ នាក់/គម² ដោយការរស់នៅរបស់ប្រជាពលរដ្ឋភាគច្រើន តាំងលំនៅឋានជាលក្ខណៈរាយប៉ាយតាមភូមិ នៅតាមដងផ្លូវសំខាន់ៗនៅក្នុងឃុំ ហើយជាពិសេសនៅតាមបណ្តោយផ្លូវជាតិលេខ៦។

តារាង 4៖ ស្ថិតិប្រជាជនតាមបណ្តាឆ្នាំ និងការគណនាអត្រាកំណើនមធ្យម

ចំនួន	២០១២	២០១៣	២០១៤	២០១៥	២០១៦	២០១៧	កំណើនមធ្យម%
ចំនួនប្រជាជនសរុប	១៤៧២៩	១៤៧១៨	១៤៨៨៧	១៤៩២៨	១៥២៥៥	១៦៣៩៣	
កំណើនមធ្យម(%)		-០,០៧	១,១៥	០,២៨	២,១៩	៧,៤៦	២,២០

ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ត្បែង ខែមេសា ឆ្នាំ២០១៨

☞ចំណាំ

- អត្រាកំណើនសម្រាប់ចន្លោះឆ្នាំនីមួយៗ៖ (ឆ្នាំចុងក្រោយ-ឆ្នាំដំបូង) x ១០០/ឆ្នាំដំបូង
- អត្រាកំណើនមធ្យមប្រចាំឆ្នាំ៖ (បូកសរុបអត្រាកំណើនតាមឆ្នាំនីមួយ/ចំនួនឆ្នាំ)

គ.ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់

នៅក្នុងឃុំត្បែងមានជនជាតិខ្មែរ និងខ្មែរកាត់ចិន ហើយភាគច្រើនកាន់សាសនាព្រះពុទ្ធ និងមានចំនួនតិចតួចកាន់សាសនាគ្រិស្ត ហើយប្រជាជនភាគច្រើននៅក្នុងឃុំគោរពប្រពៃណី និងទំនៀមទម្លាប់បែបខ្មែរ ដូចជាពិធីរៀបមង្គលការប្រារព្ធពីធីបុណ្យទាននៅតាមវត្តអារាម និងតាមផ្ទះ និមន្តព្រះសង្ឃសូត្រមន្តតាមផ្ទះ ពិធីបូជាសព និងមួយចំនួនតិចមានទំនៀមទម្លាប់បែបចិនដូចជាពិធីសែនព្រេនដូនតា ពីធីបញ្ចុះសព និងភាគតិចបំផុតមានទំនៀមទម្លាប់បែបសាសនាគ្រិស្ត ដូចជាមានប្រារព្ធពិធីចូលព្រះវិហារគ្រិស្តនៅរៀងរាល់ថ្ងៃអាទិត្យជាដើម។ល។ និយាយរួមប្រជាជនក្នុងឃុំត្បែង តែងតែប្រារព្ធពិធីបុណ្យទានតាមប្រពៃណីទំនៀមទំលាប់ពីបុរាណរៀងមក ទៅតាមជំនឿបែបខ្មែរ បែបចិន និងបែបគ្រិស្តសាសនា។

ឃ.របររកទទួលទាន

បើយោងទៅតាមទិន្នន័យនៅក្នុងតារាងខាងក្រោម បានបង្ហាញឱ្យឃើញថា នៅក្នុងឃុំត្បែង ប្រជាពលរដ្ឋមានមុខរបរចម្បង ចំនួន ៦ ៧៥៧ នាក់ ស្មើនឹង ៩៦,៦ ភាគរយ ហើយនៅក្នុងនោះប្រជាពលរដ្ឋភាគច្រើនប្រកបមុខរបរកសិកម្មជាចម្បង ដែលមានរហូតដល់ ៥ ៧៧០ នាក់ ស្មើនឹង ៨៥,៤ ភាគរយ មុខរបរសិប្បកម្មជាចម្បងមានចំនួន ២១៤ នាក់ ស្មើនឹង ៣,២ ភាគរយ និងមុខរបរសេវាកម្មមានចំនួន ៧៧៣ នាក់ ស្មើនឹង ១១,៤ភាគរយ ដែលមុខរបរទាំងនោះមានដូចជា៖ ធ្វើស្រែ ចិញ្ចឹមសត្វ ដាំដំណាំបន្លែ នេសាទត្រី កម្មករសំណង់ ស៊ីឈ្នួលដកស្ទូង ហាលស្រូវ ច្រកស្រូវ លីស្រូវ លក់ដូរ ជាងជួសជុលកង់ ម៉ូតូ ជាងកាត់សក់ ជាមន្ត្រីរាជការ អាជីវ ការលក់ដូរ ធ្វើការជាមួយវិស័យ ឯកជន និងអង្គការនានា ដែលភាគច្រើនធ្វើការមានជំនាញច្បាស់លាស់។

តារាង 5៖ តារាងមុខរបរ

បរិយាយ	២០១៧
សរុបអ្នកមានមុខរបរចម្បង	៦៧៥៧ នាក់
%សរុបអ្នកមានមុខរបរចម្បង	៩៦,៦ %
%ស្រីមានមុខរបរចម្បង(គិតក្នុងស្រី១៨-៦០ឆ្នាំ)	៧៧,៨ %

បរិយាយ		២០១៧
%ប្រុសមានមុខរបរចម្បង(គិតក្នុងប្រុស១៨-៦០ឆ្នាំ)		៨៧,៧ %
សរុបអ្នកមានមុខរបរចម្បងក្នុងផ្នែកកសិកម្ម		**៥៧៧០** នាក់
%**អ្នកមានមុខរបរចម្បងផ្នែកកសិកម្ម**(**គិតក្នុងមុខរបរចម្បង**)		**៨៥,៤** %
%**ស្រីមានមុខរបរចម្បងផ្នែកកសិកម្ម**(**គិតក្នុងមុខរបរចម្បង**)		**៤៣,២** %
ក្នុងនោះ	%អ្នកមានមុខរបរធ្វើស្រែ	៧៥,៧ %
	%អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលវែង	២,៩ %
	%អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលខ្លី	២,២ %
	%អ្នកមានមុខរបរដាំដំណាំបន្លែ	៣ %
	%អ្នកមានមុខរបរនេសាទ	០,៦ %
	%អ្នកមានមុខរបរចិញ្ចឹមសត្វ	១ %
	%អ្នកមានមុខរបរពីអនុផលព្រៃឈើ	០,០
សរុបអ្នកបម្រើការងារ(មុខរបរចម្បង) **ក្នុងផ្នែកសិប្បកម្ម**		**២១៤** នាក់
%**អ្នកបម្រើការងារក្នុងផ្នែកសិប្បកម្ម**		**៣,២** %
%**ស្រីបម្រើការងារក្នុងផ្នែកសិប្បកម្ម**		**១,៩** %
ក្នុងនោះ	%អ្នកបម្រើការងារសិប្បកម្មត្បាញរវៃ	០,០
	%អ្នកបម្រើការងារសិប្បកម្មផលិតពីផ្តៅ វល្លិ ល្ពាក់...	០,០
	%អ្នកបម្រើការងារសិប្បកម្មផលិតគ្រឿងសង្ហារឹម	០,០
	%អ្នកបម្រើការងារសិប្បកម្មចម្លាក់ធ្វើពីឈើ ថ្ម ស្ពាន់..	០,០
	%អ្នកបម្រើការងារសិប្បកម្មផលិតពីដែក អាលុយមីញ៉ូម	៣,២ %
	%អ្នកបម្រើការងារសិប្បកម្មផលិតពីជ័រ ប្លាស្ទិក ...	០,០
	%អ្នកបម្រើការងារសិប្បកម្មកែច្នៃឬវេចខ្ចប់គ្រាប់ធញ្ញជាតិ	០,០
	%អ្នកបម្រើការងារសិប្បកម្មផលិតផ្សេងៗ	០,០
សរុបអ្នកបម្រើការងារ(មុខរបរចម្បង) **ក្នុងផ្នែកសេវាកម្ម**		៧៧៣ នាក់
%**អ្នកបម្រើការងារ**(មុខរបរចម្បង) **ក្នុងផ្នែកសេវាកម្ម**		១១,៤ %
%**ស្រីបម្រើការងារ**(មុខរបរចម្បង) **ក្នុងផ្នែកសេវាកម្ម**		៥,៥ %
ក្នុងនោះ	%អ្នកបម្រើការងារលក់ដូរ និងជំនួញ	០,៤ %
	%អ្នកបម្រើការងារជាជាងជួសជុល	០,២ %
	%អ្នកបម្រើការងារក្នុងផ្នែកដឹកជញ្ជូន	០,១ %
	%អ្នកបម្រើការងារស៊ីឈ្នួលក្នុងវិស័យកសិកម្ម កម្មករសំណង់	៦,៤ %
	%អ្នកបម្រើការងារក្នុងវិស័យឯកជន(កម្មកររោងចក្រ បុគ្គលិកអង្គការ)	៣,២ %
	%អ្នកបម្រើការងារជាមន្ត្រីរាជការ	១,២ %

ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ត្បែង ខែមេសា ឆ្នាំ២០១៨

ប្រជាពលរដ្ឋនៅក្នុងឃុំត្បែង ពួកគាត់បានបង្កើតមុខរបរបន្ទាប់បន្សំបន្ថែមទៀត ក្រៅពីមុខរបរចម្បង ដើម្បីទ្រទ្រង់ជីវភាពក្នុងគ្រួសារឱ្យកាន់តែប្រសើរឡើង ដែលនៅក្នុងនោះប្រជាជន ដែលមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្ម មានចំនួន ១ ៤១៥៥ នាក់ ស្មើនឹង ៨៦,៥ ភាគរយ និងស្ត្រីចំនួន ៦០០ នាក់ ស្មើនឹង ៣៥,៧ ភាគរយ មុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្ម មានចំនួន ៨៦ នាក់ ស្មើនឹង ៥,១ ភាគរយ នៅក្នុងនោះស្រីមានចំនួន ៣៥ នាក់ ស្មើនឹង ២,១ ភាគរយ និងមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្មចំនួន ១២៩ នាក់ ស្មើនឹង ៨,៤ ភាគរយ មានស្រីចំនួន ៦៤ នាក់ ស្មើនឹង ៣,៨ ភាគរយ។

ដូច្នេះតាមព័ត៌មានខាងលើបានបង្ហាញឱ្យឃើញថា ប្រជាពលរដ្ឋ នៅក្នុងឃុំត្បែង ក្រៅពីប្រកបរបរធ្វើស្រែជាចម្បង មានមួយចំនួនប្រមាណជិតពាក់កណ្តាល បានខិតខំប្រកបរបរទទួលទានបន្ទាប់បន្សំថែមទៀត ដែលមានដូចជាលក់ដូរ និងជំនួញ ផ្នែកដឹកជញ្ជូន និង កម្មករសំណង់ ។ល។ ចំណែកអ្នកដែលមានរបរផ្នែកសេវាកម្មជាចម្បងមានស្ទើរតែទាំងអស់បានខិតខំប្រកបរបរកសិកម្មដែលជាមុខរបរបន្ទាប់បន្សំបន្ថែមទៀតផងដែរ ដូចមានរៀបរាប់ក្នុងតារាងខាងក្រោមនេះ៖

តារាង 6៖ តារាងមុខរបរបន្ទាប់បន្សំ

បរិយាយ	២០១៧	២០១៧ចំនួន(នាក់)
%អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្ម	៨៦,៥ %	១៤៥៥
%ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្ម	៣៥,៧ %	៦០០
%អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្ម	៥,១ %	៨៦
%ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្ម	២,១ %	៣៥
%អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម	៨,៤ %	១២៩
%ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម	៣,៨ %	៦៤

ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ត្បែង ខែមេសា ឆ្នាំ២០១៨

ង.ចំណូលស្រុក និងចំណាកស្រុក

កត្តាដែលធ្វើឱ្យមានការផ្លាស់ប្តូរលំនៅឋាន គឺដោយសារនៅភូមិចាស់ដែលគាត់បានរស់នៅពិបាកក្នុងការរកស៊ី និងគ្មានការងារធ្វើនៅក្នុងភូមិ ព្រមទាំងមូលហេតុមួយចំនួនទៀត ដូចជា ៖ ស្ថានភាពដី នៅក្នុងតំបន់មូលដ្ឋានមួយចំនួនមានការប្រែប្រួលដោយដីខូច ងាប់សារជាតុបម្រុង ហើយឡើងខ្សោះ ឬហឺរជាដើម ខ្វះប្រភពទឹក ធ្វើឱ្យទទួលបានទិន្នផលទាប តម្លៃផលិតផលកសិកម្មមិនទៀងទាត់ និងគ្មានទីផ្សារផលិតផល ចំណែកសមាជិកគ្រួសារកើនឡើង និងមួយចំនួនជាប់បំណុលធនាគារ និងមីក្រូហិរញ្ញវត្ថុជាដើម។ល។ ការផ្លាស់ប្តូរលំនៅឋាន របស់ប្រជាជនមួយចំនួនទៅរស់នៅ ទីប្រជុំជនឃុំ/សង្កាត់ ស្រុក/ក្រុង ខេត្ត/រាជធានី និងទៅធ្វើការងារនៅប្រទេសផ្សេងៗ។ មូលហេតុចម្បងនៃការធ្វើចំណាកស្រុកគ្រប់ប្រភេទ គឺក្នុងគោលបំណងលើកស្ទួយជីវភាពគ្រួសារ ។ នៅក្នុងឃុំត្បែង មានគ្រួសារផ្លាស់លំនៅឋានចូលចំនួន ០៣ គ្រួសារ មនុស្សសរុបចំនួន ១១ នាក់ ក្នុងនោះស្រីមានចំនួន ០៥ នាក់ និងគ្រួសារផ្លាស់លំនៅឋានចេញមានចំនួន ០៦ គ្រួសារ មានមនុស្សសរុបចំនួន ២៣ នាក់ ក្នុងនោះមានស្រីចំនួន ១៣ នាក់។

តារាង 7៖ ស្ថិតិប្រជាជនផ្លាស់ប្តូរទីលំនៅក្នុងឆ្នាំ២០១៦-២០១៧

ល.រ	បរិយាយ	ចំនួនគ្រួសារ	ចំនួនប្រជាជនសរុប	
			សរុប	ស្រី
១	ចំនួនគ្រួសារផ្លាស់លំនៅឋានចូល	០៣	១១	០៥
២	ចំនួនគ្រួសារផ្លាស់លំនៅឋានចេញ	០៦	២៣	១៣

ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ត្បែង ខែមេសា ឆ្នាំ២០១៨

ប្រជាជននៅក្នុងឃុំត្បែង មានអ្នកចំណាកស្រុកសរុប ១ ៨៨៦ នាក់ មានស្រី ៩២៤ នាក់ ដែលក្នុងនោះ អ្នកចំណាកស្រុកក្នុងប្រទេស មានចំនួន ១ ១០៧ នាក់ និងមានស្រី ៥៤៥ នាក់ ហើយប្រជាជនធ្វើចំណាកស្រុកក្រៅប្រទេសមានចំនួន ៧៧៩ នាក់ នៅក្នុងនោះមានស្រី ៣៧៩ នាក់ ។ ជាទូទៅចំណាកស្រុករបស់ប្រជាពលរដ្ឋភាគច្រើនទាំងក្នុង និងក្រៅប្រទេស គឺមិនអចិន្ត្រៃយ៍នោះទេ ពួកគាត់ទៅធ្វើការនៅ ស្រុក ខេត្តផ្សេង រាជធានីភ្នំពេញ និងក្រៅប្រទេស មានប្រទេសថៃ ម៉ាឡេស៊ី ជប៉ុន និងប្រទេសកូរ៉េជាដើម ដោយពួកគាត់ទៅតែមួយរយៈប៉ុណ្ណោះ ហើយពួកគាត់តែងតែមកស្រុកជារឿយៗ។

ប្រជាជនធ្វើចំណាកស្រុកចេញទៅរកស៊ីនៅស្រុក និងខេត្តផ្សេងៗ ឬទៅប្រទេសជិតខាងដូចជាប្រទេសថៃជាដើម ដោយសារកត្តាមួយចំនួនដូចខាងក្រោម៖

- ដីបង្កបង្កើនផលសម្រាប់វិស័យកសិកម្មតិចតួច ធ្វើស្រែបានផលតិច
- ការធ្វើស្រែចម្ការបានតែមួយរដូវ និងគ្មានទីផ្សារគ្រប់គ្រាន់សម្រាប់លក់ផលិតផល
- មិនមានការងារគ្រប់គ្រាន់នៅក្នុងស្រុក
- ជំពាក់បំណុលធនាគារ ឬឯកជនមិនមានលទ្ធភាពសង
- គ្មានមុខរបរច្បាស់លាស់ និងមានប្រាក់ចំណូលប្រចាំថ្ងៃទាប។
- កំណើនសមាជិកគ្រួសារមានមានការកើនឡើង។
- ដោយធ្វើស្រែប្រើឧបករណ៍ពាក់កណ្តាលស្វ័យប្រវត្តិធ្វើឱ្យកម្លាំងពលកម្មថយចុះ។
- គ្រួសារមានដីតិចតួច មិនគ្រប់គ្រាន់ក្នុងការចិញ្ចឹមគ្រួសារ បន្ទាប់មកលក់ចេញទៅស្រុកផ្សេង។

តារាង ៨៖ ស្ថិតិប្រជាជនចំណាកស្រុក

បរិយាយ	២០១៦			២០១៧		
	សរុប	ប្រុស	ស្រី	សរុប	ប្រុស	ស្រី
ចំនួនអ្នកធ្វើចំណាកស្រុកក្នុងប្រទេស	១០៥៧	៥២១	៥៣៦	១១០៧	៥៦២	៥៤៥
ចំនួនអ្នកធ្វើចំណាកស្រុកក្រៅប្រទេស	៨១៩	៤៧១	៣៤៨	៧៧៩	៤០០	៣៧៩
សរុប	**១៨៧៦**	**៩៩២**	**៨៨៤**	**១៨៨៦**	**៩៦២**	**៩២៤**

ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ត្បែង ខែមេសា ឆ្នាំ២០១៨

១.១.៣.ស្ថានភាពសេដ្ឋកិច្ច

ក.ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ

បើយោងតាមរបាយការណ៍ ស្តីពីការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន នៅត្រង់ចំណុចនៃការវិភាគចំណាត់ថ្នាក់ទ្រព្យធនបានឱ្យដឹងថាគ្រួសារដែលមានជីវភាពគ្រាន់បើ និងគ្រួសារមានជីវភាពមធ្យម មានប្រភពចំណូលទី១ គឺ

លក់ស្រូវ ប្រភពចំណូលទី២ គឺចម្ការ និងប្រភពចំណូលទី៣ គឺលក់ជ្រូក គោ ក្របី។ គ្រួសារមានជីវភាពក្រ និងក្រណាស់មានមានប្រភពចំណូលតែមួយគត់ គឺលក់កម្លាំងពលកម្ម។

ខ.កម្រិតជីវភាពរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ

តាមតារាងចំណាត់ថ្នាក់ទ្រព្យធននៅក្នុងឆ្នាំ២០១៧ ដែលទទួលបានពីរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានខាងលើ បានបង្ហាញឱ្យឃើញថា ក្នុងឆ្នាំ២០១៧ ប្រជាពលរដ្ឋនៅក្នុងឃុំត្បែង មានកម្រិតជីវភាពរស់នៅចែកចេញជាបួនកម្រិត គឺ ១)គ្រួសារបង្គួរ/គ្រាន់បើ ដែលជាគ្រួសារ មានកម្រិតជីវភាពធូរធាជាងគេ មានដីលំនៅឋានកាន់កាប់ ចំនួន ០,២៥ ហិកតា ដីស្រែចំនួន ៣-៤ ហិកតា និងដីផ្សេងៗ មានចំនួន ១០ ហិកតា។ ២)គ្រួសារមធ្យម មានដីលំនៅឋានចំនួន ០,១៥ ហិកតា ដីស្រែ ១-២ ហិកតា និងដីផ្សេងៗ មានចំនួន ៥ ហិកតា ។ ៣)គ្រួសារក្រ មានដីលំនៅឋានចំនួន ០,០០៥ ហិកតា ដីស្រែចំនួន ០,៥ ហិកតា ។ ៤)គ្រួសារក្រណាស់ ដែលជាគ្រួសារក្រីក្របំផុត មានដីលំនៅឋានចំនួន ០,០០៥ ហិកតា និងដីក្រៅពីនោះមិនមាននោះទេ។

យោងតាមការសាកសួរជាមួយនឹងក្រុមប្រឹក្សាឃុំត្បែង បានបង្ហាញថាចំណូលប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋជាមធ្យមចាប់ពីចាប់ពី ១០ ០០០-១៥ ០០០ រៀលក្នុង១គ្រួសារ និងប្រចាំឆ្នាំចាប់ពី៣៦៥០០០០-៥៤៧៥០០០ រៀលក្នុង១គ្រួសារ ចំណែកការចំណាយប្រចាំឆ្នាំ មានដូចជា៖ ស្បៀងអាហារ សម្លៀកបំពាក់ ឧបករណ៍កសិកម្ម និងប្រើប្រាស់ សម្ភារៈសិក្សា ថ្នាំសង្កូវ ព្រមទាំងការចំណាយផ្សេងៗចាប់ពី ២ ៥៥៥ ០០០-៣ ៦៥០ ០០០រៀល/គ្រួសារ/ឆ្នាំ។

តារាង ៩៖ តារាងកម្រិតជីវភាពរបស់ប្រជាជន

ចំណាត់ថ្នាក់ធនធាន	បង្គួរ/គ្រាន់បើ	មធ្យម	ក្រ	ក្រណាស់/គ្មានដី	សរុប
ប្រៀបធៀបជា(%) តំបន់ទីI	១៥%	៨៥%	0%	0%	១00%
តំបន់ទីII	១៥%	៦៥%	១៨%	២%	១00%
តំបន់ទីIII	២៥%	៦៥%	១0%	0%	១00%
តំបន់ទីIV	១00	0%	0%	0%	១00%
ទូទាំងឃុំ	-	-	-	-	-
ទំហំគ្រួសារ	៤-៥ នាក់	៦-៧ នាក់	៣-៤ នាក់	៧-៨ នាក់	-
កម្លាំងពលកម្ម	៤	៥	១	៤	-
ទំហំដីកាន់កាប់សរុប(ហ.ត)	-	-	-	-	-
ចំនួន និងប្រភេទក្បាលដី	-	-	-	-	-
ដីលំនៅឋាន(ហ.ត)	0.២៥	0.១៥	0.00៥	0.00៥	-
ដីស្រែ(ហ.ត)	៣-៤	១-២	0.៥	0	-
ដីផ្សេងៗទី១(ហ.ត)	១0	៥	0	0	-
ដីផ្សេងៗទី២(ហ.ត)	-	-	-	-	-
ដំណាំទី១៖ ស្រូវ (ហ.ត)	-	-	-	-	-
ដំណាំទី២៖ ឪឡឹក (ហ.ត)	-	-	-	-	-
ដំណាំទី៣៖.......... (ហ.ត)	-	-	-	-	-
ការចិញ្ចឹមត្រី	-ចិញ្ចឹម	-ចិញ្ចឹម	-	-	-

	ក្នុងស្រះ	ក្នុងស្រះ			
ចំនួនគោ	៥-១០ ក្បាល	៥-៦ ក្បាល	១-២ ក្បាល	0	-
ចំនួនក្របី	-	-	-	-	-
ចំនួនជ្រូក	១០-១៥ ក្បាល	៤-៥ ក្បាល	0	0	-
ការប្រើប្រាស់ឧបករណ៍នេសាទ	-	-អួន, ម៉ង សន្ទូច សំណាញ់, អញ្ជង, ទ្រូ	-អួន, សន្ទូច, ម៉ង សំណាញ់, អញ្ជង, ទ្រូ	-អួន, សន្ទូច, ម៉ង សំណាញ់, អញ្ជង, ទ្រូ	-
ប្រភពចំណូលទី១៖	-លក់ស្រូវ	-លក់ស្រូវ	-លក់កម្លាំង	-លក់កម្លាំង	-
ប្រភពចំណូលទី២៖	-ចម្ការ	-ចម្ការ	-	-	-
ប្រភពចំណូលទី៣៖	-លក់ជ្រូក គោ ក្របី	-លក់ជ្រូក គោ ក្របី	-	-	-
ការងារក្រៅពីកសិកម្ម (ប្រភេទពលកម្ម)	-លក់ចាប់ហួយ -គ្រឿងសំណង់ -ហាងបាយ	-លក់ ចាប់ហួយ -សំណង់ -ហាងបាយ	-លក់កម្លាំងពលកម្មទៅភ្នំពេញនិងក្រៅប្រទេស	-លក់កម្លាំងពលកម្មទៅភ្នំពេញនិងក្រៅប្រទេស	-
ការប្រើប្រាស់ឥណទាន	-ធនាគារ	-ធានាគារ	-មីក្រូហិរញ្ញវត្ថុនិងឈ្នួញក្នុងភូមិ	-មីក្រូហិរញ្ញវត្ថុនិងឈ្នួញក្នុងភូមិ	-

ប្រភព៖ *របាយការណ៍វិភាគប្រព័ន្ធកៀក្រ-បរិស្ថានឃុំត្បែង*

គ.ស្ថានភាពចំណូលសរុប និងអត្រាការប្រាក់

ប្រជាពលរដ្ឋនៅក្នុងឃុំត្បែង មានចំនួន ៧៤៧ គ្រួសារ ស្មើនឹងប្រមាណ ២៦ភាគរយ ដែលជាប់បំណុលពីមីក្រូហិរញ្ញវត្ថុ និងធនាគារ ដូចមានរាយខាងក្រោម៖

- អ្នកមានជីវភាពបង្គួរ៖ មានលទ្ធភាពអាចខ្ចីប្រាក់ពីធនាគារ យកមកចងការបន្ត និងពង្រីកមុខរបរដូចជា កសិកម្ម សិប្បកម្ម និងលក់ដូរ។ល។
- អ្នកមានជីវភាពមធ្យម៖ មានលទ្ធភាពខ្ចីប្រាក់ពីធនាគារ យកមកចងការបន្ត និងពង្រីកមុខរបរដូចជា កសិកម្ម សិប្បកម្ម និងលក់ដូរ។ល។
- អ្នកមានជីវភាពខ្សត់ខ្សោយក្រ៖ ពុំអាចមានលទ្ធភាពខ្ចីប្រាក់ពីធនាគារ ឬមីក្រូហិរញ្ញវត្ថុឯកជនទេ ដោយសារគ្មានទ្រព្យបញ្ចាំ តែត្រូវខ្ចីប្រាក់បន្តពីអ្នកមានជីវភាពបង្គួរ និងមធ្យម។
- ចំណែកអ្នកក្របំផុត៖ ប្រកបរបរដោយលក់កម្លាំងពលកម្ម និងធ្វើចំណាកស្រុក។

នៅក្នុងឃុំត្បែង មិនមានទីតាំងមីក្រូហិរញ្ញវត្ថុ ឬក៏សាខាធនាគារទេ ហើយនៅក្នុងនោះដែរ ប្រជាពលរដ្ឋបានទទួលសេវាកម្ចីលុយពីមីក្រូហិរញ្ញវត្ថុ និងធនាគារមួយចំនួនមានដូចជា៖ ធនាគារអេស៊ីលីដា ធនាគារស្ថាបនា ធនាគារប្រៃសណីយ៍ និងមីក្រូហិរញ្ញវត្ថុអម្រឹត មីក្រូហិរញ្ញវត្ថុហត្ថាកសិករ មីក្រូហិរញ្ញវត្ថុប្រាសាក់ មីក្រូហិរញ្ញវត្ថុអេ អឹម ខេ មីក្រូហិរញ្ញវត្ថុវីសិនហ្វាន់ មីក្រូហិរញ្ញវត្ថុក្រេឌីត មីក្រូហិរញ្ញវត្ថុសហគ្រិន មីក្រូហិរញ្ញវត្ថុ LOLC និងសហគមន៍សន្សំប្រាក់៣ភូមិ មានអត្រាកាប្រាក់ ០៣ភាគរយ ហើយសម្រាប់អត្រាការប្រាក់ អាស្រ័យទៅលើចំនួនទឹកប្រាក់ដែលខ្ចី បើចំនួនប្រាក់កាន់តែច្រើន អត្រាការប្រាក់កាន់តិច ០,៩៩ ភាគរយ តែបើចំនួនទឹកប្រាក់កាន់តិច

អត្រាការប្រាក់កាន់តែច្រើន ១,៨ ភាគរយ ។ ចំណែកអ្នកខ្សត់ខ្សោយ ដែលខ្ចីប្រាក់បន្តពីអ្នកមានជីវភាពបង្គួរ និងមធ្យម មានអត្រាការប្រាក់ខ្ពស់ គឺចាប់ពី ១,៥ភាគរយ ទៅ ១០ភាគរយ ។

ឃ.ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬក្រោមរូបភាពផ្សេងៗ

ជាទូទៅប្រជាពលរដ្ឋនៅក្នុងឃុំត្បែង បានប្រើប្រាស់មីក្រូឥណទាន ជាសាច់ប្រាក់សុទ្ធ គឺដើម្បីយកទៅពង្រីកមុខរបរ ចងការបន្តទិញសម្ភារៈកសិកម្ម ទិញជី និងប្រើប្រាស់តាមតម្រូវការចាំបាច់ផ្សេងៗទៀត ហើយក៏នៅមានក្រោមរូបភាព ដែលប្រជាពលរដ្ឋមួយចំនួនទៅទទួលយកជីជាក់ស្រូវមុន និងសន្យាសងប្រាក់នៅពេលប្រមូលផលស្រូវផងដែរ។

ង.ចំណូលពីប្រភពផ្សេងៗ

ប្រជាពលរដ្ឋនៅក្នុងឃុំត្បែង ពួកគាត់អាចទទួលបាននូវប្រភពចំណូលពីប្រភពផ្សេងៗដូចជា៖

- ចំណាកស្រុកក្រៅប្រទេស(ពលករផ្នែក កសិកម្ម ឧស្សាហកម្ម) ដូចជា ប្រទេសថៃ កូរ៉េជាដើម
- និងចំណូលមួយចំនួនតូចទៀតគឺបានមកពីក្រុមគ្រួសារឬបងប្អូនរស់នៅជាអចិន្ត្រៃយ៍នៅបរទេស ដែលពួកគាត់បានផ្ញើមកដើម្បីផ្គត់ផ្គង់គ្រួសារនៅស្រុកខ្មែរ។

១.១.៤.ស្ថានភាពសិក្សាធិការ

ក.ស្ថានភាពអប់រំ

តាមផែនការអភិវឌ្ឍឃុំត្បែង ៥ឆ្នាំ (២០១៧-២០២២) បានឱ្យដឹងថា ជារៀងរាល់ឆ្នាំកុមារា កុមារី គ្រប់អាយុចូលរៀន បានមកចុះឈ្មោះចូលរៀនគ្រប់គ្នា ទោះបីជាកុមារ ស្ថិតនៅក្នុងស្ថានភាពគ្រួសារក្រីក្រ គ្រួសារដែលជាស្ត្រីមេម៉ាយឬក្មេងកំព្រា កុមារពិការក៏ដោយក្តី។ មកដល់ពេលបច្ចុប្បន្ននេះ វិស័យអប់រំនៅក្នុងឃុំត្បែង មានការរីកចម្រើន ដូចជា អគារសិក្សាត្រូវបានសាងសង់ថ្មីៗ និងមានការកែលម្អបន្ទប់រៀនថែមទៀត នៅតាមសាលារៀនគ្រប់កម្រិត ដែលផ្តល់លទ្ធភាពឱ្យសិស្សបានរៀនសូត្រគ្រប់ពេលពុំមានការខ្វះខាតឡើយ។ ចំណុចអវិជ្ជមានក៏មាននៅក្នុងឃុំផងដែរដូចជាខ្វះគ្រូបង្រៀន មិនទាន់មានសាលាមត្តេយ្យសហគមន៍គ្រប់គ្រាន់ នៅតាមតាមភូមិនៅឡើយ មានអ្នកមិនចេះអក្សរ(អនក្ខរជន) ជាពិសេសមនុស្សមានវ័យចំណាស់ ពួកគាត់ពុំសូវមានស្មារតីសិក្សារៀនសូត្រ ទោះបីមានការយកចិត្តទុកដាក់ជំរុញលើកទឹកចិត្តពីអាជ្ញាធរមូលដ្ឋានយ៉ាងណាក៏ដោយ។

រូបភាព 1៖ សាលារៀន

សាលាបឋមសិក្សាក្នុងឃុំត្បែង

សាលាវិទ្យាល័យក្នុងឃុំត្បែង

ឃុំត្បែង មានកម្រិតអប់រំចាប់ពីមត្តេយ្យសិក្សារហូតដល់ទៅវិទ្យាល័យ។ សាលាមត្តេយ្យសិក្សា មានចំនួន ០៦ កន្លែង ០៦ បន្ទប់ ០៨ ថ្នាក់ មានគ្រូបង្រៀនចំនួន ០៤ នាក់ ជាស្ត្រី ហើយសិស្សដែលកំពុងរៀន មានចំនួន ២៥៥ នាក់ ក្នុងនោះស្រីមានចំនួន ១២៨ នាក់។ សាលាបឋមសិក្សាមានចំនួន ១២ កន្លែង ៨៩ បន្ទប់ ៨២ ថ្នាក់ មានគ្រូបង្រៀនចំនួន ៦៥ នាក់ ជាស្ត្រី ៤០ នាក់ ហើយសិស្សដែលកំពុងរៀនមានចំនួន ២ ២៩៩ នាក់ ក្នុងនោះមានសិស្សស្រីចំនួន ១ ០៩៩ នាក់ ។ សាលាអនុវិទ្យាល័យមានចំនួន ០១ កន្លែង ១៥ បន្ទប់ ១៤ ថ្នាក់ មានគ្រូបង្រៀនចំនួន ២២ នាក់ ក្នុងនោះស្រី ០៨ នាក់ និងសិស្សដែលកំពុងរៀនមានចំនួន ៥៥៥ នាក់ ក្នុងនោះស្រីចំនួន ៣៤២ នាក់ និងសាលាវិទ្យាល័យមានចំនួន ០១ កន្លែង ១៥ បន្ទប់ ១៤ ថ្នាក់ គ្រូបង្រៀនចំនួន ១៩ នាក់ ក្នុងនោះមានស្រី ១០ នាក់ ហើយសិស្សកំពុងរៀនមានចំនួន ៥៨៧ នាក់ និងស្រីមានចំនួន ៣៣៣ នាក់ ។

តារាង 10៖ ស្ថិតិសាលារៀន ស្ថានភាពអប់រំ និងសិក្សាធិការក្នុងឃុំឆ្នាំ២០១៧

ស្ថានភាពសាលា	ចំនួនសាលារៀន			ចំនួនសិស្ស		គ្រូបង្រៀន	
	សាលា	បន្ទប់	ថ្នាក់	សរុប	ស្រី	សរុប	ស្រី
១.សាលាមត្តេយ្យ	៦	៦	៨	២៥៥	១២៨	៤	៤
២.សាលាបឋមសិក្សា	១២	៨៩	៨២	២២៩៩	១០៩៩	៦៥	៤០
៣.អនុវិទ្យាល័យ	១	១៥	១៤	៥៥៥	៣៤២	២២	៨
៤.វិទ្យាល័យ	១	១៥	១៤	៥៨៧	៣៣៣	១៩	១០

ប្រភព៖ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ត្បែង ខែមេសា ឆ្នាំ២០១៨*

ខ.ស្ថានភាពអក្ខរកម្ម

ដោយយោងទៅតាមទិន្នន័យពីមន្ទីរផែនការឆ្នាំ២០១៧ បង្ហាញឱ្យឃើញថា នៅក្នុងឃុំត្បែង ប្រជាជនមានអាយុពី ១៥-២៤ ឆ្នាំ មានចំនួន ៦ ៦៩៩ នាក់ ក្នុងចំណោមអ្នកទាំងនោះ មានអ្នកមិនចេះអក្សរចំនួន៧ភាគរយ។ បើយើងគិតទៅតាមក្រុមអាយុ យើងឃើញថា អ្នកមិនចេះអក្សរអាយុពី ១៥-២៤ឆ្នាំ មានចំននួនសរុប ៧៨ នាក់ ស្មើនឹង ២,៦ ភាគរយ និងអ្នកមិនចេះអក្សរអាយុ ២៥-៤៥ ឆ្នាំ មានចំនួន ៣៩១ នាក់ ស្មើនឹង ១០,៦ ភាគរយ។

ប្រជាជនភាគច្រើន មិនបានចូលរៀនដោយសារសាលារៀននៅឆ្ងាយពីភូមិ ឃុំ ប្រជាពលរដ្ឋនៅតែមានកង្វះមធ្យោបាយធ្វើដំណើរទៅសាលារៀន ខ្វះថវិកាសម្រាប់ទិញសម្ភារៈសិក្សា សម្លៀកបំពាក់ និងផ្នត់គំនិតរបស់ឪពុកម្តាយចាស់គំរឹល ឬមិនជឿនលឿន ហើយនៅក្នុងឃុំនៅមានថ្នាក់អក្ខរកម្មជាប្រចាំ តែពួកគាត់ពុំទាន់មានពេលសិក្សាព្រោះជាប់រវល់ប្រកបរបរចិញ្ចឹមជីវិត ជាហេតុនាំមកនូវការភ្លេចអក្សរ ក្នុងចំណោមអ្នកដែលបានចូលមកសិក្សាក្នុងថ្នាក់អក្ខរកម្មកន្លងមក។

- អនុវិស័យអប់រំក្រៅប្រព័ន្ធ

ក្របខ័ណ្ឌស្ថាប័ន និងគោលនយោបាយ បានពង្រឹងតាមរយៈការពិនិត្យឡើងវិញ នូវគោលនយោបាយអប់រំក្រៅប្រព័ន្ធ ការបង្កើតអនុក្រុមការងារអប់រំក្រៅប្រព័ន្ធ និងមានភារកិច្ចច្បាស់លាស់ ការវាយតម្លៃសមត្ថភាពអប់រំក្រៅប្រព័ន្ធ និងការកសាងផែនទី ក៏ដូចជាការពិនិត្យឡើងវិញនូវកម្មវិធីចូលរៀនឡើងវិញ ព្រមទាំងការរៀបចំសេចក្តីណែនាំស្តីពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំនៅក្រៅប្រព័ន្ធ និងកម្មវិធីសមមូល។ ដើម្បីធ្វើការជំរុញឱ្យផែនការយុទ្ធសាស្ត្រអនុវិស័យអប់រំក្រៅប្រព័ន្ធបានទទួលជោគជ័យ ត្រូវបន្តអនុវត្តសកម្មភាពដូចខាងក្រោម៖

១. បន្តពង្រឹងសកម្មភាពមជ្ឈមណ្ឌលសិក្សាសហគមន៍ បណ្ណាល័យ និងមណ្ឌលអានដែលមានស្រាប់

២. បន្តពង្រឹងការអនុវត្តកម្មវិធីសមមូលបឋមសិក្សា និងមធ្យមសិក្សា
៣. អនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ
៤. បន្តអនុវត្តការងារអក្ខរកម្មតាមការជាក់ស្តែង
៥. បន្តអនុវត្តកម្មវិធីចូលរៀនឡើងវិញ។

តារាង 11៖ ស្ថិតិអ្នកមិនចេះអក្សរ

បរិយាយ	២០១៦	២០១៧
ចំនួនអ្នកមិនចេះអក្សរអាយុ១៥-២៤ឆ្នាំ	៧៥	៧៨
%អ្នកមិនចេះអក្សរអាយុ១៥-២៤ឆ្នាំ	២,៤	២,៦
ចំនួនអ្នកមិនចេះអក្សរអាយុ២៥-៤៥ឆ្នាំ	៤៣៦	៣៩១
%អ្នកមិនចេះអក្សរអាយុ២៥-៤៥ឆ្នាំ	១១,៨	១០,៦
សរុបមនុស្សអាយុ១៥-៤៥ឆ្នាំ	៦៧៥៧	៦៦៩៩
%អ្នកមិនចេះអក្សរអាយុ១៥-៤៥ឆ្នាំ	៧,៦	៧

ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ត្បែង ខែមេសា ឆ្នាំ២០១៨

គ.ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត

បើយោងទៅតាមប្រភពទិន្នន័យពីមន្ទីរផែនខេត្តឆ្នាំ ២០១៧ បានបង្ហាញឱ្យឃើញថាលទ្ធភាពក្នុងការបន្តការសិក្សារបស់សិស្សនៅក្នុងឃុំត្បែងទៅថ្នាក់ខ្ពស់ទៀតមានដូចខាងក្រោម៖

- អាយុពី១២-១៤ឆ្នាំរៀនអនុវិទ្យាល័យសរុបចំនួន ៣៤១ នាក់ ស្រីមានចំនួន ១៩៩ នាក់
- អាយុពី១៥-១៧ឆ្នាំរៀនអនុវិទ្យាល័យសរុបចំនួន ៤១៥ នាក់ ស្រីមានចំនួន ២០៩ នាក់
- អាយុពី១៥-១៧ឆ្នាំរៀនវិទ្យាល័យសរុបចំនួន ២១៧ នាក់ ស្រីមានចំនួន ៨៦ នាក់
- អាយុពី១៨-២៤ឆ្នាំរៀនវិទ្យាល័យសរុបចំនួន ៣២៣ នាក់ ស្រីមានចំនួន ១៩៣ នាក់
- អាយុពី១៨-២៤ឆ្នាំរៀនសកលវិទ្យាល័យសរុបចំនួន ១៥៤នាក់ ស្រីមានចំនួន ៦០ នាក់។
- អាយុពី២៥-៣៥ឆ្នាំរៀនសកលវិទ្យាល័យសរុបចំនួន ១២២ នាក់ ស្រីចំនួន ៦១ នាក់
- អាយុពី១៨-២៤ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ៣៩ នាក់ ស្រីចំនួន ២១ នាក់
- អាយុពី២៥-៣៥ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួន ១១០ នាក់ ក្នុងនោះស្រី៣៨នាក់

តារាង 12៖ ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត

ការអប់រំតាមក្រុមអាយុ	សរុប	ស្រី
អាយុពី១២-១៤ឆ្នាំរៀនអនុវិទ្យាល័យ	៣៤១	១៩៩
អាយុពី១៥-១៧ឆ្នាំរៀនអនុវិទ្យាល័យ	៤១៥	២០៩
អាយុពី១៥-១៧ឆ្នាំរៀនវិទ្យាល័យ	២១៧	៨៦
អាយុពី១៨-២៤ឆ្នាំរៀនវិទ្យាល័យ	៣២៣	១៩៣
អាយុពី១៨-២៤ឆ្នាំរៀនសកលវិទ្យាល័យ	១៥៤	៦០
អាយុពី២៥-៣៥ឆ្នាំរៀនសកលវិទ្យាល័យ	១២២	៦១
អាយុពី១៨-២៤ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ	៣៩	២១
អាយុពី២៥-៣៥ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ	១១០	៣៨

ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ត្បែង ខែមេសា ឆ្នាំ២០១៨

១.១.៩.ស្ថានភាពសុខាភិបាល

មណ្ឌលសុខភាព គឺជាកន្លែងផ្តល់សេវាអប់រំសុខភាព ថែទាំ និងព្យាបាលអ្នកជម្ងឺផ្សេងៗ ដែលជាកន្លែងសាធារណៈរបស់រដ្ឋ។ ឃុំត្បែង មានមណ្ឌលសុខភាព ១កន្លែង ស្ថិតនៅភូមិព្រៃប្រស់ ឃុំត្រពាំងឫស្សី នៅក្រោមការគ្រប់គ្រងរបស់ឃុំត្បែង ដែលមានបុគ្គលិកពេទ្យ ចំនួន ០៧ នាក់ ពេទ្យឆ្មប ០៣ នាក់ បន្ទប់ចំនួន ០៦ និងគ្រែចំនួន ០៣ ហើយនៅក្នុងឃុំមិនទាន់មានគ្លីនិកឯកជននោះទេ ។ ប្រភេទជម្ងឺ ដែលកាចសាហាវ ឬជម្ងឺឆ្លងដែលកើតញឹកញាប់ គឺជម្ងឺរលាកផ្លូវដង្ហើម។ ស្ថានភាពមាតានិងទារកនៅក្នុងឃុំត្បែង មានស្ត្រីដែលសម្រាលកូនដោយឆ្មបបុរាណក្នុង១ឆ្នាំកន្លងទៅចំនួន ២៤ នាក់ ស្ត្រីសម្រាលកូនដោយឆ្មបមានការបណ្តុះបណ្តាលនៅក្នុង១ឆ្នាំកន្លងទៅមានចំនួន ១៨២ នាក់ ទារកបានកើតរស់ដោយឆ្មបបុរាណចំនួន ២៤ នាក់ ទារកដែលបានកើតរស់ដោយឆ្មបពេទ្យចំនួន ១៩៣នាក់ មរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ ០-១ខែ ដោយឆ្មបបុរាណមិនមាននោះទេ មរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ០-១ខែ ដោយឆ្មបឆ្មបពេទ្យមិនមាននោះទេ មរណភាពទារកក្នុងចន្លោះអាយុ០-១ខែ ដោយឆ្មបបុរាណមិននោះទេ មរណភាពទារកក្នុងចន្លោះអាយុ០-១ខែ ដោយឆ្មបពេទ្យឆ្មបមិនមាននោះទេ ទារកដែលបានចុះសំបុត្រកំណើតមានចំនួន ១០៦នាក់ កុមារដែលមានអាយុចន្លោះពី៩-១២ខែមានចំនួន ១៤៣នាក់ កុមារដែលមានអាយុចន្លោះពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន ១៤០នាក់ ដែលការចាក់ថ្នាំបង្ការជម្ងឺផ្សេងៗនេះ ធ្វើនៅមណ្ឌលសុខភាពនិងតាមភូមិជូនប្រជាពលរដ្ឋ ដែលមានជម្ងឺមួយចំនួនមានដូចជា ជម្ងឺកញ្រ្ជិល ស្វិតដៃជើង ក្អកមាន់ របេង តេតាណូស រលាកថ្លើមប្រភេទបេ គ្រុនចាញ់ រាករូស និងគ្រុនឈាម។ ករណីមានជម្ងឺធ្ងន់ធ្ងរ ការបញ្ជូនអ្នកជម្ងឺមកមណ្ឌលសុខភាព ដោយមធ្យោបាយខ្លួនឯងផ្ទាល់ ឯការបញ្ជូនអ្នកជម្ងឺទៅមន្ទីរពេទ្យបង្អែក គឺដោយមធ្យោបាយផ្ទាល់ខ្លួនផង និងរថយន្តសង្គ្រោះរបស់មន្ទីរពេទ្យបង្អែក តែការចំណាយផ្សេងៗជាបន្ទុករបស់អ្នកជម្ងឺនិងគ្រួសារ បើសិនជាមិនមានប័ណ្ណក្រីក្រ។ សុខភាពរបស់ប្រជាពលរដ្ឋនៅក្នុងឃុំពុំទាន់បានល្អប្រសើរទេ ម្យ៉ាងវិញទៀតមណ្ឌលសុខភាពនៅមានការខ្វះខាតសម្ភារៈពេទ្យ ការងារបច្ចេកទេស ខ្វះថ្នាំព្យាបាល ជម្ងឺឆ្លងនៅតែមានបញ្ហា។ល។

តារាង 13៖ សុខភាពមាតានិងទារក

ល.រ	សុខភាពមាតានិងទារក	ឆ្នាំ២០១៧
១	ចំនួនបុគ្គលិកពេទ្យនៅមណ្ឌលសុខភាព	៧ នាក់
២	ចំនួនឆ្មបពេទ្យនៅមណ្ឌលសុខភាព	៣ នាក់
៣	ចំនួនឆ្មបបុរាណនៅមណ្ឌលសុខភាព	០
៤	ចំនួនបន្ទប់នៅមណ្ឌលសុខភាព	៦ បន្ទប់
៥	ចំនួនគ្រែនៅមណ្ឌលសុខភាព	៣ គ្រែ
៦	ចំនួនឆ្មបដែលបានបណ្តុះបណ្តាលមានក្នុងភូមិ	៨ នាក់
៧	ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបបុរាណក្នុង១ឆ្នាំកន្លងទៅ	២៤ នាក់
៨	ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបមានការបណ្តុះបណ្តាលក្នុង ១ឆ្នាំកន្លងទៅ	១៨២ នាក់
៩	ចំនួនទារកដែលបានកើតរស់ដោយឆ្មបបុរាណ	២៤ នាក់
១០	ចំនួនទារកដែលបានកើតរស់ដោយឆ្មបពេទ្យ	១៩៣ នាក់
១១	ចំនួនមរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ ០-១ខែដោយឆ្មបបុរាណ	០
១២	ចំនួនមរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ ០-១ខែដោយឆ្មបពេទ្យ	០

១៣	ចំនួនមរណភាពទារកក្នុងចន្លោះអាយុ ០-១ខែដោយឆ្មបបុរាណ	0
១៤	ចំនួនមរណភាពទារកក្នុងចន្លោះអាយុ ០-១ខែដោយឆ្មបពេទ្យ	0
១៥	ចំនួនទារកដែលបានចុះសំបុត្រកំណើត	១០៦ នាក់
១៦	ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែ	១៤៣ នាក់
១៧	ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន	១៤០ នាក់

ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ត្បែង ខែមេសា ឆ្នាំ២០១៨

រូបភាព 2៖ មណ្ឌលសុខភាពព្រៃប្រស់

បើយោងទៅតាមទិន្នន័យពីមន្ទីរផែនការខេត្តនៅឆ្នាំ ២០១៧ បានឱ្យដឹងថា ចម្ងាយពីភូមិនីមួយៗទៅកាន់មណ្ឌលសុខភាព មិនឆ្ងាយណាស់ណានោះទេ គឺឆ្ងាយបំផុតត្រឹមពី ០២-១៤គីឡូម៉ែត្រប៉ុណ្ណោះ ដូចដែលមាននៅក្នុងតារាងសង្ខេបខាងក្រោម។ ចំណែកស្ថានភាពផ្លូវទៅកាន់មណ្ឌលសុខភាព ក៏មិនពិបាកក្នុងការធ្វើដំណើរដែរ ដែលអំណោយផលដល់ការបញ្ជូនអ្នកជម្ងឺទៅកាន់មណ្ឌលសុខភាព បានទាន់ពេលវេលា ។

តារាង 14៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព

ល.រ	ឈ្មោះភូមិ	ចម្ងាយជាមធ្យម ពីភូមិទៅមណ្ឌលសុខភាព	ផ្សេងៗ
១	ត្រាច	៥ គីឡូម៉ែត	
២	តារាម	៤ គីឡូម៉ែត	
៣	ឫស្សីជះ	៣ គីឡូម៉ែត	
៤	ពោធិ៍	៦ គីឡូម៉ែត	
៥	ព្រៃប្រស់	២ គីឡូម៉ែត	
៦	បឹងអណ្តែង	៩ គីឡូម៉ែត	
៧	តាអាំ	១០ គីឡូម៉ែត	
៨	ត្បែង ក	៧ គីឡូម៉ែត	
៩	ត្បែង ខ	៨ គីឡូម៉ែត	

១០	បាគង់	៦ គីឡូម៉ែត	
១១	ត្រាំខ្លា	៨ គីឡូម៉ែត	
១២	ស្រង៉ែ	៦ គីឡូម៉ែត	
១៣	អូរអំបែង	៨ គីឡូម៉ែត	
១៤	ភ្លូង	១៣ គីឡូម៉ែត	
១៥	ឈើទាល	១៥ គីឡូម៉ែត	

ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ តៀ្បង ខែមេសា ឆ្នាំ២០១៨

ដ្យាក្រាម 2៖ ចម្ងាយជាមធ្យម ពីភូមិទៅមណ្ឌលសុខភាព



ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ តៀ្បង ខែមេសា ឆ្នាំ២០១៨

១.១.៦.ស្ថានភាពយេនឌ័រ

តាមផែនការអភិវឌ្ឍឃុំតៀ្បងរយៈពេល៥ឆ្នាំ (២០១៨-២០២២) បានឱ្យដឹងថា សមភាពការងាររបស់ស្ត្រី និងបុរស នៅក្នុងឃុំតៀ្បងនាពេលបច្ចុប្បន្ននេះ គ្មានការរើសអើង ឬគាបសង្កត់ទៅលើស្ត្រីនោះទេ។ ផ្ទុយទៅវិញ ការងារយេនឌ័រកំពុងតែមានការគាំទ្រយ៉ាងពេញទំហឹង ជាក់ស្តែងនៅក្នុងការងារមានថ្នាក់ដឹកនាំជាស្ត្រី នៅថ្នាក់ភូមិ និងថ្នាក់ឃុំកំពុងតែត្រូវបានលើកកម្ពស់ និងលើកទឹកចិត្តស្ត្រីឱ្យមានការចូលរួមយ៉ាងសកម្មនៅក្នុងការកសាងផែនការអភិវឌ្ឍឃុំ ក៏ដូចជាផែនការវិនិយោគផងដែរ។ ទោះជាយ៉ាងនេះក្តី បញ្ហាប្រឈមនៅតែកើតមានឡើងទៅលើសមត្ថភាពស្ត្រី ដោយស្ត្រីមួយចំនួនមានកម្រិតជីវភាពក្រីក្រ ខ្លះត្រូវបោះបង់ការសិក្សា ដើម្បីរកចំណូលមកទ្រទ្រង់ជីវភាពនៅក្នុងគ្រួសារ និងអ្នកខ្លះចំណាកស្រុកទៅភ្នំពេញ ដើម្បីធ្វើជាកម្មកររោងចក្រ។ ដើម្បីដោះស្រាយបញ្ហានេះ ក្រុមប្រឹក្សាឃុំ បានសហការជាមួយនឹងមន្ទីរការិយាល័យជំនាញៗ និងដៃគូអភិវឌ្ឍនានាជុំវិញ និងលើកទឹកចិត្តឱ្យមានការបណ្តុះបណ្តាលបច្ចេកទេសនានា និងជំនាញវិជ្ជាជីវៈបង្កើនមុខរបរថ្មីៗ ដើម្បីបង្កើននូវប្រាក់ចំណូល និងកាត់បន្ថយការចំណាកស្រុក។ ប៉ុន្តែបើតាមរយៈរបាយការណ៍នៃការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន នៅឃុំតៀ្បងឆ្នាំ ២០១៧ បានឱ្យដឹងអំពីតួនាទីយេនឌ័រក្នុងការចូលរួមសកម្មភាពការងារផលិតកម្មកសិកម្ម និងការងារទូទៅក្នុងជីវភាពគ្រួសាររបស់កសិករក្នុងឃុំតៀ្បង មានលម្អិតក្នុងតារាងខាងក្រោម។

តារាង 15៖ ការវិភាគលើតួនាទីយេនឌ័រ

សកម្មភាព	បុរស	ស្ត្រី	យោបល់បន្ថែម
ស្រូវវស្សា និង ប្រាំង			
ការរៀបចំដីលើកទី១	៩០%	១០%	ស្ត្រីជាប់រវល់ការងារផ្ទះច្រើន
ការរៀបចំដីលើកទី២	៨០%	២០%	ស្ត្រីជួយរើសស្មៅ
ការត្រាំពូជ	៥០%	៥០%	ការត្រាំពូជនៅផ្ទះស្រីអាចជួយបាន
ព្រួស	៩០%	១០%	ការព្រួសជាការងារមួយដែលធ្ងន់
ការដាក់ជីបំប៉ន	៩០%	១០%	ការព្រួសជីក៏ជាការងារមួយដែលធ្ងន់
គ្រប់គ្រងទឹកស្រែ	៥០%	៥០%	ស្ត្រីមើលថែទឹក
ការថ្នាំសម្លាប់ស្មៅ	៩០%	១០%	ស្ត្រីមានសុខភាពទន់ខ្សោយ ជួយដងទឹកលាយថ្នាំ
ការច្រូតកាត់	៥០%	៥០%	ស្ត្រីចូលរួមក្នុងការពិនិត្យមើលស្រូវ
ការដឹកជញ្ជូន	៥០%	៥០%	ចេះជួយគ្នា
ហាលសម្ងួត	៣០%	៧០%	ស្ត្រីនៅផ្ទះ
ទុកដាក់ស្រូវ	៥០%	៥០%	ស្ត្រីមានការងារនៅផ្ទះ
លក់ស្រូវ	១០%	៩០%	ស្ត្រីជាអ្នកទុកដាក់ថវិកា
សកម្មភាពមុខរបរចិញ្ចឹមជីវិតសំខាន់ផ្សេងទៀត			
សួនបន្លែ	៤០%	៦០%	ការថែទាំលើស្ត្រី
ចិញ្ចឹមជ្រូក	១០%	៩០%	ស្ត្រីនៅផ្ទះ
ចិញ្ចឹមគោ ក្របី	៥០%	៥០%	មានការមើលថែទាំទាំងអស់គ្នា
ចិញ្ចឹមមាន់ ទា	៥០%	៥០%	ជួយការងារគ្នា
ការប្រមូលអនុផលព្រៃឈើ	៧០%	៣០%	ប្រុសចូលកាប់ និងប្រមូល
រកត្រី	៨០%	២០%	ស្ត្រីមិនសូវបានចូលរួមដោយចុះទឹកយប់
ជំនួញទូទៅ	១០%	៩០%	ស្ត្រីពូកែលក់ដូជាងបុរស
ការថែទាំប្រព័ន្ធធារាសាស្ត្រ	៧០%	៣០%	មានគណៈកម្មការប្រើប្រាស់ទឹក
ដំណាំស្វាយចន្ទី			
ការរៀបចំដី	៧០%	៣០%	បុរសអ្នកភ្ជួរ ស្ត្រីដាំបាយនិងជួយរៀបចំឧបករណ៍ភ្ជួរ
ភ្ជួរ	៧០%	៣០%	ស្ត្រីជួយរៀបចំបាយទឹកនៅផ្ទះ
រាស់	៧០%	៣០%	ស្ត្រីជួយសម្អាតស្មៅ
ឆ្វួតរង	៩០%	១០%	ប្រើប្រាស់គ្រឿងយន្ត
ដាក់ជី	៥០%	៥០%	ធ្វើរួមគ្នា
ផ្ដុំរង លើករង	៩០%	១០%	ធ្វើរួមគ្នានិងប្រើគ្រឿងចក្រ
ដាំគ្រាប់/កូន	៥០%	៥០%	ការងារធ្វើរួមគ្នា
បាញ់ថ្នាំ	៧០%	៣០%	ជួយធ្វើគ្នា
ថែទាំ	៥០%	៥០%	រួមគ្នាធ្វើ
ប្រមូលផល	៥០%	៥០%	ជួយបេះផ្លែទាំងអស់គ្នា
លក់ដោយម៉ៅ	៣០%	៧០%	ស្ត្រីរកឈ្មួញនិងចូលរួមសម្រេចចិត្ត

ប្រភព៖ *របាយការណ៍ក្បេត្រ-បរិស្ថានឃុំត្បែងឆ្នាំ២០២០*

បើយោងទៅតាមរបាយការណ៍ស្ដីពីការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំត្បែង ឆ្នាំ២០១៧ បានរកឃើញពីការវិភាគតួនាទីយេនឌ័រក្នុងឃុំត្បែងដូចខាងក្រោមៈ

១.ស្រ្តីភាគច្រើនជាអ្នកផលិតកម្មកសិកម្ម

២.បុរសទៅរកចំណូលនៅឆ្ងាយៗផ្ទះ

៣.ស្រ្តីមើលថែការងារនៅផ្ទះជាប្រចាំ

៤.សកម្មភាពការងារមានការចូលរួមធ្វើទាំងអស់គ្នា

៥.ការងារធ្ងន់ៗជាបន្ទុករបស់បុរស

យោងតាមប្រភពព័ត៌មាន ដែលទទួលបាន ដូចមាន រៀបរាប់ខាងលើពាក់ព័ន្ធការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិអំណាចស្រ្តីនៅក្នុងឃុំត្បែង យើងសង្កេតឃើញថា បុរស និងស្រ្តីមិនមានការរើសអើងគ្នាធ្ងន់ធ្ងរនោះទេ គឺមានភាពលំអៀងតិចតួចប៉ុណ្ណោះ ដូចជា ការងារធ្វើស្រែឃើញថា បុរសមានការចូលរួមច្រើនជាងស្រ្តីជាពិសេស ការងាររៀបចំដីស្រែឃើញថាការងារនេះបុរសទទួលរ៉ាប់រងស្ទើរតែទាំងស្រុង ដែលស្រ្តីមានកម្លាំងទន់ខ្សោយជាង ជាអ្នកចម្អិនអាហារនៅផ្ទះ ហើយក៏ឃើញថា ការងារដឹកជញ្ជូនគ្រាប់ស្រូវ បាញ់ថ្នាំសម្លាប់សត្វល្អិត ដាក់ជី ច្រូតកាត់ និងការងារទុកដាក់ស្រូវជាដើម គឺបុរសបានចូលរួមច្រើនជាងស្រ្តី ប៉ុន្តែការងារក្នុងផ្ទះនិងនៅជិតផ្ទះឃើញស្រ្តីបានចូលរួមច្រើនជាងបុរសវិញ តែក្នុងនោះក៏បានរកឃើញថា ការសម្រេចចិត្តក្នុងគ្រួសារបុរសនៅមានសិទ្ធិច្រើនជាងស្រ្តី និងមានស្រ្តីមួយចំនួននៅទទួលរងអំពើហិង្សានៅក្នុងគ្រួសារនៅឡើយ។ ប៉ុន្តែទោះបីមានបញ្ហាប្រឈមខ្លះក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិអំណាចស្រ្តីក៏ដោយ ក៏យើងឃើញកិច្ចការនេះមានវឌ្ឍនភាព គួរឱ្យកត់សម្គាល់ ដែលទៅថ្ងៃអនាគតនឹងឈានទៅកាន់តែប្រសើរឡើង ។

១.២.ស្ថានភាពភូមិសាស្ត្រ

១.២.១.ទីតាំងភូមិសាស្ត្រ

ឃុំត្បែង ជាឃុំមួយ ដែលស្ថិតនៅក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ មានទីតាំងផ្អែកលើនិយាមកាផែនទី (អាប់ស៊ីស) ៤៧៧ ៣៨០,២៩ និង(អ័រដោនេ) ១ ៤១៤ ២១១,៤៩។ សណ្ឋានដីនៅក្នុងឃុំត្បែង បើផ្អែកតាមរបាយការណ៍ស្ដីពីការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំ បានឱ្យដឹងថា ជាដីមិនរាបស្មើមានទាបមានខ្ពស់ ដោយបានចែកចេញជា ០៤តំបន់គឺ

តំបន់ I៖ នៅភាគខាងជើងឆៀងខាងកើតឃុំ ជាតំបន់ទំនាបខ្ពស់ មានប្រភេទដីខ្សាច់សុទ្ធពណ៌ស ត្រូវបានប្រើប្រាស់ សម្រាប់ចម្ការស្វាយចន្ទី កៅស៊ូ និងស្វាយកែវល្មៀត ស្រូវស្រាល និងតំបន់ព្រៃល្បោះ។

តំបន់ II៖ នៅផ្នែកកណ្ដាលនៃឃុំ ជាតំបន់ទំនាបមធ្យម ដែលមានប្រភេទដីខ្សាច់លាយពណ៌ប្រផេះ និងត្រូវបានប្រើប្រាស់សម្រាប់ តំបន់លំនៅឋាន ឈើហូបផ្លែ បន្លែ ដំណាំរួមផ្សំ និងសត្វចិញ្ចឹម។

តំបន់ III៖ នៅផ្នែកខាងជើងឆៀងខាងលិចឃុំ ជាតំបន់ទំនាបទាបមានប្រភេទដីខ្សាច់លាយឥដ្ឋពណ៌ប្រផេះ ត្រូវបានប្រើប្រាស់សម្រាប់តំបន់ស្រែប្រាំង និងតំបន់ស្រែវស្សា។

តំបន់ IV៖ នៅភាគខាងត្បូងឃុំ ជាតំបន់ទំនាបលិចទឹកទន្លេសាប និងបឹងព្រៃប្រស់ មានប្រភេទដីកណ្ដោងដីពពាយកណ្ដុរ ដីឥដ្ឋពណ៌ប្រផេះខ្លាញ់ក្ដាម ត្រូវបានប្រើប្រាស់សម្រាប់តំបន់ស្រូវឡើងទឹក និងស្រូវប្រដេញទឹក។

ផែនទី 3៖ ផែនទីរយៈកម្ពស់ដីឃុំត្បែង



ផែនទី 4៖ ប្រព័ន្ធកេ្សត្រ-បរិស្ថាន ឃុំត្បែង



តារាង 16៖ ដ្យាក្រាមពំនុះកាត់ទទឹង ឃុំត្បែង ស្រុកកំពង់ស្វាយ

តំបន់ / បរិយាយ	តំបន់កស្សេត្រ-បរិស្ថាន I	តំបន់កស្សេត្រ-បរិស្ថាន II	តំបន់កស្សេត្រ-បរិស្ថាន III	តំបន់កស្សេត្រ-បរិស្ថាន IV
រូបថតតំណាងតំបន់កស្សេត្រ-បរិស្ថាន				
ឈ្មោះតំបន់	**តំបន់ទំនាបខ្ពស់** ដំណាំស្វាយចន្ទី និងកៅស៊ូ	**តំបន់ទំនាបមធ្យម** លំនៅឋាន ឈើហូបផ្លែ បន្លែ ដំណាំរួមផ្សំ និងចិញ្ចឹមសត្វ	**តំបន់ទំនាបទាប** ស្រូវវស្សា និងស្រូវប្រាំង	**តំបន់ទំនាបលិចទឹកទន្លេសាប និងបឹងព្រៃប្រស់** ស្រូវឡើងទឹក និងស្រូវប្រដេញទឹក
រៀបរាប់ដោយសង្ខេប	-ទំនាបខ្ពស់ជម្រាលពីជើងទៅត្បូង មិនលិចទឹក ពីមុនជាតំបន់ព្រៃឈើ មកជាតំបន់ចម្ការស្វាយចន្ទី និងកៅស៊ូ -ការស្រោចស្រពទឹកភ្លៀង និងមានត្រពាំងតូចៗមួយចំនួន	-ជម្រាលស្មើររាបស្មើ -លំនៅឋានតាមបណ្ដោយ ផ្លូវជាតិ -ការដាំដុះឈើហូបផ្លែចម្រុះ បន្លែ និងមានការចិញ្ចឹមសត្វ -មានទឹកភ្លៀងសម្រាប់ប្រើប្រាស់ និងស្រោចស្រព -មានស្រះ និងអណ្ដូងទឹក	-ជម្រាលរាបស្មើ -មានប្រឡាយ (សម្ដេច ហ៊ុនសែន) ១ខ្សែសម្រាប់ស្រោចស្រព -មានប្រឡាយជើងក្អែប និងប្រឡាយរងបញ្ចូលស្រែតិច -ស្រោចស្រពទឹកភ្លៀង ស្ទឹងព្រៃប្រស់ -ស្រែភាគច្រើនមានភ្លឺល្អ	-ជម្រាលរាបស្មើ -តំបន់ស្រូវប្រាំង និងស្រូវឡើងទឹក -ផ្ទៃដីស្រែលិចទឹករៀងរាល់ឆ្នាំ -មានបឹងព្រៃប្រស់ សម្រាប់ ការធ្វើនេសាទ -មានវាលស្មៅសម្រាប់គោក្របីនៅរដូវប្រាំង
ឋានលេខា	-ជម្រាលមិនរាបស្មើមានរយៈកម្ពស់ខ្ពស់ជាងតំបន់ II	-ជម្រាលរាបស្មើមានរយៈកម្ពស់ទាបតំបន់ I	-ជម្រាលរាបស្មើមានទឹកហូរទៅទន្លេសាប	-ជម្រាលរាបស្មើមានរយៈកម្ពស់ទាបជាងគេទឹកហូរទៅទន្លេសាប
ប្រភេទដី	-ខ្សាច់សុទ្ធពណ៌ស	-ខ្សាច់លាយពណ៌ប្រផេះ	-ខ្សាច់លាយឥដ្ឋពណ៌ប្រផេះ	-ដីកណ្ដៀង ដីពពាយកណ្ដុរ -ឥដ្ឋពណ៌ប្រផេះខ្ចាញ់ក្អាម
ជលសាស្ត្រ	-ជំនន់ទឹកភ្លៀង រយៈពេលខ្លី ១អាទិត្យ	-ជំនន់ទឹកភ្លៀង រយៈពេលខ្លី ១អាទិត្យ	-ទឹកភ្លៀង បឹង ត្រពាំង -ទឹកជំនន់ទន្លេសាបរយៈពេល ១៥ថ្ងៃ	-ទឹកបឹងព្រៃប្រស់ -ទឹកភ្លៀង បឹង ត្រពាំង

		-ស្រះ អណ្តូង	-ប្រឡាយ សម្តេច ហ៊ុន សែន	-ជំនន់ទន្លេសាបរយៈពេលវែង (លើសពី៦ខែ)
ធនធានទឹក	-ទឹកភ្លៀង	-អូរ -ស្រះសហគមន៍	-ប្រឡាយ សម្តេច ហ៊ុន សែន (ប្រឡាយមេ) -ប្រឡាយរង ប្រឡាយជើងក្អែប	-បឹងព្រៃប្រស់ -បឹងធម្មជាតិ
គម្របដី/ការប្រើប្រាស់ដី	-ចម្ការស្វាយចន្ទី -ចម្ការកៅស៊ូ -ព្រៃល្បោះ	-លំនៅឋាន -ដំណាំឈើហូបផ្លែ -ផ្ទៃដីស្រូវស្រាល -ការចិញ្ចឹមសត្វ -ហេដ្ឋារចនាសម្ព័ន្ធភូមិ ឃុំ	-ផ្ទៃដីស្រូវប្រាំង -ផ្ទៃដីស្រូវវស្សា -ប្រឡាយទឹក -វាលស្មៅ	-បឹងព្រៃប្រស់ -ស្រូវប្រាំង/ប្រដេញទឹក -ស្រូវឡើងទឹក (ស្រូវវា) -ដំណាំបន្លែ -វាលស្មៅ
ដំណាំសំខាន់ៗ	-ស្វាយចន្ទី -ស្វាយកែវល្មៀត -កៅស៊ូ -ស្រូវស្រាល	-ដូង ស្វាយ ខ្នុរ ចេក ទៀប ត្នោត -បន្លែ	-ស្រូវស្រាលពូជនាងគង់ -ពូជផ្ការំដួល ពូជរាំងជ័យ -ពូជការមួន ពូជសែនក្រអូប -ពូជស្រូវប្រាំង ពូជ ៥៤៥១	-ស្រូវប្រាំង ពូជស្រូវពពាយ -ពូជ ៥៤៥១ ពូជបាំងកក -ពូជ ៥០៤ -ស្រូវវស្សាឡើងទឹក
ពូជស្រូវ	-ស្រូវស្រាល	-រំដួល -៥៤៥១ -ស្រូវស្រាល	-ស្រូវវស្សាពូជនាងគង់ -ពូជផ្ការំដួល ពូជរាំងជ័យ -ស្រូវប្រាំង ៥៤៥១ -ការមួន សែនក្រអូប	-ពូជស្រូវពពាយ -ពូជ ៥៤៥១ ពូជបាំងកក -ពូជ ៥០៤ -ពូជឡើងទឹក
ការប្រើប្រាស់ជី	-លាមកសត្វ -ផេះអង្កាម -ជីអសរីរាង្គ ៦បេ/ហិកតា -ជីធម្មជាតិ ៦បេ/ហិកតា -N-P-K ៤បេ/ហិកតា	-ធម្មជាតិជប៉ុន ២បេ/ហិកតា -DAP ២បេ/ហិកតា -Urea ៣បេ/ហិកតា -N-P-K ៧បេ/ហិកតា	-ធម្មជាតិជប៉ុន ២បេ/ហិកតា -DAP ២បេ/ហិកតា -Urea ៣បេ/ហិកតា -N-P-K ២បេ/ហិកតា	-ធម្មជាតិជប៉ុន ២បេ/ហិកតា -DAP ២បេ/ហិកតា -Urea ៣បេ/ហិកតា -N-P-K ២បេ/ហិកតា
ការចិញ្ចឹមសត្វ	-គោ ក្របី	-គោ ក្របី មាន់ ទា ជ្រូក	-គោ ក្របី	-គោ ក្របី

ដីរបស់រដ្ឋ ដីសហគមន៍	-អូរធម្មជាតិ -ត្រពាំង -ព្រៃល្បោះ	-សាលារៀន -សាលាឃុំ -មណ្ឌលសុខភាព វត្ត -សាលាដំណាក់ ទួលច័ន្ទព្រំ -ស្រះសហគមន៍	-ប្រឡាយ -ត្រពាំង -បឹង -អូរ	-បឹងព្រៃប្រស់ -ប្រឡាយ -បឹង អូរ -សហគមន៍នេសាទ
បញ្ហាផ្សេងៗ	-គ្រោះរាំងស្ងួត -ខ្វះប្រព័ន្ធស្រោចស្រព -សត្វល្អិតបំផ្លាញដំណាំ -ខ្វះបច្ចេកទេសកសិកម្ម -ខ្វះកម្លាំងពលកម្ម -ផ្លូវពិបាកដឹកជញ្ជូន	-ផ្លូវតាមភូមិខូចច្រើនពិបាក ដឹកផលិតផល -ខ្វះស្រះ ប្រឡាយ -សត្វ មានជម្ងឺ -តម្លៃស្រូវថោក -មនុស្សកើតជម្ងឺ -គ្រោះរាំងស្ងួត -ខ្វះគណៈកម្មការប្រើប្រាស់ទឹក -ធាតុចូលកសិកម្មថ្លៃ -ខ្វះបច្ចេកទេសប្រើប្រាស់ដី និងថ្នាំពុលកសិកម្ម	-ខ្វះបច្ចេកទេសកសិកម្ម -ខ្វះប្រព័ន្ធប្រឡាយ -តម្លៃស្រូវទាប -ខ្វះប្រឡាយជើងក្អែប -ទឹកជំនន់ -សត្វល្អិតបំផ្លាញដំណាំស្រូវ -ខ្វះទ្វារបិទបើកទឹកតាមប្រឡាយធំៗ -ទំនាស់ការប្រើប្រាស់ទឹក	-ខ្វះស្ថានីយបូមទឹក -ខ្វះប្រឡាយមេ -ការរំលោភដីចំណីបឹង -ខ្វះបច្ចេកទេសកសិកម្ម -សត្វល្អិតបំផ្លាញដំណាំ -បទល្មើសនេសាទ -ទំនាស់ការប្រើប្រាស់ទឹក -បម្រែបម្រួលអាកាសធាតុ -បូមទឹកចាប់ត្រី
កាឡានុវត្តភាព/ ឱកាស	-ពង្រីកដីដាំស្វាយចន្ទី និងដំណាំកៅស៊ូ -រក្សាវាលស្មៅ -សាងសង់ប្រព័ន្ធប្រឡាយ -ចិញ្ចឹមសត្វ	-ដាំដុះបន្លែ -អាចសាងសង់ប្រព័ន្ធប្រឡាយ -បង្កើតសហគមន៍និងលក់ស្រូវ តាមកិចសន្យា -ជីកស្រះចិញ្ចឹមត្រី -ដាំដុះឈើហូបផ្លែ -ពង្រីកការចិញ្ចឹមសត្វ -ជួសជុលផ្លូវលំក្នុងភូមិ -បណ្តុះបណ្តាលបច្ចេកទេស កសិកម្ម -បន្ថែមគណៈកម្មការប្រើប្រាស់ទឹក	-សាងសង់ប្រឡាយរងបន្ថែម -ធ្វើទ្វារបិទបើកទឹកប្រឡាយ -កែលម្អគុណភាពដីស្រែ -បង្កើនការធ្វើស្រែ២ទៅ៣ដងក្នុង១ឆ្នាំ -ដាំដំណាំបន្លែ -ឃ្វាលគោ ក្របី រដូវប្រាំង -ជីកស្រះចិញ្ចឹមត្រី -ស្តារ ត្រពាំងបឹង	-ដាំព្រៃលិចទឹកឡើងវិញ -បង្កើតស្ថានីយបូមទឹក -ធ្វើប្រដេញទឹក និងស្រូវប្រាំង -នេសាទត្រី -ដាំបន្លែតាមមាត់បឹង -ធ្វើប្រព័ន្ធប្រឡាយ -ពង្រឹងសហគមន៍នេសាទ -រក្សាវាលស្មៅសម្រាប់ គោក្របី -ឃ្វាល គោក្របីរដូវប្រាំង

យោងទៅតាមរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថានបានបង្ហាញឱ្យឃើញថា ឃុំមានប្រភពទឹក ដូចជា ១)ទឹកភ្លៀង ២)អូរ ៣)ស្ទឹងព្រៃប្រស់ និង៤)បឹងធម្មជាតិ ព្រមទាំងមានប្រឡាយ ២៤ ខ្សែ សម្រាប់នាំទឹកពីប្រភពទឹកខាងលើ ក្នុងនោះមានប្រឡាយមេ ២ ខ្សែ ប្រវែង ១៣ ៧៦៨,៣៨ ម៉ែត្រ ដែលខ្សែទី១ពីប្រឡាយមេ ៣០ កញ្ញា ទៅទិសខាងកើត ក្រោយភូមិឬស្សីជះ និងនៅចន្លោះភូមិពោធិ៍ ចំណែកខ្សែទី២ ចាប់ពីភូមិតារាម ទៅទល់នឹងផ្លូវជាតិលេខ៦(ស្នាមប្រឡាយឬផ្លូវចាស់ទ្រុឌទ្រោម)។ ប្រឡាយរង ៣ខ្សែ ប្រវែង ៣៣៣៩,៦៨ម៉ែត្រ ក្នុងនោះខ្សែទី១ ចាប់ពីក្រោយវិទ្យាល័យត្បែង ទៅទល់នឹងប្រឡាយទី១។ ខ្សែទី២ ចាប់ពីក្រោយភូមិបាគង់ ទៅទល់នឹងប្រឡាយទី១ ចំណែកប្រឡាយរងទី៣ ចាប់ពីប្រឡាយមេ ៣០កញ្ញា ឆ្ពោះទៅទិសខាងកើតរហូតដល់ព្រំប្រទល់ឃុំត្បែង និងប្រឡាយតូច ១៩ខ្សែ ប្រវែង ២៤ ២៤៦,៥៧ ម៉ែត្រ និងទ្វារស្នាក់ទឹកចំនួន ១៨ កន្លែង ចំណែកទឹកក្រោមដីនៅក្នុងឃុំត្បែង មានការប្រើប្រាស់តាមរយៈអណ្តូងស្នប់ សម្រាប់ស្រោចស្រព និងប្រើប្រាស់ទូទៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋតែប៉ុណ្ណោះ។ ប្រភពទឹកដែលនាំទឹកមកប្រើប្រាស់នៅក្នុងឃុំមានតែបឹងព្រៃប្រស់ និងបឹងធម្មជាតិ តាមរយៈប្រឡាយរង ដែលឃុំបានជីក និងស្តារសម្រាប់នាំយកទឹកមកស្រោចស្រព ក្នុងភូមិសាស្រ្តស្រែវស្សា និងស្រែប្រាំង ក្រៅពីបឹងព្រៃប្រស់ និងបឹងធម្មជាតិឃុំមានតែបឹង និងស្រះទឹកដែលជាប្រភពទឹកបន្ទាប់បន្សំតែប៉ុណ្ណោះ។

តារាង 17៖ ប្រព័ន្ធធារាសាស្ត្រ

ល.រ	ប្រភេទប្រឡាយ	ចំនួនប្រឡាយ	ប្រវែង(ម៉ែត្រ)
១	ប្រឡាយមេ	២	១៣៧៦៨,៣៨
២	ប្រឡាយរង	៣	៣៣៣៩,៦៨
៣	ប្រឡាយតូច	១៩	២៤២៤៦,៥៧
ប្រវែងប្រឡាយសរុប		**២៤**	**៤១៣៥៤,៦៤**

រូបភាព 3៖ ប្រព័ន្ធធារាសាស្ត្រ

ផែនទី 5៖ ប្រព័ន្ធធារាសាស្ត្រឃុំត្បែង



១.២.២.អាកាសធាតុ (ពិពណ៌នាតាមរដូវកាល)

នៅក្នុងឃុំត្បែង ក៏ដូចជានៅទូទាំងខេត្ត គឺទទួលរបបខ្យល់ពីតំបន់ត្រូពិច ដែលមានអាកាសធាតុក្តៅហើយសើម។ របបខ្យល់មូសុង បានពាំនាំមកនូវចំនួនទឹកភ្លៀងយ៉ាងច្រើនមកជាមួយ ដែលអំណោយផលទៅដល់ការធ្វើកសិកម្មនានា និងដាំដំណាំផ្សេងៗ។

បើយោងទៅតាមប្រភពទិន្នន័យពីមន្ទីរធនធានទឹក និងឧតុនិយមក្នុងខេត្តកំពង់ធំ ប្រចាំស្រុកកំពង់ស្វាយ នៅក្នុងឆ្នាំ ២០១៧ បង្ហាញថា នៅស្រុកកំពង់ស្វាយ មានភ្លៀងធ្លាក់ចំនួន ៩១ ដង ដែលមានបរិមាណទឹកភ្លៀងប្រចាំឆ្នាំចំនួន ១ ៣៦៥,៨ ម.ម។

អំពីសីតុណ្ហភាព៖

- រដូវរងារ៖ ខែ វិច្ឆិកា ដល់ ខែ មីនា (២០ ទៅ ២៨ អង្សា)
- រដូវក្តៅ៖ ខែ មីនា ដល់ ខែ ឧសភា (៣០ ទៅ ៣៥ អង្សា)
- រដូវភ្លៀង៖ ខែ ឧសភា ដល់ ខែ តុលា (២៣ ទៅ ៣០ អង្សា ជាមួយនឹងការឡើងសំណើមទៅដល់ ៩០ ភាគរយ) នៅរដូវនេះជារៀងរាល់ឆ្នាំ គឺមានភ្លៀងធ្លាក់ខ្លាំង នៅពេលរសៀល និងល្ងាច។

តារាង 18៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ

ខែ	មករា	កុម្ភៈ	មីនា	មេសា	ឧសភា	មិថុនា	កក្កដា	សីហា	កញ្ញា	តុលា	វិច្ឆិកា	ធ្នូ
បរិមាណទឹកភ្លៀង	១,៥	០	៧៣,៨	៧៥,៦	២១២,៥	៨៧,៣	២៥៦,៧	១៧៣,៥	៩៣,៥	២៦៣,៧	៩៦,៩	៣០,៨
ចំនួនថ្ងៃមានភ្លៀង	១	០	៣	៥	១៥	៩	១៧	១១	១០	៩	៨	៣

ប្រភព៖ *មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ធំ ឆ្នាំ២០១៧*

ដ្យាក្រាម 3៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ



ប្រភព៖ *មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ធំ ឆ្នាំ២០១៧*

១.២.៣.ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន

ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍រួមមាន ផ្លូវ គោក ផ្លូវដែក ផ្លូវទឹក និងផ្លូវអាកាស។ បច្ចុប្បន្នឃុំត្បែង មានតែប្រព័ន្ធគមនាគមន៍ផ្លូវគោកប៉ុណ្ណោះ ហើយបានដើរតួយ៉ាងសំខាន់នៅក្នុងការសម្រួលដល់ការដឹកជញ្ជូន និងការធ្វើដំណើររបស់ប្រជាពលរដ្ឋក្នុងឃុំ ដែលនៅក្នុងនោះមានផ្លូវជាតិលេខ ៦ ឆ្លងកាត់ ប្រវែង ៧០១២ ម៉ែត្រ ដែលមានទិសដៅពីភ្នំពេញ ទៅកាន់ខេត្តសៀមរាប ដែលកាត់ឃុំត្បែងត្រង់ស្ពានព្រៃប្រស់ ឆ្ពោះទៅកាន់សាលាឃុំសាន់គ ដែលជាច្រកចេញ-ចូលសំខាន់សម្រាប់ឃុំត្បែង ក្នុងការទទួលផលប្រយោជន៍ពីការអភិវឌ្ឍតាមផ្លូវនេះ ហើយឃុំនៅមានផ្លូវគ្រួសក្រហម១ខ្សែទៀត ក៏ដើរតួយ៉ាងសំខាន់សម្រាប់ឃុំត្បែងផងដែរ ដែលចេញពីផ្លូវជាតិលេខ៦ ឆ្ពោះទៅកាន់ឃុំនីពេជ្រ ឆ្លងកាត់ភូមិត្រាច ភូមិស្រង៉ែ ភូមិអូរអំបែង និងភូមិឈើទាល។

ឃុំត្បែង មានផ្លូវចំនួន ១២១ ខ្សែ ដែលមានប្រវែង ១៧៤ ២១៤,៨៤ ម៉ែត្រ នៅក្នុងនោះផ្លូវចាក់កៅស៊ូ ១ ខ្សែ ប្រវែង ៧ ០១២ ម៉ែត្រ ផ្លូវក្រាលគ្រួសក្រហម ២១ ខ្សែ ប្រវែង ៤៨ ៣៩៨,២៦ ម៉ែត្រ ផ្លូវលំដីស ឬផ្លូវរទេះ ៩៩ ខ្សែ ប្រវែង ១១៨ ៨០៤,៥៨ ម៉ែត្រ ។ នៅក្នុងឃុំ មានការរីកចម្រើនផ្នែកប្រព័ន្ធដឹកជញ្ជូន គួរឱ្យកត់សម្គាល់ ប៉ុន្តែផ្លូវមួយចំនួនត្រូវបានខូចខាតទៅវិញជាបណ្តើរៗ ដោយសារការដឹកជញ្ជូនលើសទម្ងន់ ខូចខាតដោយគ្រោះធម្មជាតិ និងសកម្មភាពរបស់មនុស្សប្រចាំថ្ងៃ។

តារាង 19៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន

ល.រ	ប្រភេទផ្លូវ	ចំនួនខ្សែផ្លូវ	ប្រវែង (ម៉ែត្រ)
១	ផ្លូវចាក់កៅស៊ូ	១	៧០១២
២	ផ្លូវគ្រួសក្រហម ឬក្រាលថ្ម	២១	៤៨៣៩៨,២៦
៣	ផ្លូវដីស	៩៩	១១៨៨០៤,៥៨
សរុប		១២១	១៧៤២១៤,៨៤

រូបភាព 4៖ ប្រព័ន្ធគមនាគមន៍

ផ្លូវកៅស៊ូនៅក្នុងឃុំត្បែង	ផ្លូវគ្រួសក្រហមនៅក្នុងឃុំត្បែង	ផ្លូវលំដីសនៅក្នុងឃុំត្បែង

ផែនទី 6៖ ផែនទីហេដ្ឋារចនាសម្ព័នឃុំត្បែង



១.២.៨.បរិក្ខាសាធារណៈ

ក.ស្ថានភាពប្រើប្រាស់អគ្គិសនី

បេសកកម្មរបស់មន្ទីររ៉ែ និងថាមពលខេត្តកំពង់ធំ គឺដឹកនាំជំរុញការគ្រប់គ្រង និងសមាហរណកម្មលើវិស័យរ៉ែ និងថាមពលរួមទាំងប្រេងកាត ឧស្ម័ន និងអគ្គិសនី នៅក្នុងសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ចសង្គម នៅមូលដ្ឋាន និងក្នុងខេត្តកំពង់ធំ ក្នុងនាមជាសេនាធិការឱ្យក្រសួងរ៉ែ និងថាមពល ។

នៅក្នុងឃុំ មានប្រជាពលរដ្ឋប្រើប្រាស់បណ្តាញអគ្គិសនីចំនួន ៤៣០ ខ្នងផ្ទះ ស្មើនឹង ១៦,៤ ភាគរយ អាគុយចំនួន ១ ៤៣២ ខ្នងផ្ទះ ស្មើនឹង ៥៤,៧ ភាគរយ បន្ទះសូឡាចំនួន ៣៦៥ ខ្នងផ្ទះ ស្មើនឹង ១៣,៩ ភាគរយ ជីវឧស្ម័នមានចំនួន ២ ខ្នងផ្ទះ ស្មើនឹង ០,១ ភាគរយ។ យោងទៅតាមទិន្នន័យខាងក្រោម បានបង្ហាញថា ប្រជាពលរដ្ឋប្រើប្រាស់អាគុយមានចំនួនច្រើនជាងគេ និងប្រើប្រាស់ឡជីវឧស្ម័នមានចំនួនតិចជាងគេ ។

តារាង 20៖ ស្ថិតិអ្នកប្រើប្រាស់អគ្គិសនី

បរិយាយ	២០១៦ភាគរយ	២០១៧	
		ភាគរយ	ចំនួនផ្ទះ
ផ្ទះបំភ្លឺដោយបណ្តាញអគ្គិសនី	១៤,៣	១៦,៤	៤៣០
ផ្ទះបំភ្លឺដោយអាគុយ	៥៨,៧	៥៤,៧	១៤៣២
ផ្ទះបំភ្លឺដោយបន្ទះសូឡា	១២,៦	១៣,៩	៣៦៥
ផ្ទះបំភ្លឺដោយឡជីវឧស្ម័ន	០,៥	០,១	២

ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ត្បែង ខែមេសា ឆ្នាំ២០១៨

ខ.ប្រព័ន្ធទឹកស្អាត

អាជ្ញាធរខេត្តកំពង់ធំ បានធ្វើការអំពាវនាវឱ្យប្រជាពលរដ្ឋ ដែលធ្លាប់តែប្រើប្រាស់ទឹក ស្ទឹង បឹង ត្រពាំង ឬអណ្តូង ងាកមកបរិភោគទឹកស្អាតវិញ ដើម្បីជួយលើកកម្ពស់សុខភាព និងលើកស្ទួយអនាម័យនៅតាមជនបទ។ នៅក្នុងឃុំត្បែង ប្រជាពលរដ្ឋប្រើប្រាស់ទឹកស្អាតមានចំនួន ២ ៤១២ គ្រួសារ ស្មើនឹង ៨៤,៤ ភាគរយ ក្នុងនោះ ទឹកដែលឆ្លងកាត់ប្រព័ន្ធធ្វើទឹកឱ្យស្អាតមានចំនួន ២៦ គ្រួសារ ទឹកអណ្តូងស្នប់ ឬអណ្តូងចម្រុះមានចំនួន ១ ០៥១ គ្រួសារទឹកអណ្តូងជីកមានការការពារមានចំនួន ១ ៣៨៤ គ្រួសារ ចំណែកទឹកអណ្តូងជីកមិនមានការការពារ មានចំនួន៤០៦ គ្រួសារ និងទឹកពីប្រភពផ្សេងៗដូចជា៖ ទឹកស្ទឹង អូរ ត្រពាំង មានចំនួន ៤២ គ្រួសារ។

តារាង 21៖ ស្ថិតិអ្នកប្រើប្រាស់ការប្រើប្រាស់ទឹក

បរិយាយ		២០១៦	២០១៧
សរុបគ្រួសារមានទឹកស្អាតប្រើប្រាស់		**២៣៦០**	**២៤១២**
ក្នុងនោះ	ទឹកដែលឆ្លងកាត់ប្រព័ន្ធធ្វើទឹកឱ្យស្អាត	២៦	២៦
	ទឹកអណ្តូងស្នប់ឬអណ្តូងចម្រុះ	៩២៥	១០៥១
	ទឹកអណ្តូងជីកមានការការពារ	១៤០៩	១៣៨៤
	ទឹកភ្លៀងដែលមានការការពារ	០	០
%គ្រួសារមានទឹកស្អាតប្រើប្រាស់		**៨៣,២**	**៨៤,៤**

ទឹកអណ្តូងជីកមិនមានការការពារ	៤៥១	៤០៦
%គ្រួសារប្រើប្រាស់ទឹកអណ្តូងជីកមិនមានការការពារ	១៥,៩	១៤,១
ទឹកស្រះ	0	១
%គ្រួសារប្រើប្រាស់ទឹកស្រះ	0.0	0.0
ទឹកពីប្រភពផ្សេងៗ(ទន្លេ ស្ទឹង អូរ ជ្រោះ)	២៤	៤២
%គ្រួសារប្រើប្រាស់ទឹកពីប្រភពផ្សេងៗ(ទន្លេ ស្ទឹង អូរ ជ្រោះ)	០,៨	១,៥

ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ត្បែង ខែមេសា ឆ្នាំ២០១៨

១.៣.ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

១.៣.១.ស្ថានភាពការកាន់កាប់ និងគ្រប់គ្រង

ផែនទី 7៖ ផែនទីប្រើប្រាស់ដីសាមញ្ញក្នុងឃុំត្បែង



ផែនទី ៩៖ ផែនទីប្រើប្រាស់ដីលម្អិតក្នុងឃុំត្បែង



តារាង 22៖ តារាងរាយលម្អិតតាមប្រភេទនៃការប្រើប្រាស់ដីបច្ចុប្បន្ន

ប្រភេទដីប្រើប្រាស់ (ឈ្មោះហៅតាមបច្ចេកទេស)	បរិយាយ (ឈ្មោះហៅតាមអ្នកស្រុក)	ទំហំ (ហិតា)	ទំហំ(%)
ក.ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ		**៣៨៤,៧៦**	**២,៧២**
- ដីលំនៅឋានភូមិក្រៅតំបន់ការពារ	ដីភូមិ	១៨៨,០៨	១,៣៣
- ដីលំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប	ដីភូមិ	១៩៥,៩២	១,៣៩
- ដីលំនៅឋានភូមិក្នុងគម្របព្រៃឈើឆ្នាំ២០០២	ដីភូមិ	០,៧៦	០,០១
ខ.ដីកសិកម្ម		**១២៩២៣,៦៦**	**៩១,៤០**
ខ.១.ដីស្រែវស្សា	**ស្រែវស្សា**	**៨២៥៦,៥០**	**៥៨,៣៩**
- ដីស្រែវស្សាក្រៅតំបន់ការពារ	ស្រែវស្សា	៦៦៩៧,៦៧	៤៧,៣៧
- ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប	ស្រែវស្សា	១១១៣	៧,៨៧
- ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ២០០២	ស្រែវស្សា	៤៤៥,៨៣	៣,១៥
ខ.២.ដីស្រែប្រាំងនិងស្រែវស្សា	**ស្រែប្រាំង**	**២២៧៦,០៣**	**១៦,១០**
- ដីស្រែប្រាំងនិង ស្រែវស្សាក្នុងតំបន់១ ជុំវិញបឹងទន្លេសាប	ដីស្រែប្រាំងនិង ស្រែវស្សា	១៧៤១,២៣	១២,៣២
- ដីស្រែប្រាំងនិង ស្រែវស្សាក្នុងតំបន់២ ជុំវិញបឹងទន្លេសាប	ដីស្រែប្រាំងនិង ស្រែវស្សា	៥៣៤,៨០	៣,៧៨
ខ.៣.ដីចម្ការ	**ចម្ការ**	**២៣៩១,១៣**	**១៦,៩១**
- ដីចម្ការក្រៅតំបន់ការពារ	ចម្ការ	១៤៦២,០៨	១០,៣៤
- ដីចម្ការក្នុងតំបន់១ជុំវិញបឹងទន្លេសាប	ចម្ការ	៥,៧៥	០,០៤
- ដីចម្ការក្នុងគម្របព្រៃឈើឆ្នាំ២០០២	ចម្ការ	៩២៣,៣០	៦,៥៣
គ.ដីព្រៃ/គម្របព្រៃឈើ		**១៧៧,៣១**	**១,២៥**
- ព្រៃល្បោះ	ព្រៃសហគមន៍	១៧៧,៣១	១,២៥
ឃ.ផ្ទៃទឹក និងខ្សែទឹក		**៦៥៣,៦៤**	**៤,៦២**
ឃ.១.ស្ទឹង	**ស្ទឹងព្រៃប្រស់**	**៦៣១,០៥**	**៤,៤៦**
ឃ.២.ស្រះទឹក		**២២,៥៩**	**០,១៦**
- ស្រះក្រៅតំបន់ការពារ	ស្រះ	១៤,០៩	០,១០
- ស្រះក្នុងតំបន់១ជុំវិញបឹងទន្លេសាប	ស្រះ	៨,៥០	០,០៦
ក្រឡាផ្ទៃសរុបនៅក្នុងឃុំ		**១៤១៣៩,៣៧**	**១០០**

ក.ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ

ដីលំនៅឋាន ភូមិ គឺជាដីត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានមានលាយសួនដំណាំ និងឈើហូបផ្លែនៅជុំវិញ។ នៅពេលបច្ចុប្បន្ននេះ ដីលំនៅឋាន ភូមិនៅក្នុងឃុំត្បែងមានទំហំផ្ទៃដីសរុបចំនួន ៣៨៤,៧៦ ហិកតាភាគច្រើនស្ថិតនៅតាមបណ្តោយជាប់ផ្លូវជាតិលេខ៦ និងមានចំនួនតិចតួចស្ថិតនៅភាគខាងជើងនិងភាគខាងត្បូង

ផ្លូវជាតិលេខ៦ ដែលបច្ចុប្បន្ននេះបាននិងកំពុងប្រើប្រាស់ជាដីលំនៅឋាន ភូមិ ស្ថិតនៅតាម ៣តំបន់ផ្សេងៗគ្នា គឺ ក្រៅតំបន់ការពារ តំបន់១ និងតំបន់ក្នុងគម្រូបព្រៃឈើឆ្នាំ២០០២ ដូចមានរៀបរាប់ខាងក្រោម៖

-ដីលំនៅឋានភូមិក្រៅតំបន់ការពារ

ដីលំនៅឋានភូមិក្រៅតំបន់ការពារមានទំហំផ្ទៃដីចំនួន ១៨៨,០៨ហិកតា ភាគច្រើនស្ថិតនៅភាគខាងជើង ផ្លូវជាតិលេខ ៦ ជាដីលំនៅឋាន ភូមិ ស្ថិតនៅក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប ដែលមានភូមិចំនួន ០៩ ដូចជា ភូមិឈើទាល ភូមិភ្លូង ភូមិអូរអំបែង ភូមិតាអាំ ភូមិបឹងអណ្តែង ភូមិត្រាច ភូមិស្រង៉ែ ភូមិត្បែង ក និងភូមិត្បែង ខ ព្រមទាំងមានភូមិចំនួន០៤ ទៀត ស្ថិតនៅតាមបណ្តោយសងខាងជាប់នឹងផ្លូវជាតិលេខ៦ ដែលមួយផ្នែកខាងជើង ផ្លូវជាតិ ស្ថិតនៅក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប។ ផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំត្បែងនៃរបាយការណ៍ វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីលំនៅឋានភូមិទាំងអស់ ជាតំបន់ទំនាបខ្ពស់មានប្រភេទដីខ្សាច់សុទ្ធពណ៌ស ដីខ្សាច់ លាយពណ៌ប្រផេះ ដីកណ្តេង ដីពពាយកណ្តុរ និងដីឥដ្ឋពណ៌ប្រផេះខ្លាញ់ក្តាម ហើយជាដីដែលកាន់កាប់ដោយ ប្រជាពលរដ្ឋ (ដីកម្មសិទ្ធិឯកជន) ត្រូវបានចុះបញ្ជីជាលក្ខណៈប្រព័ន្ធបានចំនួន ១០ ភាគរយ ។

-ដីលំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប

ដីលំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានទំហំផ្ទៃដីសរុបចំនួន ១៩៥,៩២ ហិកតា ស្ថិតនៅភាគ ខាងត្បូងផ្លូវជាតិលេខ៦ចូលទៅក្នុង មានភូមិចំនួន ០២ គឺភូមិពោធិ៍ និងភូមិត្រាំខ្លា។ បើផ្អែកទៅតាមដ្យាក្រាមពំនុះ កាត់ទទឹងឃុំត្បែងនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីលំនៅឋានភូមិទាំងអស់ ជាតំបន់ទំនាបខ្ពស់ មាន ប្រភេទដីខ្សាច់សុទ្ធពណ៌ស ដីខ្សាច់លាយពណ៌ប្រផេះ ដីកណ្តេង ដីពពាយកណ្តុរ និងដីឥដ្ឋពណ៌ប្រផេះខ្លាញ់ក្តាម ហើយជាដីដែលកាន់កាប់ដោយប្រជាពលរដ្ឋ(ដីកម្មសិទ្ធិឯកជន) កំពុងដំណើរការចុះបញ្ជីជាលក្ខណៈប្រព័ន្ធបាន ចំនួន ១០ ភាគរយ ។

-ដីលំនៅឋានភូមិក្នុងគម្រូបព្រៃឈើឆ្នាំ២០០២

ដីលំនៅឋានភូមិក្នុងគម្រូបព្រៃឈើឆ្នាំ ២០០២ ស្ថិតនៅភាគខាងជើងនៃឃុំ នៅក្នុងភូមិឈើទាល ដែល មានទំហំផ្ទៃដីចំនួន ០,៧៦ ហិកតា។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំត្បែងនៃរបាយការណ៍វិភាគប្រព័ន្ធ ក្សេត្រ-បរិស្ថាន ដីលំនៅឋានភូមិក្នុងគម្រូបព្រៃឈើឆ្នាំ ២០០២ គឺជាតំបន់ទំនាបមធ្យម មានប្រភេទដីខ្សាច់លាយ ឥដ្ឋពណ៌ប្រផេះ ។ ដីលំនៅឋានភូមិនេះ ស្ថិតនៅក្នុងគម្រូបព្រៃឈើឆ្នាំ ២០០២ គឺជាដីសាធារណៈរបស់រដ្ឋ ដែល បច្ចុប្បន្នប្រជាពលរដ្ឋបានប្រើប្រាស់សម្រាប់ការតាំងលំនៅឋានរស់នៅ ។

រូបភាព 5៖ លំនៅឋានភូមិ

លំនៅឋានភូមិ	លំនៅឋានភូមិក្នុងគម្រូបព្រៃឈើឈើ២០០២

ខ.ដីកសិកម្ម

ខ.១.ដីស្រែវស្សា

នាពេលបច្ចុប្បន្ននេះ ដីស្រែវស្សានៅក្នុងឃុំតៀងមានទំហំផ្ទៃដីសរុបចំនួន ៨ ២៥៦,៥០ ហិកតា ហើយបាននិងកំពុងប្រើប្រាស់ជាដីស្រែវស្សា ដែលស្ថិតនៅ ០៣ តំបន់ផ្សេងៗគ្នា ដូចជា ក្រៅតំបន់ការពារ តំបន់១ និងតំបន់ក្នុងគម្របព្រៃឈើឆ្នាំ ២០០២ ដូចមានរៀបរាប់ខាងក្រោម៖

-ដីស្រែវស្សាក្រៅតំបន់ការពារ

ដីស្រែវស្សាក្រៅតំបន់ការពារមានទំហំផ្ទៃដីសរុបចំនួន ៦ ៦៩៧,៦៧ ហិកតា ភាគច្រើនស្ថិតនៅខាងជើងផ្លូវជាតិលេខ៦ ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំតៀងនៃរបាយការណ៍វិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន ដីស្រែវស្សាទាំងនេះ ជាតំបន់ទំនាបមានប្រភេទដីខ្សាច់លាយឥដ្ឋពណ៌ប្រផេះ គឺជាដីកម្មសិទ្ធិឯកជន ដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ ហើយត្រូវបានកំពុងដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធបានចំនួន ១០ភាគរយ។ ដីស្រែទាំងនេះមានមួយផ្នែកនៅក្បែរៗជាប់នឹងដីលំនៅឋានភូមិ ក្រោយពីច្រូតកាត់ស្រូវរួច ប្រជាពលរដ្ឋនៅក្នុងឃុំតែងនាំគ្នាដាំដំណាំរួមផ្សំថែមទៀតរួមមាន ដូចជា ពោត សណ្តែក ឪឡឹក និងបន្លែគ្រប់មុខជាដើម ។ល។ ហើយដីទាំងនេះមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និងស្ទឹងព្រៃប្រស់ ។

-ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប

ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីសរុបចំនួន ១ ១១៣ ហិកតា ស្ថិតនៅភាគខាងត្បូងផ្លូវជាតិលេខ៦។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំតៀងនៃរបាយការណ៍វិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន ដីស្រែទាំងនេះ ជាតំបន់ទំនាប មានប្រភេទដីខ្សាច់លាយឥដ្ឋពណ៌ប្រផេះ ជាដីកម្មសិទ្ធិឯកជន ដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ ហើយត្រូវបានកំពុងដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធបានចំនួន ១០ភាគរយ។ ដីស្រែវស្សាទាំងនេះមានមួយផ្នែកនៅក្បែរៗជាប់នឹងដីលំនៅឋាន ភូមិ ក្រោយពីច្រូតកាត់ស្រូវរួច ប្រជាពលរដ្ឋក្នុងឃុំតែងនាំគ្នាដាំដំណាំរួមផ្សំថែមទៀតរួមមានដូចជា ដំណាំពោត សណ្តែក ឪឡឹក និងបន្លែគ្រប់មុខជាដើម ។ល។ ហើយដីទាំងនេះមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និងស្ទឹងព្រៃប្រស់។

-ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ២០០២

ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ ២០០២ មានទំហំផ្ទៃដីសរុបចំនួន ៤៤៥,៨៣ ហិកតា ដែលមានចំនួន ០៤ ទីតាំង ស្ថិតនៅភាគខាងជើងនៃឃុំ ក្នុងនោះមាន ០៣ ទីតាំង ស្ថិតនៅក្នុងភូមិឈើទាល និង ០១ ទីតាំង ទៀត ស្ថិតនៅក្នុងភូមិក្លូង។ ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ ២០០២ គឺជាតំបន់ទំនាបខ្ពស់ និងមធ្យម មានប្រភេទដីខ្សាច់សុទ្ធពណ៌ស និងដីខ្សាច់លាយពណ៌ប្រផេះ។ ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ ២០០២ ជាដីសាធារណៈរបស់រដ្ឋ ដែលបច្ចុប្បន្ននេះ ត្រូវបានប្រជាពលរដ្ឋប្រើប្រាស់ជាដីស្រែ ដែលមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និងស្ទឹងព្រៃប្រស់។

រូបភាព ៦៖ ស្រូវវស្សា

ខ.២.ដីស្រែប្រាំង និងស្រែវស្សា

ពេលបច្ចុប្បន្ននេះ ដីស្រែប្រាំងនិងស្រែវស្សាក្នុងឃុំត្បែងមានទំហំផ្ទៃដីសរុបចំនួន ២ ២៧៦,០៣ហិកតា ហើយបាននិងកំពុងប្រើប្រាស់ជាដីស្រែប្រាំងនិងស្រែវស្សា ដែលស្ថិតនៅតាម ០២ តំបន់ផ្សេងៗគ្នា គឺ តំបន់១ និង តំបន់២ ដូចមានរៀបរាប់ខាងក្រោម៖

- ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់១ ជុំវិញបឹងទន្លេសាប

ដីស្រែប្រាំងនិង ស្រែវស្សានៅក្នុងតំបន់១ជុំវិញបឹងទន្លេសាប មាននៅផ្នែកខាងត្បូងផ្លូវជាតិលេខ៦ ដែលលាតសន្ធឹងពីផ្លូវជាតិទៅភាគខាងត្បូងនៃឃុំស្របទៅនឹងស្ទឹងព្រៃប្រស់និងមានផ្ទៃដីចំនួន១ ៧៤១,២៣ ហិកតា។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំត្បែងនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែប្រាំង និងស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប គឺជាតំបន់ទំនាបលិចទឹកទន្លេសាប និងស្ទឹងព្រៃប្រស់ មានប្រភេទដីកណ្តេង ដីពពាយកណ្តុរ ដីឥដ្ឋពណ៌ប្រផេះ និងខ្លាញ់ក្តាម ដែលត្រូវបានកាន់កាប់ដោយប្រជាពលរដ្ឋ (ដីកម្មសិទ្ធិឯកជន) ហើយកំពុងដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធបានចំនួន ១០ ភាគរយ ។ ដីស្រែប្រាំងនិង ស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាបនេះ មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និងស្ទឹងព្រៃប្រស់។

- ដីស្រែប្រាំង និងស្រែវស្សាក្នុងតំបន់២ ជុំវិញបឹងទន្លេសាប

ដីស្រែប្រាំងនិង ស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប ស្ថិតនៅភាគខាងត្បូងនៃឃុំ ដែលមានទំហំផ្ទៃដីសរុបចំនួន ៥៣៤,៨០ ហិកតា។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំត្បែង នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែប្រាំងនិងស្រែវស្សា ជាតំបន់ទំនាបលិចទឹកទន្លេសាប មានប្រភេទដីកណ្តេង ដីពពាយកណ្តុរ និងដីឥដ្ឋពណ៌ប្រផេះខ្លាញ់ក្តាម ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមអាស្រ័យផលតែប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ។ ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និងស្ទឹងព្រៃប្រស់។

រូបភាព 7៖ ដីស្រែប្រាំងនិងស្រែវស្សា

ខ.៣.ដីចម្ការ

នាពេលបច្ចុប្បន្ននេះ ដីចម្ការនៅក្នុងឃុំត្បែងមានទំហំផ្ទៃដីសរុបចំនួន ២ ៣៩១,១៣ ហិកតា ហើយបច្ចុប្បន្នបាននិងកំពុងប្រើប្រាស់ជាដីចម្ការ ដែលស្ថិតនៅ ០៣តំបន់ ផ្សេងៗគ្នា គឺក្រៅតំបន់ការពារ តំបន់១ និងតំបន់ក្នុងគម្របព្រៃឈើឆ្នាំ ២០០២ ដូចមានរៀបរាប់ខាងក្រោម៖

-ដីចម្ការក្រៅតំបន់ការពារ

ដីចម្ការក្រៅតំបន់ការពារមានទំហំផ្ទៃដីសរុបចំនួន ១ ៤៦២,០៨ ហិកតា ស្ថិតនៅខាងជើងផ្លូវជាតិលេខ៦ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំត្បែង នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីចម្ការទាំងនេះ ជាតំបន់ទំនាបខ្ពស់មានប្រភេទដីខ្សាច់សុទ្ធពណ៌ស ដីខ្សាច់លាយឥដ្ឋពណ៌ប្រផេះ ជាដីកម្មសិទ្ធិឯកជនដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ ហើយកំពុងដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធបានចំនួន ១០ ភាគរយ និងមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង។

-ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប

ដីចម្ការក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានទំហំផ្ទៃដីចំនួន ៥,៧៥ ហិកតា ដែលស្ថិតនៅភាគខាងត្បូងនៃផ្លូវជាតិលេខ៦។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំត្បែងនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីចម្ការទាំងនេះ ជាតំបន់ទំនាបខ្ពស់ មានប្រភេទដីខ្សាច់សុទ្ធពណ៌ស ដីខ្សាច់លាយឥដ្ឋពណ៌ប្រផេះ ជាដីកម្មសិទ្ធិឯកជនដែលត្រូវបានកាន់កាប់ដោយប្រជាពលរដ្ឋ និងកំពុងតែដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធ បានចំនួន ១០ ភាគរយ និងមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង។

- ដីចម្ការក្នុងគម្របព្រៃឈើឆ្នាំ២០០២

ដីចម្ការក្នុងគម្របព្រៃឈើឆ្នាំ២០០២ មានទំហំផ្ទៃដីចំនួន ៩២៣,៣០ហិកតា ដែលមានចំនួន ០៥ ទីតាំងស្ថិតនៅភាគខាងជើងនៃឃុំ ក្នុងភូមិតាអាំ និងភូមិភ្លូង។ ដីចម្ការក្នុងគម្របព្រៃឈើឆ្នាំ ២០០២ ជាតំបន់ទំនាបខ្ពស់ និងមធ្យម ដែលមានប្រភេទដីខ្សាច់សុទ្ធពណ៌ស និងដីខ្សាច់លាយពណ៌ប្រផេះ ហើយជាដីសាធារណៈរបស់រដ្ឋ ។ ដីចម្ការក្នុងគម្របព្រៃឈើឆ្នាំ ២០០២ បច្ចុប្បន្ននេះត្រូវបានប្រជាពលរដ្ឋកំពុងប្រើប្រាស់ជាដីចម្ការ ដែលភាគច្រើនជាដំណាំស្វាយចន្ទី និងស្វាយកែវល្មៀតមានតិចតួច ដែលមានប្រភពទឹកស្រោចស្រពតែពីទឹកភ្លៀងប៉ុណ្ណោះ ។

រូបភាព ៨៖ ដីចម្ការ

ចម្ការស្វាយ	ចម្ការស្វាយចន្លឹក្នុងគម្របព្រៃឈើ២០០២

គ.ដីព្រៃ/គម្របព្រៃឈើ

- ព្រៃល្បោះ

នៅក្នុងឃុំត្បែងមានដីព្រៃល្បោះ ០១ កន្លែង ស្ថិតនៅចុងភាគខាងជើងនៃឃុំជាប់នឹងព្រំប្រទល់ឃុំនីពេជ្រ ដែលមានទំហំផ្ទៃដីសរុបចំនួន ៧២៩,៦៧ ហិកតា ។ ដីព្រៃល្បោះ គឺជាតំបន់ទំនាបខ្ពស់ មានប្រភេទដីខ្សាច់សុទ្ធពណ៌ស ជាដីសាធារណៈរដ្ឋរបស់រដ្ឋ ។ បច្ចុប្បន្នព្រៃល្បោះនេះ បានផ្តល់អនុផលព្រៃឈើមួយចំនួនដល់ប្រជាជនមានដូចជា ទឹកឃ្មុំ ផ្លែឈើព្រៃ ផ្សិត វល្លិ និងរុក្ខជាតិឱសថជាដើម ប៉ុន្តែបច្ចុប្បន្ននេះ មានការរេចរឹលយ៉ាងច្រើនដែរ ដោយមានការលួចកាប់ធ្វើអាជីវកម្ម និងកាប់រានដីយកធ្វើកសិកម្ម។

រូបភាព ៩៖ ព្រៃល្បោះ

ឃ.ផ្ទៃទឹក និងខ្សែទឹក

-ស្ទឹង

ឃុំត្បែងមានស្ទឹងព្រៃប្រស់ចំនួន ១ខ្សែ ដែលមានទំហំផ្ទៃដីសរុបចំនួន ៦៣១,០៥ហិកតា ជាដីសាធារណៈរបស់រដ្ឋ ហើយក៏ជាប្រភពទឹកដ៏សំខាន់ សម្រាប់ស្រោចស្រពដំណាំស្រូវ និងដំណាំផ្សេងៗទៀតរបស់ប្រជាពលរដ្ឋ

នៅក្នុងឃុំ ព្រមទាំងជាប្រភពធនធានជលផលផងដែរ។ ស្ទឹងព្រៃប្រស់នេះ ហូរកាត់តាមព្រំប្រទល់រវាងឃុំត្បែង និង ឃុំត្រពាំងឫស្សីពីជើងទៅត្បូងចាក់ចូលទៅបឹងទន្លេសាប ដែលផ្តល់ទឹកបានតែនៅក្នុងរដូវវស្សាប៉ុណ្ណោះ។

រូបភាព 10៖ ស្ទឹងព្រៃប្រស់

-ស្រះទឹក

នៅក្នុងឃុំត្បែងមានស្រះទឹកចំនួន ១៦ កន្លែង ដែលនៅក្នុងនោះមានស្រះសហគមន៍ចំនួន ០៣កន្លែង គឺ ស្រះសហគមន៍វីឡទ្បៃត្បែង ស្រះសហគមន៍តារាម និងស្រះសហគមន៍ត្រាច ក្រៅពីនោះគឺជាស្រះឯកជន ដែល ភាគច្រើនស្ថិតនៅលាយឡំជាមួយតំបន់លំនៅឋានរបស់ប្រជាពលរដ្ឋនិងតំបន់ស្រែវស្សា ដែលត្រូវបានប្រើប្រាស់ សម្រាប់បរិភោគ ស្រោចស្រពដំណាំផ្សេងៗ និងជាប្រភពធនធានជលផលផងដែរ ដែលមានទំហំផ្ទៃដីសរុបចំនួន ២២,៥៩ ហិកតា។

រូបភាព 11៖ ស្រះទឹក

ពាក់ព័ន្ធបញ្ហាផ្សេងៗក្នុងការប្រើប្រាស់ដីនៅក្នុងឃុំត្បែងតាមរយៈការសម្ភាសន៍លោកមេឃុំ បានឱ្យដឹងថា មានប្រជាពលរដ្ឋក្នុងឃុំចំនួន ៦៥ គ្រួសារ មិនមានដីសម្រាប់សាងសង់លំនៅឋាន និង ១៤០ គ្រួសារ មិនមានដីធ្វើ របរកសិកម្មឡើយ។ ក្នុងចំណោមប្រជាពលរដ្ឋទាំងនេះ មានមួយចំនួនរស់នៅលើដីចិញ្ចើមផ្លូវ រស់នៅលើដីកម្មសិទ្ធិ

របស់គេផ្សេង ព្រមទាំងមួយចំនួនទៀត រស់នៅជាមួយឪពុកម្តាយ។ ចំណែកបញ្ហាទំនាស់ក្នុងការការប្រើប្រាស់ដីនៅក្នុងឃុំដំរីស្លាប់វិញ ពុំមានចេញជារូបភាពធំដុំគួរឱ្យកត់សម្គាល់ឡើយ ទោះបីមិនទាន់ត្រូវបានចុះបញ្ជីកាន់កាប់ដីរួចរាល់ក៏ដោយ តែក្រុមប្រឹក្សាឃុំអាចសម្របសម្រួល និងដោះស្រាយបាន។

១.៣.២.ផលិតកម្ម កសិកម្ម

ក.ផលិតកម្មដំណាំស្បៀង

ផលិតកម្មដំណាំស្បៀងនៅក្នុងឃុំតៀង បានផ្តោតសំខាន់ទៅលើផលិតកម្មដំណាំស្រូវ ហើយដំណាំនេះបានដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍឃុំ ដោយសារផលិតផលស្រូវ ក្រៅពីប្រជាពលរដ្ឋបានទុកផ្គត់ផ្គង់សម្រាប់ការហូបចុក និងមាននៅសល់បានទុកលក់សម្រាប់បំពេញតម្រូវការចាយវាយចាំបាច់ក្នុងជីវភាពរស់នៅផងដែរ។ ដំណាំស្រូវបានផលិតនៅលើផ្ទៃដីស្រែសរុបទំហំ ១០ ៥៣២,៥៣ ហិកតា ដែលលាតសន្ធឹងស្ទើតែពេញផ្ទៃដីឃុំទាំងមូល គឺប្រមាណជា ៧៤ ភាគរយ នៅក្នុងនោះផ្ទៃដីសម្រាប់ស្រែវស្សាមានទំហំ ៨ ២៥៦,៥០ហិកតា ជាចំនួនភាគច្រើនស្ថិតនៅភាគខាងជើងនៃឃុំ និងផ្ទៃដីស្រែប្រាំងនិងវស្សា ដែលមានទំហំផ្ទៃដីចំនួន ២២៧៦,០៣ហិកតានៅភាគខាងត្បូង ។ ដីស្រែទាំងនេះ មានប្រភេទដីខ្សាច់សុទ្ធពណ៌ស ដីខ្សាច់លាយពណ៌ប្រផេះ ដីខ្សាច់លាយឥដ្ឋពណ៌ប្រផេះ ដីកណ្តោង ដីពពាយកណ្តុរ និងដីឥដ្ឋពណ៌ប្រផេះខ្លាញ់ក្តាម ដែលបច្ចុប្បន្ន ត្រូវបានប្រជាពលរដ្ឋប្រើប្រាស់សម្រាប់ធ្វើស្រែវស្សា និយមប្រើពូជស្រូវស្រាល ស្រូវរំដួលស្រូវ ៥៤៥១ ស្រូវវស្សា (ពូជនាងគង់) ពូជផ្ការំដួល ពូជរាំងជ័យ ស្រូវប្រាំង (៥៤៥១) ស្រូវការមួន និងស្រូវសែនក្រអូប និងធ្វើស្រែប្រាំង និយមប្រើពូជស្រូវពពាយ ពូជស្រូវ ៥៤៥១ ពូជបាំងកក ពូជស្រូវ ៥០៤ និងពូជឡើងទឹក ។ ក្នុងការស្រោចស្រពសម្រាប់ដំណាំស្រូវនៅក្នុងឃុំតៀង ត្រូវបានប្រើប្រាស់ទឹកពីប្រភពទឹកភ្លៀង ស្ទឹងព្រៃប្រស់ បឹងព្រៃប្រស់ និងស្រះសហគមន៍ ដែលនាំទឹកមកស្រោចស្រពតាមរយៈប្រព័ន្ធប្រឡាយ ដែលបច្ចុប្បន្ននៅមានការខូះខាតនៅឡើយ ។ ជាទូទៅប្រជាពលរដ្ឋនៅក្នុងឃុំតៀង បានទទួលផលស្រូវវស្សាជាមធ្យម ១,៥ តោន/ហ.ត ស្រូវប្រាំងជាមធ្យម ២,៥ តោន/ហ.ត ហើយបានពិនិត្យឃើញថាក្នុងឆ្នាំ២០១៧នេះ នៅក្នុងឃុំទទួលបានផលស្រូវសរុបចំនួន ១៨ ៩២២ តោន ក្នុងនោះផលស្រូវវស្សាមាន ១១ ៦៨៩ តោន និងស្រូវប្រាំងចំនួន ២ ៦៧២ តោន ដោយទុកហូបចុក ៣០ ភាគរយ ទុកពូជ ១០ ភាគរយ និងសល់ពីនេះ បានធ្វើការលក់ចេញចំនួន ១១ ៣៥៣ តោន នៅក្នុងតម្លៃ ៨២៩ រៀល/គ.ក្រជាមធ្យម ដែលទទួលបានចំណូលសរុបប្រមាណ ៩ ៤១២ លានរៀល។

តារាង 23៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

ឧបសគ្គ	ឱកាស
- ភាពរាំងស្ងួត - សត្វល្អិតបំផ្លាញ និងជម្ងឺលើដំណាំស្រូវ - ប្រើប្រាស់ពូជស្រូវតាមទម្លាប់ - ខ្វះបច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំកសិកម្ម - ខ្វះបច្ចេកទេសដាំ និងថែទាំដំណាំស្រូវ - ប្រព័ន្ធប្រឡាយមានស្រាប់រងការខូចខាត (រាក់) - ខ្វះកម្លាំងពលកម្ម(ចំណាកស្រុកច្រើន) ។	- ដីស្រែធំទូលាយរហូត ៧៤ភាគរយ នៃផ្ទៃដីសរុប - ស្ថានភាពដីស្រែជាវាលទំនាប អាចមានលទ្ធភាព នាំទឹកពីប្រភពបឹងព្រៃប្រស់ បឹងព្រៃប្រស់ មកផ្គត់ផ្គង់ការស្រោចស្រព ដើម្បីធ្វើស្រែបង្កើនរដូវ២-៣ដងក្នុងមួយឆ្នាំបាន - មានប្រព័ន្ធប្រឡាយស្រាប់ - មានកម្លាំងពលកម្មច្រើន - មានគោលការណ៍ជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិ

	បាលក្នុង ការពង្រឹងតួនាទីលើវិស័យកសិកម្ម - មានគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ របស់រាជរដ្ឋាភិបាល។

ខ.ផលិតកម្មដំណាំរួមផ្សំ

ផលិតកម្មដំណាំរួមផ្សំក្នុងឃុំត្បែងបច្ចុប្បន្ន មានដូចជា ស្ពៃ ត្រកួន ត្រសក់ សណ្តែក ននោង ល្ពៅជាដើម ដែលភាគច្រើន ពួកគាត់ធ្វើការដាំដុះជាលក្ខណៈគ្រួសារ នៅលើដីជុំវិញលំនៅឋាន និងលើដីស្រែវស្សានៅជាប់ក្បែរភូមិក្រោយពីច្រូតកាត់រួច ដោយពុំមានទិន្នន័យការអះអាងកំណត់ទំហំដីច្បាស់លាស់បាន។ ដីសម្រាប់ដំណាំរួមផ្សំទាំងនេះជាប្រភេទដីខ្សាច់លាយពណ៌ប្រផេះ ហើយមានប្រភពស្រោចស្រពពីទឹកស្ទឹងព្រៃប្រស់ បឹងព្រៃប្រស់ ស្រះ និងអណ្តូងទឹកក្រោមដី ដែលទទួលបានផលសម្រាប់ផ្គត់ផ្គង់ការហូបចុក និងលក់ដូរបន្តិចបន្តួច ដើម្បីបានកម្រៃខ្លះក្នុងការជួយបំពេញញការខ្វះខាតក្នុងជីវភាពគ្រួសារតែប៉ុណ្ណោះ។

តារាង 24៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

ឧបសគ្គ	ឱកាស
- ការយល់ដឹងពីបច្ចេកទេសដាំដំណាំរបស់ប្រជាពលរដ្ឋនៅមានកម្រិត។ - សត្វល្អិតបំផ្លាញ - ដំណាំកើតមានជម្ងឺ - ខ្វះខាតទឹកស្រោចស្រពនៅរដូវប្រាំង	- មានដីល្បាប់តាមមាត់បឹងព្រៃប្រស់ - មានដីនៅជុំវិញលំនៅឋាន - មានប្រភពទឹកស្ទឹង ស្រះ និងទឹកក្រោមដី សម្រាប់ការស្រោចស្រព - ប្រជាពលរដ្ឋមានការយល់ដឹងពីសារៈប្រយោជន៍នៃដំណាំរួមផ្សំដែលអាចជួយផ្គត់ផ្គង់ដល់ការហូបចុក កាត់បន្ថយបានលើការចំណាយ ហើយបានលក់ខ្លះដោះស្រាយដល់ជីវភាពរស់នៅប្រចាំថ្ងៃ។

គ.ផលិតកម្មឧស្សាហកម្ម

ផលិតកម្មដំណាំឧស្សាហកម្មបច្ចុប្បន្នក្នុងឃុំត្បែង ក៏បានដើរតួយ៉ាងសំខាន់ដែរក្នុងការអភិវឌ្ឍឃុំបន្ទាប់ពីដំណាំស្រូវ ហើយត្រូវបានផលិតនៅលើទំហំផ្ទៃដី ២ ៣៩១,១៣ ហិកតា ជាប្រភេទដីខ្សាច់សុទ្ធពណ៌ស ដីខ្សាច់លាយតដ្ឋពណ៌ប្រផេះ។ ដំណាំឧស្សាហកម្មទាំងនេះ ភាគច្រើនជាដំណាំស្វាយចន្ទី និងស្វាយកែវល្មៀតមានចំនួនតិចតួច ដែលមិនបានទទួលការស្រោចស្រពបន្ថែមក្រៅពីទឹកភ្លៀងនោះទេ ហើយទទួលបានទិន្នផលជាមធ្យម ១,៥តោន/ហ.ត ដែលនៅក្នុងឆ្នាំ២០១៧ ទទួលបានទិន្នផលសរុបប្រមាណ ៥៧៤ តោន ចំណែកដំណាំស្វាយកែវល្មៀតទទួលបានទិន្នផលជាមធ្យម ១តោន/ហ.ត ហើយនៅក្នុងឆ្នាំ២០១៧ ទទួលបានទិន្នផលសរុបប្រមាណ ១២ តោន។

តារាង 25៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

ឧបសគ្គ	ឱកាស
-ជួបគ្រោះរាំងស្ងួត -ខ្វះខាតទឹកស្រោចស្រព -ជួបប្រទះទឹកជំនន់(ទឹកភ្លៀង)	-មានផ្ទៃដីធំទូលាយរហូតដល់ ១៧ ភាគរយ នៃផ្ទៃដីសរុប -អាចពង្រីកផ្ទៃដីដាំដុះលើដំណាំនេះបាន -មានប្រភពទឹកភ្លៀង ទឹកបឹង សម្រាប់ការស្រោចស្រព

-សត្វល្អិតបំផ្លាញនិងជម្ងឺលើដំណាំ -ដីខ្វះជីវជាតិ -បច្ចេកទេសដាំ និងថែទាំដំណាំនៅមានកម្រិត -តម្លៃនៅទីផ្សារមានការប្រែប្រួលមិនទៀងទាត់	-មានបច្ចេកទេសដាំដុះនិងថែទាំដំណាំគ្រប់គ្រាន់ពីអ្នកជំនាញបច្ចេកទេសកសិកម្ម

១.៣.៣.ធនធានធម្មជាតិ

ក.ធនធានព្រៃឈើ

បច្ចុប្បន្ននៅក្នុងឃុំត្បែង មានធនធានព្រៃឈើគ្របដណ្តប់លើផ្ទៃដីប្រមាណ ១៧៧,៣១ ហិកតា ស្មើនឹង ១,២៥ភាគរយ នៃផ្ទៃដីឃុំទាំងមូលជាប្រភេទព្រៃល្បោះ ដែលមានមុខងារការពារឱ្យមានស្ថេរភាពទៅលើបរិស្ថានធម្មជាតិ ដូចជា ចរន្តទឹកភ្លៀង ខ្យល់អាកាស សីតុណ្ហភាពជាដើម។ល។ ព្រមទាំងផ្តល់នូវផលមួយចំនួន ដូចជា ទឹកឃ្មុំ ផ្លែឈើព្រៃ ផ្សិត វល្លិ និងរុក្ខជាតិឱសថ និងកូនឈើសម្រាប់ធ្វើរបងផ្ទះជាដើម ដែលមានបរិមាណតិចតួចសម្រាប់ផ្គត់ផ្គង់សេចក្តីត្រូវការរបស់ប្រជាពរដ្ឋក្នុងឃុំតែប៉ុណ្ណោះ។

តារាង 26៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

ឧបស័គ្គ	ឱកាស
- មានការកាប់បំផ្លាញឈើសម្រាប់ធ្វើឧសដុត និងប្រើប្រាស់ផ្សេងៗ - មានការកាប់បំផ្លាញឈើដើម្បីយកដីកាន់កាប់ - ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីផលប្រយោជន៍នៃដើមឈើនៅមានកម្រិត - ការអនុវត្តច្បាប់ព្រៃឈើនូវមិនទាន់បានពេញលេញ - ការផ្សព្វផ្សាយច្បាប់ពុំទាន់បានទូលំទូលាយនៅឡើយ	- មានច្បាប់និងអនុក្រឹត្យស្តីពីព្រៃឈើ - មានសហគមន៍ព្រៃឈើការពារ - មានដីព្រៃឈើធម្មជាតិ - មានរដ្ឋបាលព្រៃឈើជាសមត្ថកិច្ចគ្រប់គ្រងព្រៃឈើ

ខ.ធនធានជលផល

បច្ចុប្បន្នឃុំត្បែង មានស្ទឹងចំនួន១ គឺស្ទឹងព្រៃប្រស់ ដែលមានទំហំ ៦៣១,០៥ ហិកតា និងស្រះទឹកមាន ចំនួន ១៦ កន្លែង ដែលមានទំហំផ្ទៃដីសរុប ២២,៥៩ ហិកតា ។ ស្ទឹង បឹង និងស្រះទាំងអស់នេះ បានផ្តល់នៅធនធានជលផលដ៏សំខាន់ក្នុងឃុំ មានដូចជា ត្រីរ៉ស់ ត្រីឆ្តោរ ត្រីអណ្តែង ត្រីក្រាញ់ ត្រីទីឡាបស្យា អន្ទង់ ក្តាម ខ្យង កង្កែប អណ្តើក និងពស់ជាដើម។ល។ ហើយត្រូវបានធ្វើការនេសាទដោយប្រជាជននៅក្នុងឃុំជាលក្ខណៈគ្រួសារ តាមរយៈការប្រើប្រាស់ ឧបករណ៍ សំណាញ់ មង ទ្រ អួន សន្ទូច ជាលក្ខណៈប្រពៃណី ដែលផលនេសាទទាំងនេះ សម្រាប់តែការហូបចុក និងលក់ដូរតិចតួចប៉ុណ្ណោះ។

តារាង 27៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

ឧបស័គ្គ	ឱកាស
- មានការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិតមិនសមស្របលើដំណាំកសិកម្ម នាំឱ្យមានការថយចុះបរិមាណធនធានជលផល	- មានស្ទឹង បឹង អាងស្តុកទឹក ស្រះ និងស្រែ ដែលអំណោយផលដល់ធនធានជលផល - មានច្បាប់ជលផល

- ការប្រើឧបករណ៍នេសាទខុសច្បាប់។	- ប្រើប្រាស់ឧបករណ៍បែបប្រពៃណី ។

១.៣.៤.ធនធានរ៉ែ

នៅក្នុងឃុំត្បែង មិនមានទិន្នន័យ ពីជំនាញពាក់ព័ន្ធអំណះអំណាងពីវត្តមានធនធានរ៉ែ នៅក្នុងឃុំគួរឱ្យកត់សម្គាល់បាននោះទេ។

១.៤.ទីផ្សារ និងខ្សែសង្វាក់ផលិតផល

១.៤.១.ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ

បច្ចុប្បន្ននៅក្នុងឃុំត្បែង មានតែផលិតផលស្រូវ និងស្វាយចន្ទី ដែលអាចនាំចេញទៅរកទីផ្សារ ហើយផលិតផលស្រូវ ដែលសល់ពីការហូបចុក អាចនាំទៅរកទីផ្សារមានប្រភេទស្រូវប្រដេញទឹក (ពូជ៥០៤/៥៤៥១) ស្រូវ ៥០៤ និងស្រូវផ្ការំដួល ដោយឡែកផលិតផលដំណាំស្វាយចន្ទីនាំទៅរកទីផ្សារទាំងអស់ ។ បើយោងតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំត្បែងឆ្នាំ២០១៧ បានឱ្យដឹងថា ស្រូវប្រដេញទឹក(ពូជ៥០៤/៥៤៥១) និងស្រូវ៥០៤ មានតែទីផ្សារនៅប្រទេសវៀតណាម ដែលប្រជាពលរដ្ឋតែងលក់ស្រូវសើម ៩០ភាគរយតាមរយៈឈ្មួញមកទទួលទិញដល់ក្នុងឃុំ មានតម្លៃត្រឹម ៧០០-៨០០០ រៀលក្នុងមួយគីឡូក្រាម ចំណែកស្រូវផ្ការំដួលមានទីផ្សារនៅក្នុងប្រទេស និងទីផ្សារនៅប្រទេសប្រទេសវៀតណាមដូចគ្នា ប្រជាពលរដ្ឋតែងលក់ស្រូវសើម ៧០ ភាគរយ តាមរយៈឈ្មួញមកទទួលទិញដល់ក្នុងឃុំដែរ ដែលមានតម្លៃចាប់ពី ៩០០-១០០០ រៀល ក្នុងមួយគីឡូក្រាម។ ចំណែកផលិតផលស្វាយចន្ទីតាមការសាកសួរប្រជាពលរដ្ឋក្នុងឃុំបានឲ្យដឹងថា មានឈ្មួញកណ្តាលមកទិញដល់ក្នុងឃុំ ហើយឈ្មួញបន្តលក់ទៅឱ្យទីផ្សារក្នុងប្រទេសវៀតណាមដែលមានតម្លៃប៉ុន្មាន ៧០០០រៀល/គីឡូក្រាមនៅដើមរដូវប្រមូលផល និង ២៥០០ រៀល/គីឡូក្រាមនៅចុងរដូវប្រមូលផល ។

តារាង 28៖ ស្ថិតិផលិតផលស្រូវ និងតម្លៃ

ល.រ	ប្រភេទផលិតផលស្រូវ	ឯកតា	តម្លៃជារៀល	តម្លៃជារៀលទីផ្សារ	
				ក្នុងស្រុក	ក្រៅប្រទេស
១	ស្រូវប្រដេញទឹក(ពូជ៥០៤/៥៤៥១) និង៥០៤	១ គ.ក្រ	៧០០-៨០០០		វៀតណាម
២	ស្រូវផ្ការំដួល	១ គ.ក្រ	៩០០-១០០០		វៀតណាម
៤	ស្វាយចន្ទី	១ គ.ក្រ	៧០០០-២៥០០		វៀតណាម

១.៤.២.ខ្សែសង្វាក់ និងចរាចរផលិតផល

តាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំត្បែងឆ្នាំ២០១៧ បានឱ្យដឹងថា បច្ចុប្បន្ននេះ នៅក្នុងឃុំត្បែង ការផលិតដំណាំស្រូវរហូតដល់បានផលលក់ចេញ គឺត្រូវដំណើរការតាមខ្សែសង្វាក់ជាបន្តបន្ទាប់ ដូចជាការផលិតដំណាំស្រូវផ្ការំដួល ដោយចាប់ផ្តើមពីការត្រៀមពូជស្រូវ ដែលភាគច្រើនបានរក្សាទុកដោយខ្លួនឯង ៧០ ភាគរយ និងមានការទិញចូល ៣០ ភាគរយ ហើយមានការរៀបចំដី រួមទាំងការថែទាំ មានការដាក់ជី និងបាញ់ថ្នាំសម្លាប់សត្វល្អិត រហូតដល់ច្រូតកាត់ ដោយប្រើប្រាស់គ្រឿងយន្តរហូត ៩៥ ភាគរយ និងច្រូតកាត់ដោយដៃតែ ៥ ភាគរយ ប៉ុណ្ណោះ។ ផលស្រូវដែលទទួលបានត្រូវហាលសម្ងួតទុកពូជ ១០ ភាគរយ និងទុកផ្គត់ផ្គង់ការហូបចុកប្រមាណ ២០ ភាគរយ ចំណែកផលស្រូវនៅសើម ដែលសល់ប្រមាណ ៧០ ភាគរយ យកទៅលក់ឱ្យឈ្មួញនៅតាមដងផ្លូវក្នុងឃុំ បានតម្លៃ ៩០០-១០០០ រៀល

ក្នុងមួយគីឡូក្រាម ហើយឈ្មួញបន្តលក់ឱ្យរោងម៉ាស៊ីនកិនស្រូវ យកទៅកិនកែច្នៃជាអង្ករ នាំទៅទីផ្សារក្នុងប្រទេស និងទីផ្សារក្រៅប្រទេស។ តែចំពោះស្រូវប្រដេញទឹក (ពូជ ៥០៤/៥៤៥១) និងស្រូវ ៥០៤ វិញ ពូជត្រូវបានទុកខ្លួនឯង និងទិញខ្លះ ហើយមានការរៀបចំដី រួមទាំងការថែទាំ មានការដាក់ជី និងបាញ់ថ្នាំសម្លាប់សត្វល្អិតរហូតដល់ច្រូតកាត់ដោយគ្រឿងយន្ត ១០០ ភាគរយ ចំពោះផលស្រូវដែលទទួលបានត្រូវបានហាលសម្ងួតទុកពូជ ១០ ភាគរយ ចំណែកផលស្រូវនៅសើមដែលនៅសល់ប្រមាណ ៩០ ភាគរយ យកទៅលក់ឱ្យឈ្មួញនៅតាមដងផ្លូវក្នុងឃុំបានតម្លៃត្រឹមតែ ៧០០-៨០០ រៀលក្នុងមួយគីឡូក្រាម ហើយឈ្មួញបន្តយកទៅលក់ឱ្យទីផ្សារប្រទេសវៀតណាម ។

ទន្ទឹមនេះក្រៅពីផលិតផលស្រូវ ឃុំត្បែងនៅមានផលិតផលស្វាយចន្ទីថែមទៀត ដែលបច្ចុប្បន្នដំណាំនេះ មានដើមលូតលាស់ធំៗ កំពុងផ្តល់ផល បើតាមការសាកសួរប្រជាពលរដ្ឋក្នុងឃុំ បានឱ្យដឹងថា ពួកគាត់នៅក្នុងឃុំកំពុងថែទាំ ជួលគេដាក់ជី បាញ់ថ្នាំសម្លាប់សត្វល្អិត ដែលបំផ្លាញដំណាំរបស់ពួកគាត់ ។ សម្រាប់ផលដំណាំស្វាយចន្ទី ប្រជាពលរដ្ឋអាចធ្វើការប្រមូលផលក្នុងមួយឆ្នាំបាន២ដង គឺនៅដើមរដូវ និងចុងរដូវ ហើយផលិតផលត្រូវបាន ឈ្មួញមកទិញដល់ឃុំផ្ទាល់ និងបានបន្តលក់ទៅប្រទេសវៀតណាម ក្នុងតម្លៃប៉ុន្មាន ៧០០០ រៀល/គីឡូក្រាមនៅដើមរដូវប្រមូលផល និង ២៥០០ រៀល/គីឡូក្រាមនៅចុងរដូវប្រមូលផល។

គំនូសតាងនៃការលំហូផលិតផលកសិកម្ម នៅក្នុងភូមិ និង ការប្រើប្រាស់




-ភ្ជួរ រាស់= ២៦០០០០៛
-ជួលព្រួស ១នាក់
៤ម៉ឺនរៀល/ហ.ត
-ពូជ ១០០គ.ក្រ /ហ.ត
១គ.ក្រ =២៥០០៛
តម្លៃ ៩០០-១០០០៛/គ.ក្រ
ឈ្មួញ
កណ្តាល
លក់ស្រូវសើម
៧០%
ឃ្លាំងស្តុកក្នុង
ខេត្ត
រោងម៉ាស៊ីន
ខេត្ត
កិនអង្ករលក់
-ជីសរីរាង្គ ៤បេ =៣៦០០០០៛
-ថ្នាំសម្លាប់ស្មៅ =៥០០០០៛
ស្រូវវស្សា ផ្ការំដួល
តំបន់ III
លក់ស្រូវស្ងួត
១០%
វៀតណាម
-ច្រូត ១ហ.ត = ២៨០០០០៛
-ច្រក ១បេ=៦០០៛
-ឈ្នួលដឹក ១ហ.ត=៥០០០៛
-ឈ្នួលហាល
១នាក់ =២០០០០៛/ថ្ងៃ
ទុកហូប
២០%
តម្លៃ
១០០០-១២០០៛/គ.ក្រ
ឈ្មួញ
កណ្តាល


-ពូជ M ២៣
-កូន ១ហ.ត =២០០ ដើម
កូកកក
លក់១០០%
ទិន្នផល ៣០០គ.ក្រ/ហ.ត
ឆ្នាំទី១
តម្លៃ
-៧០០០៛/គ.ក្រដើមរដូវ
ប្រមូលផល
-២៥០០៛/គ.ក្រ
ចុងរដូវប្រមូលផល
-ភ្ជួរដី ៣ដង = ៣៦០០០០៛
-ជួលដាំ ១ថ្ងៃ ២០០០០៛/នាក់
១០នាក់/ហ.ត
ស្វាយចន្ទី
តំបន់ I
-បាញ់ថ្នាំសម្លាប់សត្វល្អិត
២ឆ្នាំកន្លះ =៣៨៤០០០០៛
-ឈ្នួលបាញ់ថ្នាំ ១នាក់
៤០០០០៛/២ឆ្នាំកន្លះ
លក់ទៅឈ្មួញកណ្តាល
-ភ្ជួរ ៨ដង/២ឆ្នាំកន្លះ=៩៦០០០០៛
-គាក់តែងមែក ៥ដង/២ឆ្នាំកន្លះ ១០ម៉ឺន
-ដាក់ជី ៨បេ (១បេ=១២០០០០៛)
-ជួលអ្នកដាក់ជី ៥ដង =៣០០០០០៛
-ឈ្នួលរើសផ្លែ
១ថ្ងៃ=២០០០០៛
លក់ទៅវៀតណាម

១.៤.៣.ឧបសគ្គ និងឱកាស

តារាង 29៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

ឧបសគ្គ	ឱកាស
- ឈ្មួញជាអ្នកកំណត់តម្លៃស្រូវ - ឈ្មួញកណ្តាលយកជី ថ្នាំ និងប្រេងមកបណ្តាក់ដោយគិតការប្រាក់ខ្ពស់រហូតដល់ ២ ភាគរយ ក្នុងមួយខែ ហើយទូទាត់នៅពេលប្រមូលផល - កសិករប្រើពូជទុកខ្លួនឯងច្រើនជំនាន់ - ធាតុចូលកសិកម្មថ្លៃខ្ពស់ - តម្លៃស្រូវមិនទៀងទាត់(អាស្រ័យលើឈ្មួញ) - ប្រើប្រាស់ពូជស្រូវវៀតណាម	- មានឈ្មួញមកទិញដល់កន្លែង - មានសេវាកម្មជួលគ្រឿងយន្តកសិកម្ម(ភ្ជួររាស់ ច្រូតកាត់) - មានភាពងាយស្រួលក្នុងការដឹកជញ្ជូនផលិតផលស្រូវ - អាចប្រកួតប្រជែងតម្លៃជាមួយប្រទេសជិតខាង - គុណភាពស្រូវស្របតាមស្តង់ដាសម្រាប់ការនាំចេញ - តម្លៃអង្ករកើនឡើង និងទៀងទាត់ - ពូជស្រូវមានទិន្នផលខ្ពស់ និងតម្លៃខ្ពស់ - កែច្នៃចេញជាផលិតផលសម្រេច

ជំពូក ២៖ ការវិភាគ តម្រូវការ សក្តានុពល និងឧបសគ្គសម្រាប់អនាគត

២.១.តម្រូវការសម្រាប់អនាគត

២.១.១.ផែនការអភិវឌ្ឍ ឃុំ

ក.ផែនការអភិវឌ្ឍឃុំ៥ឆ្នាំ(២០១៨-២០២២)

ផែនការអភិវឌ្ឍឃុំ ៥ ឆ្នាំ គឺជាមធ្យោបាយយ៉ាងសំខាន់របស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ ដែលត្រូវប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហា តម្រូវការ ដែលជាអាទិភាពយ៉ាងពិតប្រាកដរបស់មូលដ្ឋាន និងយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ សំដៅឆ្លើយតបទៅនឹងតម្រូវការជាអាទិភាព របស់ប្រជាពលរដ្ឋនៅក្នុងឃុំយ៉ាងមានប្រសិទ្ធភាពតាមរយៈការរៀបចំឱ្យមានតារាងក្របខ័ណ្ឌអភិវឌ្ឍឃុំមួយ ដែលមានរយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិក្រុមប្រឹក្សាឃុំ។ តារាងក្របខ័ណ្ឌអភិវឌ្ឍឃុំនេះ បានរំលេចនូវចក្ខុវិស័យអភិវឌ្ឍ ដែលជាទស្សនៈរបស់ក្រុមប្រឹក្សាចង់បាន ដើម្បីកែប្រែជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ឱ្យស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ហើយដើម្បីសម្រេចបាននូវចក្ខុវិស័យនេះក៏បានរំលេចចេញឱ្យឃើញពីគោលបំណងអភិវឌ្ឍ ដែលជាលទ្ធផលរួមរបស់ក្រុមប្រឹក្សាព្រមទាំងគោលដៅអភិវឌ្ឍ ដែលជាលទ្ធផលនានារបស់ក្រុមប្រឹក្សាឃុំចង់បាន នៅតាមវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ក៏បានរំលេចឱ្យឃើញនូវយុទ្ធសាស្ត្រអភិវឌ្ឍ ដែលបានកំណត់នូវវិធីសាស្ត្រ ឬសកម្មភាពត្រូវអនុវត្ត ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍនីមួយៗខាងលើ។

ចំណែកឃុំត្បែង ក្រុមប្រឹក្សាឃុំក្នុងអាណត្តិ ២០១៨-២០២២ ក៏បានរៀបចំឱ្យមានផែនការអភិវឌ្ឍឃុំរយៈពេលប្រាំឆ្នាំរបស់ខ្លួន ដែលក្នុងនោះបានលើកឡើងពីគម្រោងវិនិយោគរយៈពេលប្រាំឆ្នាំ ទៅក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍឃុំ ដូចមានខ្លឹមសារ ដែលក្រុមការងារបានដកស្រង់បញ្ចូលក្នុងតារាងខាងក្រោម៖

តារាង 30៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍ និងជម្រើសនៃការប្រាស់ដីធ្លីអនាគត

កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និង យុទ្ធសាស្ត្រ					
តម្រូវការនៃការអភិវឌ្ឍន៍	ប្រភពឯកសារ	គោលដៅនៃការអភិវឌ្ឍន៍	យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍	សកម្មភាពជា អាទិភាព	លេខរៀងនៅលើផែនទី
១	២	៣	៤	៥	៦
១.ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូនល្អប្រសើរ	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២	-ស្តារ និងកែលម្អឡើងវិញបណ្តាញគមនាគមន៍ផ្លូវថ្នល់	-កែលម្អរជួសជុលផ្លូវ និងដាក់លូបង្ហូរទឹក -កសាងផ្លូវថ្មី	-សាងសង់ផ្លូវថ្មីនិងកែលម្អផ្លូវដែលមានស្រាប់ -ជម្រុញការថែទាំជាប្រចាំ -ពង្រឹងការគ្រប់គ្រងដីចំណីផ្លូវ -សាងសង់ និងកែលម្អប្រព័ន្ធលូឱ្យបានត្រឹមត្រូវតាមបច្ចេកទេស -អប់រំណែនាំអ្នកប្រើប្រាស់ពីមូលហេតុដែលបង្កឱ្យខូចថ្នល់ -ដាក់បង្គោលនិងស្លាកសញ្ញាចរាចរណ៍	
២.មានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២	-ពង្រីដីស្រោចស្រពដោយប្រព័ន្ធធារាសាស្ត្រ	-ស្តារនិងជួសជុលប្រព័ន្ធធារាសាស្ត្រចាស់ៗឡើងវិញ -សាងសង់សំណង់ធារាសាស្ត្រ	- សាងសង់សំណង់ធារាសាស្ត្រ - ស្តារឡើងវិញប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ -រៀបចំនិងពង្រឹងសហគមន៍ប្រើប្រាស់ទឹក	
៣.លើកកម្ពស់ផលិតភាពនិង	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ	-បង្កើនចំណេះដឹងបច្ចេកទេសដាំដុះ	-បង្កើនផលិតកសិកម្ម	-បង្កើនចំណេះដឹងបច្ចេកទេសដាំដុះ -ផ្សព្វផ្សាយការប្រើប្រាស់ពូជផ្តល់	

ផលិតកម្មកសិកម្ម	២០១៨-២០២២	ដល់កសិករ		ទិន្នផលខ្ពស់និងស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ -បង្កើនការប្រើប្រាស់គ្រឿងយន្តកសិកម្ម -បង្កើនបច្ចេកទេសការគ្រប់គ្រងផលិតផលស្រូវមុននិងក្រោយពេលប្រមូលផល -ជម្រុញអនុវត្តប្រពលវប្បកម្មដំណាំស្រូវ -បណ្តុះបណ្តាលពីសាលារៀនទីផ្សាកសិករ -ផ្តល់ចំណេះដឹងពីការកែឆ្នៃវេចខ្ចប់ទុកដាក់ផលិតផល -បង្កើនទំនាក់ទំនងព័ត៌មានទីផ្សាផលិតផល	
៤.គ្រួសារចិញ្ចឹមសត្វកើនឡើង	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២	ជម្រុញកំណើនចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនិងកសិដ្ឋាន	-ជម្រុញការផ្តល់បច្ចេកទេសជំនាញកសិកម្ម -ជម្រុញការផ្តល់បច្ចេកទេសចិញ្ចឹមថែទាំសុខភាពសត្វនិងជ្រើសរើសពូជ	-បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ -ផ្តល់វ៉ាក់សាំងការពារ -ផ្តល់ពូជសត្វ	
៥.ឱ្យមានភាពប្រសើរឡើងចំពោះវិស័យឯកជន និងការងារអគ្គិសនី	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២	ជម្រុញអភិវឌ្ឍវិស័យឯកជន និងការងារអគ្គិសនី	-ពង្រឹងកិច្ចសហការជាមួយវិស័យឯកជន និងអង្គភាពអគ្គិសនី	-បង្កលក្ខណៈងាយស្រួលសម្រាការវិនិយោគ -បង្កើនទំនាក់ទំនងឱ្យកាន់តែជិតស្និទរវាងវិស័យឯកជន និងស្ថាប័នរដ្ឋ -ពង្រីកបណ្តាញអគ្គិសនី -សាងសង់កែលម្អរបណ្តាញគមនាគមន៍ -ពង្រីកសេវាឥណទាន	
៦.ប្រជាពលរដ្ឋមានការងារ និងមុខរបរបន្ថែម	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២	បង្កើនសម្ថភាពវិជ្ជាជីវៈដើម្បីបង្កើតមុខរបរនិងការងារ	បើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវគ្គខ្លីៗ	-បណ្តុះបណ្តាលជំនាញ និងវិជ្ជាជីវៈរយៈពេលខ្លី -ពង្រីកថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈ -ផ្តល់ឱកាសដល់យុវជនបានចូលសិក្សានៅសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ	
៧.កម្រិតអប់រំមានគ្រប់កម្រិត និងសិស្សបានចូលរៀនគ្រប់គ្នានៅក្នុងឃុំ	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២២០២	-ពង្រឹងនិងពង្រីកកម្មវិធីអប់រំកុមារតូច -លើកកម្ពស់គុណភាពនិងប្រសិទ្ធិភាពនៃការសិក្សានៅគ្រប់កម្រិត -កាត់បន្ថយអនក្ខរជនឱ្យនៅមានកម្រិតទាបបំផុត	-ពង្រឹងនិងពង្រីកផ្នែកមត្តេយ្យសាលាឱ្យបានគ្រប់មូលដ្ឋានភូមិ -ជម្រុញការយល់ដឹងដល់ឪពុកម្តាយកុមារពីតម្លៃសិក្សា -ពង្រឹងកិច្ចសហការជាមួយមន្ទីរជំនាញ និងអង្គការនានាដើម្បីកាត់បន្ថយអនក្ខរកម្មរបស់ប្រជាពលរដ្ឋ	-បង្កើនសាលាមត្តេយ្យសិក្សារដ្ឋ -គាំទ្រដល់មត្តេយ្យសហគមន៍ដែលមានស្រាប់ -អប់រំមាតាបិតាយស់ពីអត្ថប្រយោជន៍នៃការសិក្សាថ្នាក់ដំបូងរបស់កុមារ -បង្កើតសាលារៀនឱ្យគ្រប់កម្រិតថ្នាក់ស្របតាមភូមិសាស្ត្រជាក់ស្តែង -កែលម្អរគុណភាពនៃការបង្រៀននិងរៀននៅគ្រប់កម្រិតសិក្សា -ផ្តល់លទ្ធភាពដល់សិស្សក្នុងគ្រួសារក្រីក្របានបន្តការសិក្សា -ផ្តល់លទ្ធភាពដល់សិស្សមកឆ្ងាយស្នាក់នៅសាលា -អប់រំមាតាបិតាឱ្យយល់ពីតម្លៃនៃការសិក្សារបស់កូន -កែលម្អរគុណភាពនៃការចូលរៀនតាមភូមិ -ជម្រុញសកម្មភាពថ្នាក់អក្ខរកម្ម -អប់រំដល់អក្ខរជនឱ្យទទួលយកសេវាអក្ខរកម្មផ្តល់សម្ភារសម្រាប់ថ្នាក់អក្ខរកម្ម	
៨.សុខភាពរបស់ប្រជាជន	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ	-លើកកម្ពស់សុខភាពមាតានិង	-បង្កើននិងកែលម្អសេវាសុខភាព និង	-ពង្រឹងនិងពង្រីកសេវាសាធារណៈ -អប់រំពីសុខភាពបន្តពូជ	

ល្អប្រសើរ	២០១៨-២០២២	ទារក -ពង្រឹងវិធានការការពារ ទប់ស្កាត់ជម្ងឺឆ្លងនិងជម្ងឺរ៉ាំរ៉ៃផ្សេងៗទៀត	ចំណេះដឹងដល់ភ្នាក់ងារសុខភាពភូមិ	-អប់រំពីការថែទាំសុខភាពមាតានិងទារក -អប់រំពីបញ្ហាអាហារូបត្ថម្ភ -ផ្តល់វ៉ាក់សាំងការពារជម្ងឺដល់ស្ត្រីនិងកុមារ -អប់រំពីការសម្រាលកូនដោយសុវត្ថិភាព -ផ្តល់សេវាដោយមិនគិតថ្លៃដល់គ្រួសារក្រីក្រ -អប់រំឱ្យមានការចូលរួមធ្វើអនាម័យជាប្រចាំ -អប់រំផ្សព្វផ្សាយវិធីការពារទប់ស្កាត់ជម្ងឺឆ្លងគ្រប់ប្រភេទ -អប់រំឱ្យស្វែងរកសេវាពិគ្រោះនិងព្យាបាលពេលមានជម្ងឺ -មានវិធានការការពារនិងទប់ស្កាត់ផលប៉ះពាល់សុខភាពដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយផ្សេងៗ	
៩.ព្រៃឈើមានចេរភាព	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២	គ្រប់គ្រងនិងអភិរក្សធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយចីរភាព	-មានវិធានការគ្រប់គ្រងនិងប្រើប្រាស់ព្រៃឈើឱ្យមានប្រសិទ្ធភាព	-ពង្រឹងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងព្រៃឈើ -កំណត់ព្រំប្រទល់ចំណាត់ថ្នាក់និងចុះបញ្ជីដែនព្រៃឈើ -មានវិធានការគ្រប់គ្រងនិងប្រើប្រាស់ព្រៃឈើឱ្យមានប្រសិទ្ធភាព -យកចិត្តទុកដាក់លើកកម្ពស់ជីវភាពនិងបង្កើនការចូលរួមរបស់សហគមន៍ដែលរស់នៅអាស្រ័យផលព្រៃឈើ -យកចិត្តទុកដាក់ពង្រឹងសហគមន៍គ្រប់គ្រងព្រៃឈើ -បង្កើនការដាមឈើឡើងវិញ	
១០.ឃុំមានបរិស្ថាន និងធនធានធម្មជាតិស្រស់បំព្រង	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២	គ្រប់គ្រងនិងអភិរក្សធនធានជលផលប្រកបដោយចេរភាព	-បង្កើនសេវាលើការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន	-ពង្រឹងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងធនធានជលផល -បង្កើនប្រសិទ្ធិភាពការគ្រប់គ្រងដែននេសាទ -ពង្រឹងការគ្រប់គ្រងឧបករណ៍នេសាទទាំងរដូវបើកនិងបិទនេសាទ -ទប់ស្កាត់ការកាប់បំផ្លាញព្រៃលិចទឹក -អភិរក្សស្រះជម្រកត្រី	
១១.មានទឹកស្អាតសម្រាប់គ្រួសារប្រើប្រាស់	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០០៨-២០១២	លើកកម្ពស់សុខភាពប្រជាពលរដ្ឋតាមរយៈការប្រើប្រាស់ទឹកស្អាតនិងបង្គន់អនាម័យ	-ពង្រីក និងកែលំអប្រភពផ្គត់ផ្គង់ទឹក	-សាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត -ជួសជុលអណ្តូងដែលមានស្រាប់ -ផ្តល់មធ្យោបាយចម្រោះទឹកស្អាត -បណ្តុះបណ្តាលបច្ចេកទេសថែទាំនិងជួសជុលអណ្តូង -សាងសង់បង្គន់អនាម័យ -ផ្តល់សម្ភារៈសាងសង់បង្គន់អនាម័យ -អប់រំប្រជាពលរដ្ឋឱ្យមានការយល់ដឹងពីសុខភាពនិងអនាម័យ	
១២.ពង្រឹងយន្តការគ្រប់គ្រងគ្រោះមហន្តរាយ	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២	-ត្រៀមលក្ខណៈគ្រប់គ្រង បង្កានិងដោះស្រាយរាល់បញ្ហាដែលកើតឡើងដោយគ្រោះមហន្តរាយផ្សេងៗ -ត្រៀមលក្ខណៈស្តារ	-ការរៀបចំការគ្រប់គ្រងបង្កានិងដោះស្រាយរាល់បញ្ហាដែលកើតឡើងដោយគ្រោះមហន្តរាយផ្សេង -ផ្សព្វផ្សាយ	-បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋពីមុខសញ្ញាគ្រោះថ្នាក់ភាពងាយរងគ្រោះនិងហានិភ័យគ្រោះមហន្តរាយ -រៀបចំផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ -ពង្រឹងក្រុមការងារអន្តរាគមន៍ឆ្លើយតបគ្រោះមហន្តរាយ	

		ឡើងវិញនូវការខូចខាតដែលបណ្ដាលមកពីគ្រោះមហន្តរាយ -ភាពងាយរងគ្រោះនិងហានិភ័យគ្រោះមហន្តរាយ	បច្ចេកទេសនិងផ្ដល់សេវាព្យាបាលកាត់បន្ថយគ្រោះមហន្តរាយកាន់តែមានភាពប្រសើរឡើង	-ត្រៀមស្បៀង និងសម្ភារៈបរិក្ខាសង្គ្រោះបន្ទាន់ -សាងសង់និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត -ផ្ដល់សម្ភារៈកសិកម្ម ពូជ ជី បម្រើឱ្យការដាំដុះឡើងវិញ -ផ្ដល់សេវាព្យាបាល អប់រំ ថែទាំសុខភាព និងអនាម័យ	
១៣.ធ្វើឱ្យប្រសើរឡើងសម្រាប់ការផ្ដល់សេវាអត្រានុកូលដ្ឋាន	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២	ពង្រឹងការងារផ្ដល់សេវាអត្រានុកូលដ្ឋាន	ការផ្ដល់សេវាអត្រានុកូលដ្ឋានដល់ប្រជាពលរដ្ឋឱ្យកាន់ល្អប្រសើរឡើង	-បង្កើនសមត្ថភាពការងាររបស់មន្ត្រីអត្រានុកូលដ្ឋាន -ពង្រឹងការអនុវត្តតួនាទីក្នុងការផ្ដល់សេវាអត្រានុកូលដ្ឋាន -ពង្រឹងយន្តការក្នុងការផ្ដល់សេវាអត្រានុកូលដ្ឋាន -អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីសារសំខាន់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន	
១៤.ធ្វើឱ្យប្រជាពលរដ្ឋរស់នៅប្រកបដោយភាពសុខសាន្ត និងសុវត្ថិភាព	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២	ពង្រឹងការគ្រប់គ្រងព័ត៌មានដើម្បីឆ្លើយតបនឹងគោលនយោបាយគ្រប់វិស័យ	ផ្សព្វផ្សាយពីច្បាប់ផ្សេងៗនិងគោលនយោបាយនានា	-អប់រំផ្សព្វផ្សាយច្បាប់ផ្សេងៗ -អនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព -ពង្រឹងប៉ុស្តិ៍រដ្ឋបាល -ពង្រឹងកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលគ្រប់កម្រិត -ជម្រុញការចូលរួមពីប្រជាពលរដ្ឋ -លុបបំបាត់ភាពអនាធិបតេយ្យនៅតាមដងផ្លូវ	
១៥.សមភាព និងសមធម៌ក្នុងការរស់នៅ	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២	-កាត់ន្ថយអំពើហឹង្សាក្នុងគ្រួសារនិងសហគមន៍	-បង្កើនការផ្សព្វផ្សាយច្បាប់	-អប់រំច្បាប់ស្ដីពីអំពើហឹង្សាក្នុងគ្រួសារនិងកិច្ចការពារជនងាយរងគ្រោះ -ទប់ស្កាត់ការលេងល្បែងស៊ីសងគ្រប់ប្រភេទ -ទប់ស្កាត់ការជួញដូរនិងការប្រើប្រាស់គ្រឿងញៀន -អប់រំកាត់បន្ថយការសេពគ្រឿងស្រវឹង -អប់រំពីការលើកកម្ពស់សីលធម៌ ចរិយាធម៌	
១៦.លុបបំបាត់កាត់បន្ថយទំនាស់ដីធ្លី	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២	-បង្កើនសេវាផ្ដល់ប័ណ្ណកម្មសិទ្ធិដីធ្លី	-ជម្រុញឱ្យប្រជាពរដ្ឋបានយល់ដឹងពីច្បាប់ និងមានកម្មសិទ្ធិដីធ្លីដោយស្របច្បាប់ -បង្កើនការគ្រប់គ្រងដីធ្លីឱ្យស្របតាមគោលនយោបាយរបស់រដ្ឋ	-ពន្លឿនការផ្ដល់ប័ណ្ណកម្មសិទ្ធិដីធ្លីដើម្បីគាំទ្រដំណើរការវាស់វែងដីធ្លីជាប្រព័ន្ធ -បន្តអនុវត្តសកម្មភាពផ្ដល់សេវាវាស់វែងដាច់ដោយដុំ -ផ្សព្វផ្សាយច្បាប់ភូមិបាល	
១៧.លើកម្ពស់យេនឌ័រ	សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២	បង្កើនការយល់ដឹងពីការបញ្ជ្រាបយេនឌ័រនិងការចូលរួមក្នុងឆាកនយោបាយរបស់ស្ត្រី	ការយល់ដឹងរបស់ស្ត្រីកាន់តែប្រសើរឡើង	-ពង្រឹងបណ្ដាញការងារយេនឌ័រ -ជម្រុញការគាំទ្រពីសហគមន៍និងគ្រួសារស្ត្រីចូលរួមក្នុងឆាកនយោបាយ -លើកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពសង្គម	

ខ.គម្រោងអភិវឌ្ឍផ្សេងៗទៀតដែលបានអនុម័តរួច

នៅក្នុងឃុំត្បែង បច្ចុប្បន្នមិនមានគម្រោងណាមួយ ដែលត្រូវបានអនុម័តរួចដើម្បីជំណើរការជួយជំរុញក្នុងការអភិវឌ្ឍឃុំឡើយ។

ផែនទី ១៖ គម្រោងវិនិយោគអាទិភាពឃុំត្បែង



២.១.២.ចំណោលប្រជាសាស្ត្រគិតទៅដល់ឆ្នាំ២០៣២

ការព្យាករណ៍ពីកំណើនប្រជាជន ជាចំណុចសំខាន់ណាស់ សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំត្បែង ដែលអាចឱ្យយើងដឹងមុននូវចំនួនប្រជាជននៅក្នុងឃុំនេះ នៅក្នុងរយៈពេល ១៥ឆ្នាំខាងមុខដ៏វែង អត្រាកំណើនជាមធ្យមរបស់ប្រជាពលរដ្ឋ នៅក្នុងឃុំ ដែលបានបង្ហាញនៅក្នុងជំពូកទី១ បានឱ្យដឹងថា មានចំនួន ២,២០ ភាគរយ ដូច្នេះ ប្រជាពលរដ្ឋក្នុងឃុំនឹងមានការកើនឡើងរហូតដល់ឆ្នាំ ២០៣២ ត្រូវបានធ្វើចំណោលតាមរយៈការគណនាដូចខាងក្រោម៖

-ចំនួនប្រជាជនសរុបក្នុងឆ្នាំ ២០១៧ គឺ ១៦៣៩៣ នាក់

-អត្រាកំណើនមធ្យមប្រចាំឆ្នាំ: ២,២០%

-ចំនួនប្រជាជនកើនឡើងក្នុងរយៈពេល១ឆ្នាំ: ១៦៣៩៣នាក់ x ២,២០% = ៣៦១នាក់/ឆ្នាំ

-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើនឡើងបាន: ៣៦១នាក់/ឆ្នាំ x ១៥ ឆ្នាំ = ៥៤១៥នាក់

-ដូច្នេះប្រជាជនសរុបក្នុងរយៈពេល១៥ខាងមុខមាន: ១៦៣៩៣នាក់ + ៥៤១៥នាក់ = ២១៨០៨នាក់

ចំណែកចំនួនគ្រួសារនៅក្នុងឃុំ នឹងមានការកើនឡើងនៅក្នុងឆ្នាំ ២០៣២ ត្រូវបានធ្វើចំណោលតាមរយៈការគណនាដូចខាងក្រោម៖

-ចំនួនប្រជាជនសរុបក្នុងឆ្នាំ ២០១៧ គឺ ១៦៣៩៣នាក់

-ចំនួនគ្រួសារសរុបក្នុងឆ្នាំ ២០១៧ គឺ ២៨៧០គ្រួសារ

-ចំនួនសមាជិកមធ្យមក្នុងមួយគ្រួសារក្នុងឆ្នាំ ២០១៧ គឺ:

១៦៣៩៣នាក់ /២៨៧០គ្រួសារ = ៥,៧១នាក់/គ្រួសារ

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខចំនួនគ្រួសារកើនឡើងបាន:

៥៤១៥នាក់/ ៥,៧១នាក់/គ្រួសារ = ៩៤៨គ្រួសារ

-ដូច្នេះចំនួនគ្រួសារសរុបក្នុងរយៈពេល១៥ឆ្នាំខាងមុខទៀតមាន:

២៨៧០គ្រួសារ + ៩៤៨គ្រួសារ = ៣៨១៨គ្រួសារ

តារាង 31៖ ចំណោលប្រជាសាស្ត្រនៃចំនួនគ្រួសារ និងប្រជាជនសរុប (០៥ឆ្នាំ)

ឆ្នាំ	ចំនួនគ្រួសារ	ចំនួនប្រជាជន(នាក់)	
		សរុប	ស្រី
២០១៧	២៨៧០	១៦៣៩៣	៨៧១០
២០២២	៣២០៣	១៨១៩៦	៩៩៤៣
២០២៧	៣៥៣៥	១៩៩៩៩	១១១៧៦
២០៣២	៣៨១៨	២១៨០៨	១២៤០៩

☞**ចំណាំ៖**

- ចំណោលប្រជាសាស្ត្រសម្រាប់១៥ឆ្នាំខាងមុខ៖ អត្រាកំណើនមធ្យមប្រចាំឆ្នាំ x ចំនួនប្រជាជនឆ្នាំបច្ចុប្បន្ន/១០០
- ដូច្នេះក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើន៖ អត្រាកំណើនប្រជាជនប្រចាំឆ្នាំ x ១៥
- ដូច្នេះប្រជាជនសរុបក្នុងរយៈពេល១៥ទៀតមាន៖ ចំនួនអត្រាកំណើនប្រជាជន១៥ខាងមុខ + ចំនួនប្រជាជនឆ្នាំបច្ចុប្បន្ន

តារាង 32៖ ចំណោលប្រជាសាស្ត្រតាមក្រុមអាយុ (០៥ឆ្នាំ)

ស្ថិតិតាមក្រុមអាយុ	២០១៧		២០២២		២០២៧		២០៣២	
	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
អាយុពី០-២ឆ្នាំ	៦៧៩	៣៣៥	៧៥៤	៣៧២	៨២៨	៤០៩	៩០៣	៤៤៦
អាយុពី៣-៤	៧៦៩	៣៨៨	៨៥៤	៤៣១	៩៣៨	៤៧៣	១០២៣	៥១៦
អាយុ៥ឆ្នាំ	៩៧៤	៣៧៧	១,០៨១	៤១៨	១,១៨៨	៤៦០	១,២៩៥	៥០១
អាយុ៦-១១ឆ្នាំ	៣,២៤៧	១,៩៧៣	៣,៦០៤	២,១៩០	៣,៩៦១	២,៤០៧	៤,៣១៨	២,៦២៤
អាយុ១២-១៤ឆ្នាំ	១,២៤៦	៦១៨	១,៣៨៣	៦៨៦	១,៥២០	៧៥៤	១,៦៥៧	៨២២
អាយុ១៥-១៧ឆ្នាំ	១,២៧១	៥៨៨	១,៤១១	៦៥៣	១,៥៥១	៧១៧	១,៦៩០	៧៨២
អាយុ១៨-២៤ឆ្នាំ	១,៧២៦	៩៤៧	១,៩១៦	១,០៥១	២,១០៦	១,១៥៥	២,២៩៦	១,២៥៩
អាយុ២៥-៦០ឆ្នាំ	៥,២៧១	២,៨០២	៥,៨៥១	៣,១១០	៦,៤៣១	៣,៤១៨	៧,០១០	៣,៧២៧
អាយុ៦១ឆ្នាំ	១,២១០	៦៨២	១,៣៤៣	៧៥៧	១,៤៧៦	៨៣២	១,៦០៩	៩០៧
ប្រជាជនសរុប	១៦,៣៩៣	៨,៧១០	១៨,១៩៦	៩,៦៦៨	១៩,៩៩៩	១០,៦២៦	២១,៨០២	១១,៥៨៤
ចំនួនគ្រួសារ	២,៨៧០		៣,២០៣		៣,៥៣៥		៣,៨៦៨	

២.១.៣.តម្រូវការដីជាមូលដ្ឋាន

ក.ដីលំនៅឋាន

ចំពោះដីលំនៅឋានភូមិ គឺសំដៅទៅលើដីសម្រាប់សង់ផ្ទះ និងសម្រាប់សួនដំណាំជុំវិញផ្ទះតាមគ្រួសារ។ នៅក្នុងឆ្នាំ២០១៧ ដែលជាឆ្នាំគោលយើងបានដឹងថា ដីលំនៅឋានមានទំហំ ៣៨៤,៧៦ ហិកតា និងមានគ្រួសារសរុបចំនួន ២ ៨៧០ គ្រួសារ គឺជាស្ថានភាពរស់នៅរបស់ប្រជាជន មានភាពសមស្របមិនមានបញ្ហាពីការខ្វះខាតដីសម្រាប់លំនៅឋានឡើយ លើកលែងតែគ្រួសារមួយចំនួនតូចគឺស្មើចំនួន ៦៥ គ្រួសារប៉ុណ្ណោះ ដែលមិនមានដីសម្រាប់សាងសង់លំនៅឋាន ហើយបច្ចុប្បន្នគ្រួសារទាំងនោះ កំពុងរស់នៅលើដីចំណីប្រឡាយ ជាដីសាធារណៈ និងគ្រួសារមួយចំនួនទៀតកំពុងរស់នៅលើដីកម្មសិទ្ធិរបស់អ្នកដទៃ(យោងតាមទិន្នន័យក្នុងជំពូកទី១ ត្រង់ចំណុច ១.៣.១ អំពីការកាន់កាប់ និងការគ្រប់គ្រងការប្រើប្រាស់ដី) ដែលត្រូវយកចិត្តទុកដាក់ដោះស្រាយជូនតាមរយៈដីសម្បទានដីសង្គមកិច្ចមាននៅទីតាំងក្រៅឃុំតាមការសម្រេចចរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ច

ក្នុងឆ្នាំ២០១៧ ផ្ទៃដីលំនៅឋានជាមធ្យមសម្រាប់មួយគ្រួសារមានចំនួន៖

៣៨ ៤,៧៦ ហិកតា/ ២ ៨៧០ គ្រួសារ = ០,១៣ ហិកតា/ គ្រួសារ

តែបើយោងទៅតាមអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច ចែងតម្រូវឱ្យមានដីលំនៅឋាន យ៉ាងច្រើន ០,២៥ហិកតា ក្នុងមួយគ្រួសារ ដែលអាចប្រើប្រាស់សម្រាប់ដោះស្រាយជូន ១៤ គ្រួសារដែលគ្មានដីពិតប្រាកដសម្រាប់លំនៅឋានដើម្បីអាចទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋដែលមាននៅទីតាំងផ្សេងពីឃុំត្បែងនេះ។

ដូច្នេះដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ននេះ ចំពោះប្រជាជន ដែលមានកំណើនក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់ធ្វើកសិកម្មចំនួនតាមការគណនាដូចខាងក្រោម៖

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើនឡើងចំនួនៈ ៥ ៤១៥ នាក់

-ចំនួនសមាជិកមធ្យមក្នុងមួយគ្រួសារមានៈ ៥,៧១ នាក់/គ្រួសារ

-តម្រូវការដីលំនៅឋានក្នុង១គ្រួសារមានចំនួន ០,១៣ ហិកតា/ គ្រួសារ

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខចំនួនគ្រួសារកើនឡើងបានៈ

៥ ៤១៥ នាក់/ ៥,៧១នាក់/គ្រួសារ = ៩៤៨ គ្រួសារ

-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ(២០១៧-២០៣២) ដីលំនៅឋានត្រូវកើនឡើងៈ

៩៤៨ គ្រួសារ x ០,១៣ ហិកតា/គ្រួសារ = ១២៣,២៤ ហិកតា

-ដូច្នេះរហូតដល់ឆ្នាំ ២០៣២ ដីលំនៅឋាននៅក្នុងឃុំត្បែងត្រូវកើនឡើងដល់ៈ

៣៨៤,៤៨ ហិកតា + ១២៣,២៤ ហិកតា = ៥០៧,៧២ ហិកតា

-ចំណែកការដោះស្រាយដីលំនៅឋានជូនគ្រួសារដែលគ្មានដីពិតប្រាកដចំនួន ៦៥គ្រួសារតាមរយៈសម្បទានសង្គមកិច្ចមានចំនួនៈ **៦៥ គ្រួសារ x ០,២៥ ហិកតា/គ្រួសារ = ១៦,២៥ ហិកតា**

តារាង 33៖ តម្រូវការដីសម្រាប់លំនៅឋានក្នុងឆ្នាំ២០៣២

បរិយាយ	២០១៧ បច្ចុប្បន្ន	អនាគត ២០៣២	បម្រែបម្រួលតម្រូវការដី
គ្រួសារ	២៨៧០គ្រួសារ	៣៨១៨គ្រួសារ	៩៤៨ គ្រួសារ
តម្រូវការដីលំនៅឋាន	៣៨៤,៧៦ហិកតា	៥០៧,៧២ហិកតា	១២៣,២៤ហិកតា

ខ.ដីកសិកម្ម

ចំពោះដីកសិកម្មសំដៅទៅលើដីសម្រាប់ធ្វើស្រែ និងដីចម្ការដំណាំ។ នៅក្នុងឆ្នាំ២០១៧ ដែលជាឆ្នាំគោលយើងបានដឹងថា ដីកសិកម្មមានទំហំ ១២ ៩២៣,៦៦ ហិកតា និងមានគ្រួសារសរុបចំនួន ២៨៧០គ្រួសារអាចធ្វើស្រែផលិតស្រូវបានសល់ពីការហូបចុកខ្លះសម្រាប់ការនាំចេញទៅទីផ្សារដោះស្រាយជីវភាព គឺជាស្ថានភាពដែលប្រជាពលរដ្ឋអាចរស់នៅក្នុងជីវភាពសមរម្យបានលើកលែងតែគ្រួសារចំនួន ១៤០ គ្រួសារប៉ុណ្ណោះ ដែលមិនមានដីសម្រាប់ធ្វើកសិកម្មផ្ទាល់ខ្លួន និងនិងមួយចំនួនស៊ីឈ្នួលគេ។

ដូច្នេះបច្ចុប្បន្នទំហំដីកសិកម្មសម្រាប់មួយគ្រួសារមានចំនួន៖

១២ ៩២៣,៦៦ ហិកតា / ២ ៨៧០ គ្រួសារ = ៤,៥០ ហិកតា/ គ្រួសារ

តែបើយោងតាមអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច ចែងតម្រូវឱ្យមានដីកសិកម្មយ៉ាងច្រើន ២ហិកតាក្នុង១គ្រួសារ ដែលអាចប្រើប្រាស់សម្រាប់ដោះស្រាយជូន ១៤០ គ្រួសារ គ្មានដីពិតប្រាកដសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ដើម្បីអាចទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋ ដែលមានទីតាំងផ្សេងពីឃុំត្បែង។

ដូច្នេះដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ន ចំពោះប្រជាជនដែលមានកំណើនក្នុងរយៈពេល ១៥ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់ធ្វើកសិកម្មចំនួនតាមការគណនាដូចខាងក្រោម៖

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ គ្រួសារកើនឡើងចំនួនៈ ៩៤៨ គ្រួសារ

-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ (២០១៧-២០៣២) ដីកសិកម្មត្រូវកើនឡើងៈ

៩៤៨ គ្រួសារ x ៤,៥០ ហិកតា/គ្រួសារ = ៤ ២៦៦ ហិកតា

-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ(២០១៧-២០៣២) ដីកសិកម្មសរុបមានចំនួនៈ

១២ ៩១១,៩៨ ហិកតា + ៤ ២៦៦ ហិកតា = ១៧ ១៧៧,៩៨ ហិកតា

-ចំណែកការដោះស្រាយដីកសិកម្មជូនគ្រួសារដែលគ្មានដីពិតប្រាកដចំនួន ១៤០ គ្រួសារតាមរយៈសម្បទានសង្គមកិច្ចមានចំនួនៈ **១៤០ គ្រួសារ x ២ ហិកតា/គ្រួសារ = ២៨០ ហិកតា**

តារាង 34៖ តម្រូវការដីសម្រាប់កសិកម្មក្នុងឆ្នាំ២០៣២

បរិយាយ	២០១៧ បច្ចុប្បន្ន	អនាគត ២០៣២	បម្រែបម្រួលតម្រូវការដី
គ្រួសារ	២ ៨៧០ គ្រួសារ	៣ ៨១៨ គ្រួសារ	៩៤៨ គ្រួសារ
តម្រូវការដីកសិកម្ម	១២ ៩១១,៩៨ ហិកតា	១៧ ១៧៧,៩៨ ហិកតា	៤ ២៦៦ ហិកតា

គ.ដីព្រៃឈើ

ព្រៃឈើផ្តល់នូវផលិតផលនានា ដែលមានដូចជា ឈើហ៊ុប ឈើគ្រឿងសង្ហារឹម ឈើបង្គោល ឧស និងអនុផលនានា មានជ័រ វល្លិ និងឱសថជាដើម ដែលជួយគាំទ្រទៅដល់ការចិញ្ចឹមជីវិត របស់ប្រជាជននៅជនបទតាមរយៈការប្រើប្រាស់ដោយផ្ទាល់ឬតាមរយៈការលក់ដូរ។ ទន្ទឹមនេះ ព្រៃឈើក៏បានដើរតួយ៉ាងសំខាន់ នៅក្នុងចំណោមតួនាទីដទៃទៀត ដូចជា ការទាក់ទាញទឹកភ្លៀង បញ្ចុះសីតុណ្ហភាព មានអាកាសធាតុបរិសុទ្ធ(ផ្តល់ខ្យល់អាកាសបរិសុទ្ធ) បញ្ចេញឧស្ម័នអុកស៊ីសែន (ជួយស្រូបយកឧស្ម័នកាបូននិច និងបញ្ចេញឧស្ម័នអុកស៊ីសែនទៅដល់មនុស្ស) ការពារគ្រោះធម្មជាតិ (ជួយទប់ទល់ខ្យល់ព្យុះទឹកជំនន់ជួយការពារការហូរច្រោះដី និងបាក់ដី) ធ្វើឱ្យដីមានជីជាតិ ជាតំបន់ទេសចរធម្មជាតិ ។ ចំណែកព្រៃលិចទឹកសាប ជាជម្រកត្រីពង ផ្តល់ជីជាតិដី សម្រាប់ធ្វើកសិកម្ម រក្សាជីវសាស្រ្តចម្រុះ...។ នៅឃុំត្បែង មានដីព្រៃឈើចំនួន ១៧៧,៣១ ហិកតា ស្មើនឹង ១,២៥ ភាគរយ

នៃផ្ទៃដីឃុំទាំងមូល ដែលនាពេលអនាគតឃុំ មិនអាចមានលទ្ធភាពពង្រីកដីបន្ថែមសម្រាប់ព្រៃឈើនោះទេ តែនៅក្នុងឃុំមានលទ្ធភាពក្នុងការដាំដើមឈើបន្ថែមលើដីសាធារណៈផ្សេងៗ ដូចជា នៅតាមដងផ្លូវ ស្ទឹង ប្រឡាយ សាលាឃុំ សាលារៀន មណ្ឌលសុខភាព និងនៅតាមវត្តអារាមជាដើម សម្រាប់ជាម្លប់ពណ៌បៃតង ធ្វើឱ្យដីមានជីជាតិ ផ្តល់អុកស៊ីសែន ស្រូបឧស្ម័នកាបូនិកជួយដល់សុខភាពប្រជាពលរដ្ឋ ។ល។

ឃ.សម្រាប់ធនធានទឹក

ឃុំត្បែង ជាឃុំមួយមានសក្តានុពលទៅលើផ្នែកសិកម្ម ដំណាំស្រូវ និងចម្ការដំណាំឧស្សាហកម្ម ដែលនាំឱ្យឃុំត្បែង មានគោលដៅអភិវឌ្ឍរយៈពេលវែងរបស់ខ្លួនផ្តោតសំខាន់ទៅលើកសិកម្មដំណាំស្រូវ និងចម្ការដំណាំឧស្សាហកម្មនេះមិនអាចគេចចេញបានឡើយ។ ដូច្នេះដើម្បីជំរុញវិស័យកសិកម្មដំណាំស្រូវ កត្តាចាំបាច់មួយក្នុងចំណោមកត្តាជាច្រើន គឺទឹក ដែលជាកត្តាសំខាន់ត្រូវយកចិត្តទុកដាក់ ដោយត្រូវធ្វើយ៉ាងណាឱ្យមានទឹកគ្រប់គ្រាន់សម្រាប់ការស្រោចស្រពបាននៅគ្រប់រដូវកាលទៅលើដីស្រែ និងចម្ការដែលឃុំមាន ដើម្បីដោះស្រាយទឹកពេលមានគ្រោះរាំងស្ងួត និងធ្វើស្រែបង្កើនរដូវឱ្យទទួលបានផលិតភាពខ្ពស់ ដើម្បីជួយផ្គត់ផ្គង់ទៅដល់ការហូបចុក និងជំរុញការនាំចេញ សម្រាប់បង្កើនសេដ្ឋកិច្ចគ្រួសារក៏ដូចសេដ្ឋកិច្ចជាតិ ដើម្បីឆ្លើយតបបានទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ។

ចំពោះឃុំត្បែងបច្ចុប្បន្នមាន ស្ទឹង និងស្រះ ដែលមានទំហំផ្ទៃដីសរុបចំនួន ៦៥៣,៦៤ហិកតា ស្មើនឹង ៤,៦២ ភាគរយ នៃផ្ទៃដីឃុំទាំងមូល។ នាពេលអនាគត ស្ថានភាពដីក្នុងឃុំត្បែង មិនមានអំណោយផលសមស្របដល់ការរៀបចំអាងស្តុកទឹកបន្ថែម ដើម្បីបំពេញតម្រូវការដល់ការស្រោចស្រព ដែលនាំឱ្យឃុំមិនមានតម្រូវការដីបន្ថែម សម្រាប់ប្រភពធនធានទឹកនោះទេ ។

ង.ហេដ្ឋារចនាសម្ព័ន្ធសង្គម និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត

ង.១.វិស័យអប់រំ

កុមារគ្រប់រូបមានសិទ្ធិរៀនសូត្រ មិនថាពួកគេស្ថិតនៅក្នុងកាលៈទេសៈបែបណានោះឡើយ។ ការផ្តល់ការគាំទ្រគ្រប់គ្រាន់ដល់ការរៀនសូត្ររបស់កុមារ មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីឱ្យពួកគេអាចអភិវឌ្ឍខ្លួនឈានទៅសម្រេចបានសក្តានុពលរបស់ពួកគេ។ យ៉ាងណាមិញនៅក្នុងឃុំត្បែងទៅថ្ងៃអនាគតក្នុងរយៈពេល១៥ឆ្នាំទៅមុខនឹងមានការកើនឡើងនូវចំនួនកុមារ និងមនុស្សវ័យជំទង់ក្នុងវ័យសិក្សា ដូចមានការគណនានៅក្នុងចំណុច ២.១.២ ស្តីពីចំណោលប្រជាសាស្ត្រខាងលើ ដែលចាំបាច់ត្រូវគិតគូរដោះស្រាយបន្ទប់រៀនបន្ថែមនៅគ្រប់កម្រិតនៅតាមទីតាំងសាលារៀន ដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ន។

- **មត្តេយ្យសិក្សា:**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ កុមារមានអាយុពី៥ឆ្នាំ នឹងកើនឡើងចំនួនៈ ២ ៣១៨ នាក់

-តាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ បានឱ្យដឹងពីការកំណត់សម្រាប់មត្តេយ្យសាលាក្នុងមួយថ្នាក់មានចំណុះកុមារសិក្សារៀនសូត្រ ៥០ នាក់

-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់មត្តេយ្យត្រូវការបន្ថែមចំនួនៈ

២ ៣១៨ នាក់ /៥០ នាក់/បន្ទប់= ៤៦ បន្ទប់

-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ

៤៦ បន្ទប់ / ៥ បន្ទប់/អគារ= ៩ អគារ

❖ **បឋមសិក្សា**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ៦-១១ ឆ្នាំនឹងកើនឡើងចំនួនៈ ៤៣១៨នាក់

-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់បឋមសិក្សាត្រូវការបន្ថែមចំនួនៈ

៤៣១៨នាក់ ៖ ៤៥នាក់/បន្ទប់ = ៩៦ បន្ទប់

-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៦ បន្ទប់បន្ថែមចំនួនៈ

៩៦ បន្ទប់ ៖ ៦ បន្ទប់/អគារ = ១៦ អគារ

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សារតែចំនួនៈ

១៦អគារ/វេន ៖ ២ វេន = ៨ អគារ

❖ **អនុវិទ្យាល័យ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ១២-១៤ ឆ្នាំនឹងកើនឡើងចំនួនៈ ១ ៦៥៧ នាក់

-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់អនុវិទ្យាល័យសិក្សាត្រូវការបន្ថែមចំនួនៈ

១ ៦៥៧ នាក់ ៖ ៤៥នាក់/បន្ទប់ = ៣៧ បន្ទប់

-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ

៣៧ បន្ទប់ ៖ ១២ បន្ទប់/អគារ = ៣ អគារ

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សារតែចំនួនៈ

៣ អគារ / វេន ៖ ២ វេន = ១,៥ អគារ

❖ **វិទ្យាល័យ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ១៥-១៧ឆ្នាំនឹងកើនឡើងចំនួនៈ ១ ៦៩០ នាក់

-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់អនុវិទ្យាល័យសិក្សាត្រូវការបន្ថែមចំនួនៈ

១ ៦៩០ នាក់ ៖ ៤៥ នាក់/បន្ទប់ = ៣៨ បន្ទប់

-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ

៣៨ បន្ទប់ ៖ ១២ បន្ទប់/អគារ = ៣ អគារ

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សារតែចំនួនៈ

៣ អគារ / វេន ៖ ២ វេន = ១,៥ អគារ

តារាង 35៖ កំណើនកុមារ តម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១៨ ដល់ឆ្នាំ ២០៣២

បរិយាយ	បច្ចុប្បន្ន២០១៧	អនាគត ២០៣២	បម្រែបម្រួល
សាលាមត្តេយ្យ			
សិស្ស	២៥៥នាក់	២ ៣១៨ នាក់	២០៦៣ នាក់
បន្ទប់	៦ បន្ទប់	៤៦ បន្ទប់	៤០ បន្ទប់
អគារ	៦ អគារ	៩ អគារ	៣ អគារ
សាលាបឋមសិក្សា			
សិស្ស	២២៩៩នាក់	៤ ៣១៨ នាក់	២ ០១៩ នាក់

បន្ទប់	៨៩ បន្ទប់	៩៦ បន្ទប់	៧ បន្ទប់
អគារ	១២ អគារ	១៦ អគារ	៤ អគារ
អនុវិទ្យាល័យ			
សិស្ស	៥៥៥នាក់	១ ៦៥៧ នាក់	១១០២ នាក់
បន្ទប់	១៥ បន្ទប់	៣៧ បន្ទប់	២២ បន្ទប់
អគារ	១អគារ	៣ អគារ	២ អគារ
វិទ្យាល័យ			
សិស្ស	៥៨៧ នាក់	១ ៦៩០ នាក់	១១០៣ នាក់
បន្ទប់	១៥ បន្ទប់	៣៨ បន្ទប់	២៣ បន្ទប់
អគារ	១ អគារ	៣ អគារ	២ អគារ

ង.២.សម្រាប់វិស័យសុខាភិបាល

យោងទៅតាមការស្រាវជ្រាវរកឃើញដែលបានរៀបរាប់នៅក្នុងជំពូកទី១ នៃរបាយការណ៍នេះបានឱ្យដឹងថា នៅក្នុងឃុំត្បែងមានមណ្ឌលសុខភាពមួយកន្លែង ស្ថិតក្នុងភូមិព្រៃប្រស់ ឃុំត្រពាំងឫស្សី ដែលទៅថ្ងៃអនាគត១៥ ឆ្នាំទៅមុខនឹងមានតម្រូវការដី សម្រាប់រៀបចំទីតាំងផ្តល់សេវាកម្មសុខាភិបាលបន្ថែមមួយកន្លែង នៅក្នុងភូមិតារាម ដោយសារមណ្ឌលសុខភាព ដែលមានបច្ចុប្បន្ននេះ ស្ថិតនៅក្នុងដែនឃុំត្រពាំងឫស្សី និងមានចម្ងាយឆ្ងាយពីភូមិមួយចំនួន។

ង.៣.អគ្គិសនី

អគ្គិសនី គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ជីវិតរស់នៅរបស់មនុស្សយើង។ អគ្គិសនីផ្តល់ឱ្យយើងនូវសន្តិសុខ សុវត្ថិភាព សុខភាព និងភាពសម្បូររុងរឿង ដូចជា ជួយដោះស្រាយបញ្ហា និងធ្វើឱ្យកាន់តែប្រសើរឡើងនូវសន្តិសុខ សុវត្ថិភាព ការប្រែប្រួលអាកាសធាតុ ផលិតកម្មស្បៀងអាហារ និងការពង្រឹងសេដ្ឋកិច្ចដោយរួមទាំងការអប់រំ និងកម្សាន្តផងដែរ។

យោងទៅតាមទិន្នន័យពីមន្ទីរផែនការនៅក្នុងឆ្នាំ២០១៧ បានបង្ហាញឱ្យឃើញថា នៅក្នុងឃុំត្បែងប្រជាពលរដ្ឋប្រើប្រាស់បណ្តាញអគ្គិសនី មានចំនួន ៤៣០ ខ្នងផ្ទះ ស្មើនឹង ១៦,៤ ភាគរយ អាគុយចំនួន ១ ៤៣២ ខ្នងផ្ទះ ស្មើនឹង ៥៤,៧ ភាគរយ បន្ទះសូឡាចំនួន ៣៦៥ ខ្នងផ្ទះ ស្មើនឹង ១៣,៩ ភាគរយ ។ ដូច្នេះនៅពេលអនាគត១៥ឆ្នាំទៅមុខនឹងមានការកើនឡើងចំនួនគ្រួសារថែមទៀត អាជ្ញាធរពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ជាពិសេសក្រុមប្រឹក្សាឃុំត្បែង ត្រូវខិតខំយកចិត្តទុកដាក់ នៅក្នុងការដោះស្រាយពង្រីកបណ្តាញអគ្គិសនី តភ្ជាប់ផ្គត់ផ្គង់ឱ្យទៅដល់គ្រប់គ្រួសារ បានប្រើប្រាស់។

ង.៤.ទីលានចាក់សំរាម

សំរាម គឺជាកាកសំណល់ដែលគេបានបោះបង់ចោល វាមានពីរប្រភេទ គឺកាកសំណល់រឹង និងរាវ។ ដូច្នេះសំរាម គឺជាអ្វីដែលបំបែកចេញពីបរិស្ថានយើង និងអាចបង្កើតកន្លែងគរមួយផ្សេងទៀត ប្រសិនបើយើងមិនប្រុងប្រយ័ត្ន។ គំនរសំរាម បានមកពីកាកសំណល់ផ្ទះបាយ ដែលដាក់លាយឡំចូលគ្នាជាមួយនឹង អំបែងកែវ អំបែងចាន និងអំបែងដបជាដើម។ នៅពេលមានភ្លៀងធ្លាក់ចុះមក គឺដូចជាការចម្រោះជាតិពុល គ្រប់បែបយ៉ាង

ឱ្យហូរជ្រាបទៅបំពុលដី បំពុលទឹក និងបំពុលដល់ប្រភពទឹកនៅក្នុងស្រទាប់ដីខាងក្រោម ជាហេតុធ្វើឱ្យទឹកស្អាតក្លាយជាទឹកមិនស្អាត មានលោហៈធ្ងន់ និងជួនកាលមានបាក់តេរីកាចៗ នៅពេលនោះ បណ្តាលឱ្យលេចឡើងនូវជម្ងឺរាតត្បាតផ្សេងៗដោយសារតែការទទួលទានទឹកមិនស្អាត។

ចំពោះសំរាមនៅក្នុងឃុំត្បែងបច្ចុប្បន្ន ប្រជាពលរដ្ឋភាគច្រើនបោះចោលសំរាមនៅក្បែរផ្ទះ ខ្លះចោលរាយប៉ាយនៅតាមផ្លូវ ខ្លះដុតចោល ដែលធ្វើឱ្យរងការបំពុលពីផ្សែងដុត និងបាត់បង់សោភ័ណភាពក្នុងភូមិ ឃុំ។ ដើម្បីអាចគ្រប់គ្រងសំរាមបានឃុំត្រូវរកទីតាំងនៅក្នុងឃុំ ដែលនៅដាច់ដោយឡែកឆ្ងាយពីភូមិធ្វើទីលានចាក់សំរាមមួយកន្លែង ដើម្បីប្រមូលសំរាមដែលមាននៅក្នុងឃុំទៅរក្សាទុកឱ្យបានគត់មត់ ឬត្រូវប្រមូលសំរាមប្លាស្ទិកយកទៅកែច្នៃផលិតឡើងវិញ ចំណែកសំរាមពីផ្ទះបាយ និងស្លឹកឈើផ្សេងពីប្លាស្ទិក អាចកែច្នៃធ្វើជីដូចជាជីកំប៉ុស្តជាដើម ដើម្បីប្រើប្រាស់ក្នុងការបង្កើនគុណភាពដីដាំដុះ។ ជារួមសំខាន់ជាងគេបំផុត គឺត្រូវលុបបំបាត់សំរាមប្លាស្ទិកឱ្យអស់ពីភូមិ ឃុំ។

ង.៥.ដីកប់ខ្មោច

ជាទូទៅពិធីបូជាសព មានពីប្រភេទ គឺពិធីដុតសព និងកប់សពរក្សាក្នុងដី ក្នុងពិធីទាំងពីរនេះ គឺពីធីកប់សពត្រូវការប្រើប្រាស់ដី ដែលធ្វើឱ្យមានការបាត់បង់ដី សម្រាប់ប្រើប្រាស់បម្រើឱ្យការអភិវឌ្ឍនៅក្នុងសហគមន៍ ដែលមនុស្សរស់នៅ។ នៅក្នុងឃុំត្បែងបច្ចុប្បន្ន ក៏មានប្រើពិធីទាំងពីរនេះដែរ ចំណែកការប្រើប្រាស់ដីនៅក្នុងឃុំ ក៏មានតម្រូវការកាន់តែច្រើនឡើង ស្របទៅនឹងកំណើនប្រជាពលរដ្ឋទៅថ្ងៃអនាគត ដែលចាំបាច់អាជ្ញាធរដែនដីពាក់ព័ន្ធជាពិសេសក្រុមប្រឹក្សាឃុំត្បែង ត្រូវខិតខំយកចិត្តទុកដាក់គិតគូរពីពិធីបូជាសពនេះ ដែលនឹងកើតឡើងជាបន្តបន្ទាប់ដោយគួរខិតខំលប់បំបាត់ការបញ្ចុះសព ដោយកប់ក្នុងដី ហើយជំនួសមកវិញ ដោយការរៀបចំឱ្យមានកន្លែងបូជាសពនៅតាមវត្តអារាម ឬកន្លែងណាផ្សេងដាច់ឆ្ងាយពីភូមិ ដែលជាជម្រើសល្អបំផុត។

ង.៦.ស្រះ និងអណ្តូងទឹក

ទឹក គឺជាផ្នែកមួយនៃធាតុ ដ៏សំខាន់បំផុតសម្រាប់រាងកាយមនុស្សយើង ដែលជាពិសេសនោះ គឺសម្រាប់សុខភាព ដើម្បីធានាបាននូវការរស់រានមានជីវិតរបស់មនុស្ស ។ ទឹកអាចនឹងមាននៅគ្រប់ទីកន្លែង ប៉ុន្តែវាមិនអាចយកមកសម្រាប់ការទទួលទានបានទាំងអស់នោះទេ គឺត្រូវការទឹកដែលស្អាត។ នៅក្នុងឃុំត្បែងក្នុងបច្ចុប្បន្ននេះ មានការប្រើប្រាស់ទឹកស្អាត សម្រាប់ទទួលទានតាមរយៈការប្រើទឹកស្រះ និងអណ្តូង ដូចដែលបានរៀបរាប់ក្នុងជំពូកទី១នៃរបាយការណ៍នេះ ប៉ុន្តែបានរកឃើញថា ចំនួនស្រះទឹក និងអណ្តូងទឹកទាំងអស់នេះ មិនមានបរិមាណគ្រប់គ្រាន់សម្រាប់បំពេញតម្រូវរបស់មនុស្ស និងសត្វចិញ្ចឹមគ្រប់គ្រាន់នារដូវប្រាំងបានឡើយ។

ដូច្នេះដើម្បីឆ្លើយតបទៅនឹងការខ្វះខាតនាពេលបច្ចុប្បន្ន ក៏ដូចជាឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋនៅក្នុងរយៈពេល១៥ឆ្នាំខាងមុខបាន អាជ្ញាធរដែនដីពាក់ព័ន្ធ ជាពិសេសក្រុមប្រឹក្សាឃុំត្បែង ត្រូវយកចិត្តទុកដាក់លើកទឹកចិត្តឱ្យប្រជាពលរដ្ឋក្នុងឃុំត្រងទឹកភ្លៀងនៅរដូវវស្សា ដើម្បីរក្សាទុកក្នុងអាងស្តុកតាមផ្ទះរៀងៗខ្លួនសម្រាប់ទុកដោះស្រាយការប្រើប្រាស់នៅរដូវប្រាំង ដែលខ្សត់ទឹកហើយថែមពីលើនេះទៀត ក៏ត្រូវបំផុសឱ្យមានការរៀបចំជីកស្រះសហគមន៍ផងដែរ ព្រមទាំងជំរុញលើកទឹកចិត្តដល់វិស័យឯកជនឱ្យផលិតទឹកស្អាតតបណ្តាញឱ្យដល់គ្រប់ខ្នងផ្ទះប្រជាពលរដ្ឋបានប្រើប្រាស់គ្រប់ក្រុមគ្រួសារដែលជាជម្រើសដ៏ល្អបំផុត។

២.២.តំបន់សេរីប

តំបន់សេរីប ជាតំបន់ដែលទាមទារនូវការការពារបន្ថែម និងជាពិសេសដោយផ្អែកលើសារៈសំខាន់ឬជីវចម្រុះនៃបរិស្ថាន បេតិកភ័ណ្ឌវប្បធម៌ តម្លៃខាងផ្លូវចិត្ត ដែលមានលក្ខណៈ ដូចជា តំបន់ប្រពៃណីសម្រាប់ជនជាតិដើមភាគតិច ឬក៏មូលហេតុសំខាន់ៗផ្សេងទៀត។ តំបន់បង្ហាញបញ្ហាចោទ ចាំបាច់ត្រូវតែកំណត់ ដើម្បីជានាថាឃុំ/សង្កាត់ត្រូវការដឹងឮនូវតម្រូវការ និងប្រធានបទពិសេសទាំងនេះ។ នៅក្នុងឃុំត្បែង តំបន់សេរីបមានទួលបុរាណចំនួន ០២កន្លែង និងវត្តមានស្ថានីយបុរាណចំនួន ០៤កន្លែង ដែលទាមទារនូវកិច្ចការពារបន្ថែម ពិសេសដែរនោះដោយសារតែតំបន់នេះមានសារៈសំខាន់ផ្អែកវប្បធម៌ ប្រវត្តិសាស្ត្រ តាមរយៈការធ្វើកំណាយសិក្សាស្រាវជ្រាវស្វែងរកសំណល់ជាភស្តុតាងដែលនាំឱ្យដឹងពីប្រវត្តិសាស្ត្រពីយូរលង់មកហើយ។ តំបន់ដីព្រៃសហគមន៍ ដែលត្រូវទាមទារនូវកិច្ចការពារបន្ថែម និងជាពិសេសនោះ ដោយសារតំបន់នេះ ត្រូវថែរក្សាទុកស្របតាមច្បាប់ស្តីពីព្រៃឈើជាតំបន់សហគមន៍ព្រៃឈើ។ សហគមន៍នេសាទ ១កន្លែង ដែលទាមទារនូវកិច្ចការពារបន្ថែម ពិសេសនោះដោយសារតំបន់នេះមានសារៈសំខាន់ដល់ជម្រកមច្ឆាជាតិ និងជីវចម្រុះផ្សេងៗទៀត ព្រមទាំងតំបន់ដីសង្ស័យថាមានមីន ដែលត្រូវទាមទារនូវកិច្ចការពារបន្ថែមពិសេសដើម្បីធ្វើការហាមឃាត់ប្រជាពលរដ្ឋចូលទៅតំបន់នេះ ដែលនាំឱ្យពួកគាត់មានគ្រោះថ្នាក់ពីគ្រាប់មីន ដែលមិនទាន់ផ្ទុះ។ តំបន់សេរីបដែលមាននៅក្នុងឃុំត្បែង ដូចបានរៀបរាប់ខាងលើមានបង្ហាញនៅក្នុងផែនទីតំបន់សេរីបខាងក្រោម។

ផែនទី 10៖ តំបន់សេរីបឃុំត្បែង



២.៣.ការប្រឈម

២.៣.១.ការប្រឈមដោយធម្មជាតិ

ក.កំណើនប្រជាជន

បច្ចុប្បន្ននៅក្នុងឃុំត្បែង បានរកឃើញថាប្រជាពលរដ្ឋបានកើនឡើងតាមធម្មជាតិជារៀងរាល់ឆ្នាំដែលគិតជាមធ្យមប្រមាណ ២,២០ ភាគរយ ហើយទៅថ្ងៃអនាគតត្រឹមឆ្នាំ ២០៣២ បញ្ហាកំណើនប្រជាជន ត្រូវបានធ្វើការគិតគូរដោះស្រាយដោយពុំមានបញ្ហាប្រឈមធ្ងន់ធ្ងរឡើយ តែបន្តពីនេះទៅមុខវែងឆ្ងាយនឹងអាចកើតមានបញ្ហាប្រឈមដែលត្រូវបន្តដោះស្រាយមួយចំនួនដូចខាងក្រោម៖

-មានការខ្វះខាតដីលំនៅឋាន ដែលនាំឱ្យមានការដោះស្រាយផលប៉ះពាល់ទៅដល់ដីស្រែ។

-មានការខ្វះខាតដីស្រែ ដែលនាំឱ្យពិបាកក្នុងការដោះស្រាយ ដោយសារតែនៅក្នុងឃុំ ពុំមានដីសល់ទំនេរសម្រាប់បំពេញការខ្វះខាតនេះ។

-មានការខ្វះខាតដល់ការផ្តល់សេវាអប់រំ ដែលត្រូវដោះស្រាយដូចជាការសាងសង់សាលារៀន គ្រូបង្រៀន និងសម្ភារៈសិក្សាបន្ថែម។

-មានការខ្វះខាតសេវាសុខាភិបាល ដែលត្រូវដោះស្រាយដូចជា គ្រូពេទ្យ ឧបករណ៍ និងសម្ភារៈបរិក្ខាពេទ្យ និងថ្នាំដង្កូវបន្ថែម។

-មានការខ្វះខាតទឹកស្អាត អគ្គិសនី ដែលត្រូវដោះស្រាយ សម្រាប់ការផ្គត់ផ្គង់បន្ថែម។

ខ.គ្រោះធម្មជាតិ ការរេចរឹលនៃធម្មជាតិ

បច្ចុប្បន្ននៅក្នុងឃុំត្បែង គេបានកត់សម្គាល់ឃើញថា មានជួបប្រទះនូវគ្រោះធម្មជាតិ កើតឡើងស្ទើរតែរៀងរាល់ឆ្នាំ មានដូចជា គ្រោះរាំងស្ងួត ទឹកជំនន់ជាដើម។ ទន្ទឹមនឹងនេះ ដីធ្លីដែលជាធនធានធម្មជាតិកម្រនៅក្នុងឃុំត្បែង ក៏មានភាពរេចរឹលទៅៗផងដែរ ដូចជាធ្វើឱ្យដីស្រែរឹង និងខ្សោះជីជាតិ ដោយសារតែការប្រើប្រាស់ជីគីមី និងថ្នាំគីមីសម្លាប់សត្វល្អិតនៅលើដំណាំស្រូវ និងដំណាំដទៃទៀត មិនស្របតាមបទដ្ឋានបច្ចេកទេស ព្រមទាំងមានការថយចុះ និងបាត់បង់ធនធានជលផល ជាពិសេសនោះមច្ឆាជាតិ ដោយសារការនេសាទខុសច្បាប់ មានដូចជាការប្រើប្រាស់ឧបករណ៍ឆក់ នេសាទនៅរដូវបិទនេសាទជាដើម។ ទៅថ្ងៃអនាគត ប្រជាពលរដ្ឋនៅក្នុងឃុំនៅតែបន្តជួបប្រទះនូវបញ្ហាប្រឈមទាំងអស់នេះជាដដែល បើសិនជាមិនមានយន្តការឬដំណោះស្រាយ ដើម្បីទប់ទល់ទៅនឹងគ្រោះរាំងស្ងួត ព្រមទាំងមិនមានការកែប្រែតវិយាបថក្នុងការប្រើប្រាស់ដី សម្រាប់កសិកម្មឱ្យបានសមស្របទេនោះ។

២.៣.២.ការប្រឈមដោយ ការអភិវឌ្ឍដែលពុំមាននិរន្តរភាព

ជាការពិតណាស់រាល់គម្រោងអភិវឌ្ឍនានា ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានធម្មជាតិ ជាពិសេសការប្រើប្រាស់ដីក្នុងទីតាំងភូមិសាស្ត្រណាមួយ តែងនាំមកការរីកចម្រើនជានិច្ច តែផ្ទុយទៅវិញ បើសិនគម្រោងអភិវឌ្ឍទាំងនោះពុំទាន់បានគិតគូរគ្រប់ជ្រុងជ្រោយទៅដល់ទីតាំងភូមិសាស្ត្រនីមួយៗ និងសក្តានុពលនៃធនធាន ដែលមានវានឹងនាំមកនូវផលប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ច សង្គម និងបរិស្ថាននាពេលអនាគត ដោយមិនអាចធានាចីរភាពនៃគម្រោងទាំងនោះ ទៅដល់កូនចៅជំនាន់ក្រោយ នៅក្នុងតំបន់នោះបានឡើយ ដូចជាស្ថានភាពនៅក្នុងឃុំត្បែង ដែលជាឃុំគោលដៅសិក្សារៀបចំផែនការប្រើប្រាស់ដី ដូចដែលបានរៀបរាប់នៅក្នុងជំពូកទី១ខាងលើនៃរបាយការណ៍នេះ បានឱ្យដឹងថា នៅក្នុងឃុំត្បែង មានស្ថានភាពភូមិសាស្ត្រ ជាវាលទំនាប ដែលមានធនធាន

ដីអំណោយផលដល់ដំណាំស្រូវ និងដំណាំចម្ការ ដែលជាសក្តានុពលដល់ការអភិវឌ្ឍដល់ឃុំនេះ ដោយមិនមានការអះអាងណាផ្សេងក្រៅពីនេះនៅឡើយ។ ដូចនេះសម្រាប់ឃុំត្បែង គួរជៀសវាងដាច់ខាតនៅគម្រោងអភិវឌ្ឍទាំងឡាយណា ដែលនាំឱ្យមានផលប៉ះពាល់ដល់ការបាត់បង់ដីស្រែចម្ការ ដែលខ្លួនមាន ធ្វើឱ្យឃុំមានការថយចុះឱកាសអភិវឌ្ឍ ដូចជាគម្រោងចាក់លុបដីស្រែ ដីចម្ការបង្កកទុកលក់ ឬពុះដីឡូតិ៍លក់ ដើម្បីកេងផលចំណេញពីឈ្នួញ និងគម្រោងជីកយកអាចម៍ដីយកលក់ជាដើម។ លើកលែងតែគម្រោងណាពាក់ព័ន្ធ ដែលធ្វើឱ្យប្រសើរឡើងដល់ប្រព័ន្ធកសិកម្ម ដូចជាកសិដ្ឋានផលិតពូជស្រូវ ពូជដំណាំ ស្រែគម្រូផលិតជីធម្មជាតិ ទុកដាក់គ្រឿងយន្តកសិកម្ម ទន្ទឹមនិងនេះក៏នៅមានគម្រោងអភិវឌ្ឍប៉ះពាល់ដល់ការរស់នៅ និងបរិស្ថាន ដែលគួរចៀសវាងផងដែរ ដូចជាគម្រោងបង្កើតសិប្បកម្ម ឧស្សាហកម្ម ដែលធ្វើឱ្យមានការបង្ហូរទឹកស្អុយកខ្វក់ជាដើម។ល។ ទន្ទឹមនឹងនេះការប្រឈមដោយការអភិវឌ្ឍខាងលើ ដែលត្រូវចៀសវាងក៏នៅមានការប្រឈមទៅនិងអំពើអនាធិបតេយ្យ ដែលកើតឡើងពីការដោះស្រាយការខ្វះខាតរបស់ប្រជាពលរដ្ឋនៅក្នុងឃុំផងដែរ ដូចជា ការសាងសង់ផ្ទះស្នាក់នៅលើដីនៅតាមមាត់ប្រឡាយ តាមចិញ្ចើមផ្លូវសាធារណៈ ការទន្ទ្រានដីព្រៃ ធ្វើស្រែបំពានទៅលើប្រឡាយ និងបឹងជាដើម។

២.៤.ឱកាស

២.៤.១.ដោយអំណោយផលពីធម្មជាតិ

នៅលើលោកយើងនេះ ធម្មជាតិ គឺពិតជាបានផ្តល់នូវធនធានដ៏មានសារៈសំខាន់ សម្រាប់ធ្វើអ្វីៗគ្រប់យ៉ាងដែលមនុស្សចង់ធ្វើ ដូចជា មនុស្សបានប្រើប្រាស់ធនធានដី និងទឹកសម្រាប់ការដាំដុះ ឈើធ្វើឧសដុត សម្រាប់ផ្តល់កំដៅឬសាងសង់ទីជម្រក ខ្យល់អាកាស ត្បូងថ្ម ប្រេង ឧស្ម័នធម្មជាតិ និងរ៉ែជាវត្ថុធាតុដើមជាច្រើនទៀត ដូចជាដែកទង់ដែងជាដើម សម្រាប់ធ្វើឧបករណ៍ប្រើប្រាស់ផ្សេងៗ។ ចំណែកនៅក្នុងឃុំត្បែង យើងផ្តោតសំខាន់លើធនធានដីដែលមានសក្តានុពលលើសលប់លើការអភិវឌ្ឍឃុំ ដូចបានរកឃើញ និងរៀបរាប់ក្នុងជំពូក១ នៃរបាយការណ៍នេះ។ នៅក្នុងឃុំត្បែងមានស្ថានភាពអំណោយផលពីធម្មជាតិដូចខាងក្រោម៖

- ស្ថានភាពដី ជាវាលទំនាប ដែលអំណោយផលដល់ការដាំដុះដំណាំស្រូវ ព្រមទាំងទំនាបទាបនិងទំនាបខ្ពស់អំណោយផលដល់ការដាំដំណាំចម្ការជាពិសេសដំណាំឧស្សាហកម្ម។
- នៅជិតប្រភពស្ទឹង បឹង អូរ អាចមានលទ្ធភាពនាំទឹកមកស្រោចស្រពដំណាំស្រូវ និងដំណាំចម្ការ នៅពេលជួបប្រទះគ្រោះរាំងស្ងួត និងមានលទ្ធភាពនាំទឹកមកស្រោចស្រពបង្កើនរដូវធ្វើស្រែបានច្រើនដង។
- នៅរដូវវស្សាមានភ្លៀងធ្លាក់ច្រើនអាចស្រោចស្រពដំណាំស្រូវ និងដំណាំចម្ការបាន។
- អាកាសធាតុ ក្តៅ ហើយសើម អំណោយផលដល់ការលូតលាស់របស់រុក្ខជាតិ និងដំណាំគ្រប់ប្រភេទ។

២.៤.២.ដោយបច្ចេកវិទ្យាថ្មីៗ

ជីវិតរស់នៅ ដែលយើងកំពុងតែទទួលបានភាពប្រសើរឡើងនាពេលបច្ចុប្បន្ននេះ គឺដោយសារតែមានការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា។ បច្ចេកវិទ្យាថ្មីៗ ធ្វើឱ្យមានការផ្លាស់ប្តូរកាន់តែប្រសើរឡើង សម្រាប់ជីវិតរស់នៅរបស់ពលរដ្ឋ ដែលធ្វើឱ្យអ្វីៗនៅក្នុងពេលបច្ចុប្បន្នកាន់តែប្រសើរឡើង និងងាយស្រួលជាងមុន។ បច្ចេកវិទ្យាថ្មីអាចកាត់បន្ថយបាននូវពេលវេលា គុណភាព និងការចំណាយទៅលើកម្លាំងពលកម្មក្នុងផលិតកម្មនានា។

បច្ចុប្បន្ន ស្ថានភាពនៅក្នុងឃុំត្បែង គឺមានសក្តានុពលខ្លាំងដោយពឹងផ្អែកទៅលើផលិតកម្មដំណាំស្រូវ និងដំណាំឧស្សាហកម្ម ហើយនាពេលអនាគត ក៏នៅតែពឹងផ្អែកលើផលិតកម្មដំណាំទាំងនេះ ដដែលដែរនោះ

ប្រជាពលរដ្ឋនឹងចាំបាច់ត្រូវការបច្ចេកវិទ្យាទំនើបទាន់សម័យ សម្រាប់វិស័យកសិកម្មដំណាំស្រូវ និងចម្ការ ដើម្បីជួយជំរុញឱ្យមានការកើនឡើងទិន្នផលខ្ពស់ ដើម្បីអាចដោះស្រាយបាននូវសន្តិសុខស្បៀង និងមានប្រាក់ចំណូលកាន់តែខ្ពស់ ដែលនាំឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង នៅក្នុងពេល ដែលមានកំណើនប្រជាពលរដ្ឋកាន់តែខ្ពស់នាពេលខាងមុខ។ តាមរយៈបច្ចេកវិទ្យាថ្មីៗ នឹងនាំឱ្យប្រជាពលរដ្ឋនៅក្នុងឃុំមានឱកាសអាចប្រើប្រាស់គ្រឿងយន្តកសិកម្មទំនើបទាន់សម័យ សម្រាប់ការផលិតដំណាំស្រូវ ដែលរួមមានដូចជា ម៉ាស៊ីនភ្ជួររាស់ដី ម៉ាស៊ីនពង្រាបដីស្រែដោយប្រើប្រព័ន្ធឡាស៊ែរ ម៉ាស៊ីនដកស្ទូង ជ្រូនបាញ់ថ្នាំសម្លាប់សត្វល្អិត និងដាក់ជី ម៉ាស៊ីនច្រូតកាត់ និងបោកបែន ព្រមទាំងគ្រឿងយន្តដឹកជញ្ជូនជាដើម។ល។

២.៨.៣.ដោយគម្រោងវិនិយោគ

សម្រាប់នាពេលអនាគត នៅឃុំត្បែង ដែលមានសក្តានុពលខ្ពស់ទៅលើដំណាំស្រូវនោះ នឹងនាំឱ្យមានការផ្តួចផ្តើមបង្កើតគម្រោងវិនិយោគនានា ដែលភាគច្រើនផ្តោតទៅលើដំណាំស្រូវ និងដំណាំចម្ការ ដូចជាគម្រោងបង្កើតកសិដ្ឋានកសិកម្ម ដើម្បីជំរុញផលិតកម្មដំណាំស្រូវ និងដំណាំចម្ការ ព្រមទាំងគម្រោងវិនិយោគលើការកែច្នៃផលិតផលកសិកម្ម ដើម្បីនាំចេញដែលនឹងផ្តល់ការងារបន្ថែមទៀតទៅដល់ប្រជាពលរដ្ឋ ដើម្បីបង្កើនប្រាក់ចំណូលឱ្យបានកាន់តែខ្ពស់ ដែលអាចធ្វើឱ្យជីវភាពរស់នៅកាន់តែប្រសើរឡើង ព្រមទាំងកាត់បន្ថយបាននូវភាពក្រីក្រស្របទៅតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

២.៩.បញ្ហា មូលហេតុ នឹងដំណោះស្រាយ

ផ្អែកទៅតាមការរកឃើញ នៅក្នុងជំពូកទី១នៃរបាយការណ៍នេះ អាចឱ្យយើងធ្វើការវិភាគ និងចងក្រងបាននូវបញ្ហា ដែលកើតមាននៅក្នុងឃុំត្បែង។ មូលហេតុដែលនាំឱ្យកើតមានបញ្ហា និងដំណោះស្រាយលើបញ្ហាទាំងអស់នេះ គឺត្រូវបានបង្ហាញនៅក្នុងតារាង និងនៅក្នុងផែនទី ដូចមាននៅខាងក្រោមនេះ៖

តារាង 36៖ បញ្ហាប្រឈម និងសក្តានុពល(ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ)

បញ្ហា	ទីតាំងបញ្ហា	មូលហេតុ	ដំណោះស្រាយ
១.ខ្វះដីលំនៅឋាន (៦៥គ្រួសារ)	គ្រប់ភូមិ	ក-លក់សងបំណុល ខ-កំណើនគ្រួសារ	ក-ខ- ដោះស្រាយតាមរយៈដីសម្បទានសង្គមកិច្ច
២.ខ្វះដីកសិកម្ម (១៤០គ្រួសារ)	គ្រប់ភូមិ	ក-លក់សងបំណុល ខ-កំណើនគ្រួសារ គ-ដីកសិកម្មតិច	ក-ខ-គ-១-ស្នើសុំសម្បទានសង្គមកិច្ច ក-ខ-គ-២-ផ្តល់បច្ចេកទេសកសិកម្មទំនើបៗ
៣.ខ្វះទីលានចាក់សំរាម	ទូទាំងឃុំ	ក-ទុកដាក់សំរាមគ្មានសណ្តាប់ធ្នាប់ មិនមានទីតាំង សមរម្យ ខ-ចោលសំរាមលើដីសារធារណៈរបស់រដ្ឋ	ក-ខ-១-យល់ដឹងពីការបែងចែកសំរាម (ប្រភេទសំរាមនីមួយ) ក-ខ-២-ជំរុញឱ្យក្រុមហ៊ុនវិនិយោគ ក្នុងការប្រមូលសំរាមកែច្នៃ ក-ខ-៣-មន្ទីរ ឬក្រសួង ពាក់ព័ន្ធ និងក្រុមប្រឹក្សាឃុំគួរបង្កើតឱ្យមានទីលានទុកដាក់សំរាមក្នុងឃុំ
៤.គ្រាប់មីននៅ	ភូមិឈើទាល	ក-ជាកន្លែងសមភូមិ	ក-១-ដាក់សញ្ញាសម្គាល់ដីដែលមានមីន និង

សេសសល់ 	ភូមិបឹងអណ្តែង ភូមិអូរអំបែង ភូមិក្លង ភូមិពោធិ៍	ប្រយុទ្ធ	គ្រាប់មីន ទាន់ផ្ទុះ ក-២-ដាក់សំណើរទៅអង្គភាពកំចាត់ មីនឬអង្គការដើម្បី ជួយអន្តរាគមន៍
៥-ទិន្នផលស្រូវទាប 	ដីស្រែ	ក-ដីខ្វះជីជាតិ	ក-១-បណ្តុះបណ្តាលផលិតជីកំប៉ុស្ត ក-២-បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី ក-៣-ជំរុញការចិញ្ចឹមសត្វដើម្បីបានលាមក
		ខ-ខ្វះបច្ចេកទេសកសិកម្ម	ខ-១-បណ្តុះបណ្តាលពីបច្ចេកទេសផលិតពូជស្រូវ ខ-២-បណ្តុះបណ្តាលពីការដាំដំណាំស្រូវ ខ-៣-បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី ខ-៤-បណ្តុះបណ្តាលបច្ចេកទេសផលិតជីកំប៉ុស្ត ខ-៥-ប្រើប្រាស់ពូជស្រូវសុទ្ធល្អតាមស្តង់ដា
៦-ខ្វះទឹកស្រោចស្រព 	ដីស្រែ និង ចម្ការ	ក-ប្រព័ន្ធធារាសាស្ត្ររងការខូចខាត	ក-១-ស្តារប្រឡាយឡើងវិញ ក-២-ជួសជុល និងរៀបចំទ្វារទឹក
		ខ-ធ្វើស្រែក្នុងប្រឡាយ	ខ-១-ស្រង់ស្ថិតិអ្នកធ្វើស្រែក្នុងប្រឡាយ ខ-២-ផ្សព្វផ្សាយពីច្បាប់ភូមិបាល និងច្បាប់ពាក់ព័ន្ធនានា។ ខ-៣-រកវិធីដោះស្រាយនិងធ្វើកិច្ចសន្យាបញ្ឈប់
៧-ផ្លូវរងការខូចខាត ពិបាកធ្វើដំណើរ 	-ផ្លូវគ្រួសក្រហម ពីភូមិស្រង៉ែ ទៅភូមិតាអាំ -ផ្លូវគ្រួសក្រហម ពីភូមិអូរអំបែង ទៅភូមិក្លង -ផ្លូវលំដីសពីភូមិឈើទាល ទៅភូមិក្លង -ផ្លូវលំដីសពីភូមិអូរអំបែង ទៅភូមិត្បែងក	ក-ឡានធុនធ្ងន់ដឹកលើសទម្ងន់ឆ្លងកាត់	ក-១-ពង្រឹងការអនុវត្តន៍ច្បាប់ចរាចរណ៍ទប់ស្កាត់ឡានដឹកលើសទម្ងន់តាមរយៈដាក់សញ្ញាកំណត់ទម្ងន់ដឹកជញ្ជូនរបស់រថយន្ត ក-២-ដាក់បារាស់កាត់ផ្លូវដែលមានរថយន្តធំឆ្លងកាត់
		ខ-ខ្វះការថែទាំផ្លូវ	ខ-១- ថែទាំផ្លូវ ខួប ជាប្រចាំ ខ-២-បង្កើតគណៈកម្មការថែទាំផ្លូវ
៨-ធនធានមច្ឆាថយ		ក-នេសាទខុសច្បាប់	ក-១-ផ្សព្វផ្សាយច្បាប់ជលផល និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា

ចុះ និងបាត់បង់	ស្ទឹង		ក-២-ហាមឃាត់ការប្រើប្រាស់ឧបករណ៍ឆក់ខុសច្បាប់ ក-៣-ធ្វើវារីវប្បកម្ម
៩-ខ្វះទឹកស្អាតប្រើប្រាស់	ក្នុងឃុំ	ក-គ្មានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត	ក-១-យកចិត្តទុកដាក់ជំរុញឱ្យមានសេវាកម្មផ្គត់ផ្គង់ប្រព័ន្ធទឹកស្អាតបានដល់គ្រប់ភូមិ
		ខ-គ្រួសារមួយចំនួនខ្វះសម្ភារៈបរិក្ខារចម្រោះទឹកស្អាត	ខ-១-បំផុសឱ្យប្រជាពលរដ្ឋមានការប្រើប្រាស់ធុងចម្រោះទឹកស្អាត

ប្រភព៖ *សៀវភៅផែនការអភិវឌ្ឍ០៥ឆ្នាំ និងក្រុមប្រឹក្សាឃុំត្បែង ខែកញ្ញា ២០១៨*

ផែនទី 11៖ បញ្ហា មូលហេតុ និងដំណោះស្រាយ



ជំពូក ៣៖ ផែនការប្រើប្រាស់ដីសម្រាប់ពេលអនាគតឆ្នាំ២០១៧-២០៣២

៣.១.តម្រូវការ ស្ថានភាព និងសក្តានុពលដីជាក់ស្តែង

៣.១.១.តម្រូវការដីទៅតាមប្រភេទ

នៅពេលអនាគតរហូតទៅដល់ឆ្នាំ ២០៣២ នៅក្នុងឃុំត្បែង នឹងមានការកើនឡើងចំនួនប្រជាពលរដ្ឋ ៥៤១៥នាក់ ដែលត្រូវនឹងចំនួន ៩៤៨ គ្រួសារ ។ ដោយសារសន្ទុះនៃកំណើនប្រជាពលរដ្ឋនេះហើយ ដែលតម្រូវឱ្យមានការគិតគូរយកចិត្តទុកដាក់ដល់ការរកដីបន្ថែម សម្រាប់លំនៅឋាន និងដីស្រែជូនដល់ប្រជាពលរដ្ឋ ដែលមានចំនួនកើនឡើង ដើម្បីធានាឱ្យមាននិរន្តរភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំត្បែង ទៅថ្ងៃអនាគតបន្តពីពេលបច្ចុប្បន្ន ដូចបានរកឃើញនៅក្នុងជំពូក២ខាងលើ នៃរបាយការណ៍នេះ។ តែដោយសារទំហំផ្ទៃដី ដែលត្រូវបានប្រើប្រាស់បច្ចុប្បន្ននៅក្នុងឃុំ ពុំមានប្រែប្រួលកើនឡើង ស្របគ្នាទៅនឹងកំណើនប្រជាពលរដ្ឋ នាពេលអនាគតនោះជាដំណោះស្រាយ គឺសម្រាប់លំនៅឋាន ត្រូវប្រើប្រាស់ដីលំនៅឋានភូមិដែលមានស្រាប់ ពីព្រោះថាស្ថានភាពការតាំងលំនៅឋានក្នុងបច្ចុប្បន្ន មិនទាន់មានភាពចង្អៀតនោះទេ ដែលអាចមានលទ្ធភាពទ្រទ្រង់ដល់ការសាងសង់លំនៅឋានបន្ថែមទៀតបានសម្រាប់រយៈពេល១៥ឆ្នាំទៅមុខហើយម្យ៉ាងទៀតការតាំងលំនៅឋានមានលក្ខណៈប្រមូលផ្តុំវានឹងផ្តល់ភាពងាយស្រួលដល់ការផ្គត់ផ្គង់ទឹកស្អាត ភ្លើង និងសេវាសង្គមផ្សេងៗទៀត ដូចជា សេវាអប់រំ សេវាសុខភាពជាដើម។ល។

ដោយឡែកចំពោះដីស្រែវិញ ក៏មិនមានលទ្ធភាពពង្រីកបន្ថែមទៀតដែរ តែត្រូវបានថយចុះទំហំផ្ទៃដីមួយចំនួនថែមទៀត ដោយសារផ្ទៃដីស្រែវស្សា ដែលមានបច្ចុប្បន្ននេះមួយចំនួនស្ថិតនៅក្នុងគម្របព្រៃឈើឆ្នាំ២០០២ ដែលមានទំហំផ្ទៃដីចំនួន ៤៤៥,៨៣ហិកតា មិនត្រូវបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យទៅប្រជាពលរដ្ឋកាន់កាប់ និងអាស្រ័យផល ដោយមានការស្នើសុំពីអាជ្ញាធរដែនដីទេនោះ ផ្ទៃដីទាំងអស់នេះ នឹងត្រូវប្រើប្រាស់ជាដីគម្របព្រៃឈើឡើងវិញ។ ជាដំណោះស្រាយ ត្រូវតែគិតគូរពិចារណា ដោយយកចិត្តទុកដាក់លើការបង្កើនផលិតភាព គុណភាព និងពិពិធកម្មកសិកម្មដំណាំស្រូវ ដោយត្រូវធ្វើស្រែវស្សាបង្កើនរដូវឱ្យបាន២ដងនៅក្នុងមួយឆ្នាំ និងធ្វើស្រែតាមបែបប្រពលវប្បកម្ម ឱ្យស្របទៅតាមយុទ្ធសាស្ត្រអភិវឌ្ឍកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៃរាជរដ្ឋាភិបាលកម្ពុជា។

ចំពោះដីចម្ការវិញបច្ចុប្បន្ន មានទំហំផ្ទៃដីចំនួន ២៣៩១,១៣ ហិកតា ទៅថ្ងៃអនាគតនឹងត្រូវបានកំណត់ការប្រើប្រាស់តាមតម្រូវការទៅលើផ្ទៃដីចម្ការមានទំហំផ្ទៃដីសរុបចំនួន ៣០,០២ហិកតា ជាព្រៃដាំឡើងវិញ ដែលត្រូវមានកិច្ចការពារពិសេស។

៣.១.២.ស្ថានភាពនៃដីធ្លី និងសក្តានុពល

នៅពេលអនាគត ធនធានដីក្នុងឃុំត្បែង នៅតែរក្សាទំហំក្រឡាផ្ទៃសរុបចំនួន ១៤ ១៣៩,៣៧ ហិកតា ដដែល ដោយពុំមានការប្រែប្រួលឡើយ ហើយដីធ្លីទាំងនេះ នឹងត្រូវប្រើប្រាស់សម្រាប់ការសាងសង់លំនៅឋាន (រួមទាំងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន និងដំណាំជុំវិញលំនៅឋាន) ដីស្រែ (រួមទាំងប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន) ដីចម្ការដំណាំ ដីព្រៃឈើ ដីស្មឹង និងស្រះ ដូចទៅនឹងការប្រើប្រាស់ដីធ្លីបច្ចុប្បន្នដដែល ដោយពុំមានការប្រែប្រួលឡើយ ពីព្រោះដីធ្លី ដែលបានប្រើប្រាស់ក្នុងពេលបច្ចុប្បន្ននេះ បានសមស្របនិងចំសក្តានុពលនៃដីរួចហើយ។ ចំណែកទំហំផ្ទៃដីតំបន់ប្រើប្រាស់នីមួយៗ ដូចមានរៀបរាប់ក្នុងសេចក្តីអត្ថាធិប្បាយអំពីការបែងចែកដីតាមតម្រូវការប្រើប្រាស់ខាងក្រោមនេះ។ ជាទូទៅធនធានដីនៅក្នុងឃុំត្បែង មានសក្តានុពលខ្ពស់ សមស្របទៅលើ

កសិកម្មដំណាំស្រូវ និងចម្ការដំណាំ ដោយសារតែដីក្នុងឃុំមានទីតាំងភូមិសាស្ត្រ អំណោយផលពីធម្មជាតិ ដូចដែលបានរៀបរាប់ក្នុងជំពូកទី២ខាងលើ។ ដូច្នេះ ការប្រើប្រាស់ដីនាពេលបច្ចុប្បន្ន និងការសម្រេចចិត្តប្រើប្រាស់ដីទៅថ្ងៃអនាគតខាងមុខ នៅក្នុងឃុំ ដែលបានផ្តោតសំខាន់ទៅលើកសិកម្មដំណាំស្រូវ និងចម្ការជាចំបង គឺជាការប្រើប្រាស់បានត្រឹមត្រូវចំសក្តានុពល ហើយក៏ជាការគាប់ជួន ដែលភាពអំណោយផលពីធនធានដី នៅក្នុងឃុំសមស្របទៅលើវិស័យកសិកម្មដំណាំស្រូវ និងចម្ការនេះ ហើយក៏ស្របទៅនឹងគោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងតួនាទីវិស័យកសិកម្ម ក្នុងការបង្កើតការងារ ការធានាសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍជនបទ ដែលមានចែងនៅក្នុងមុំទី១ ចតុកោណទី៤ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា ដែលជាការផ្តល់ឱកាសដ៏ល្អដល់អាចអភិវឌ្ឍ នៅក្នុងមូលដ្ឋានរបស់ខ្លួនឱ្យឃុំមានការរីកចម្រើនបាន តាមរយៈការជំរុញធ្វើពិពិធកម្មកសិកម្មដំណាំស្រូវ នៅលើផ្ទៃដីកសិកម្មដ៏ធំល្វឹងល្វើយស្ទើរតែពេញដែនដីឃុំទាំងមូល។ ដើម្បីបង្កើនទិន្នផលស្រូវ និងដំណាំចម្ការ ដែលជាដំណាំដ៏មានសារៈសំខាន់សម្រាប់ជាស្បៀងផ្គត់ផ្គង់ការហូបចុកមិនអាចខ្វះបាន និងការនាំចេញទៅលក់នៅទីផ្សារ ដើម្បីបានចំណូលផ្គត់ផ្គង់តម្រូវការចាំបាច់ក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង រួមទាំងចូលរួមក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ តាមរយៈសកម្មភាពធ្វើពាណិជ្ជកម្មនាំអង្ករចេញ របស់រាជរដ្ឋាភិបាលកម្ពុជា។

ចំណែកដី ដែលមានទំហំតិចតួច ដែលបានកំណត់ ជាដីសម្រាប់ការសាងសង់លំនៅឋាន នៅលើដីខ្ពស់ជាប់តាមដងផ្លូវសំខាន់ៗ ដែលមិនលិចទឹកនៅរដូវវស្សា បានផ្តល់ភាពងាយស្រួលនៅក្នុងការធ្វើដំណើរចេញចូល និងងាយស្រួលក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត សម្រាប់បម្រើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋ នៅក្នុងឃុំបានប្រកបដោយជាសុកភាព ព្រមទាំងដី ដែលប្រើប្រាស់សម្រាប់ប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត គឺជាការប្រើប្រាស់បានត្រឹមត្រូវផងដែរ។

ស្ថានភាពដី ដែលត្រូវប្រើប្រាស់ទាំងនោះមានដីលំនៅឋាន និងដីកសិកម្មដំណាំស្រូវ ចម្ការ និងស្រះទឹកនៅខាងត្បូងផ្លូវជាតិលេខ៦ ជាកម្មសិទ្ធិរបស់ឯកជន។ ដីលំនៅឋាន និងដីកសិកម្មដំណាំស្រូវ និងចម្ការ នៅខាងជើងផ្លូវជាតិលេខ៦ភាគច្រើនស្ថិតនៅក្នុងតំបន់គម្របព្រៃឈើឆ្នាំ ២០០២ ជាដីសាធារណៈរបស់រដ្ឋ ត្រូវបានកាន់កាប់និងប្រើប្រាស់អាស្រ័យផលដោយប្រជាពលរដ្ឋ ចំណែកព្រៃល្បោះ ព្រៃដាំឡើងវិញ ស្ទឹង ប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធ គឺជាដីកម្មសិទ្ធិរបស់រដ្ឋ ដែលយើងទាំងអស់គ្នា ត្រូវតែធ្វើការការពារថែទាំឱ្យបានគង់វង្សសម្រាប់បម្រើឱ្យជាផលប្រយោជន៍សាធារណៈដោយមិនត្រូវរំលោភកាន់កាប់ដើម្បីប្រើប្រាស់បម្រើផលប្រយោជន៍បុគ្គលផ្ទាល់ខ្លួនបានឡើយ។

៣.២.ការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់

៣.២.១.ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ

ជាទូទៅរាល់ការកំណត់តំបន់ប្រើប្រាស់ដី ត្រូវបានផ្តោតសំខាន់លើមុខងារនៃការប្រើប្រាស់ដី សម្រាប់គោលបំណងផ្សេងៗ ដូចជា ផ្លូវ កសិកម្ម លំនៅឋាន ពាណិជ្ជកម្ម សួនកម្សាន្ត ព្រៃឈើ។ល។ ទន្ទឹមនឹងនោះការប្រើប្រាស់ដីតែងតែមានការផ្លាស់ប្តូរមុខងាររបស់វា តែការផ្លាស់ប្តូរមុខងារប្រើប្រាស់ដីទាំងនេះត្រូវតែគិតគូរពិចារណាឱ្យបានហ្មត់ចត់ ដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវទៅតាមស្ថានភាពច្បាប់ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ហើយត្រូវតែប្រាកដថា ដីដែលក្រោយពីបានប្តូរមុខងារប្រើប្រាស់ហើយនោះ ត្រូវតែមានតម្លៃសេដ្ឋកិច្ចឬផលប្រយោជន៍ខ្ពស់ជាងមុខងារប្រើប្រាស់ពីមុន តាមរយៈការរក្សាជំហរច្បាស់លាស់ ក្នុងការបង្កើនធនធានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ជាមួយនឹងផលប៉ះពាល់ដ៏តិចតួចបំផុតចំពោះមនុស្សជំនាន់ក្រោយ។

ឧទាហរណ៍៖ ដូចជាការផ្លាស់ប្តូរពីដីព្រៃឈើរេចរឹលទៅជាដីសម្រាប់កសិកម្ម ដែលវានឹងនាំឱ្យមានការបាត់បង់បរិមាណដីព្រៃឈើ ដែលផ្តល់ប្រយោជន៍ច្រើនយ៉ាងទៅដល់សហគមន៍មូលដ្ឋានតែជំនួសមកវិញដោយវាលស្រែសម្រាប់ផលិតកម្មស្រូវ ដែលជាចំណីអាហារដ៏សំខាន់ សម្រាប់ជីវិតរស់នៅមិនអាចខ្វះបាន ទាំងនេះជាការបង្ហាញឱ្យឃើញអំពីអន្តរអំពើរវាងមុខងារប្រើប្រាស់ដីមួយ ជាមួយមុខងារប្រើប្រាស់ដីមួយផ្សេងទៀត នៅលើទីតាំងដីដដែល។

យ៉ាងណាមិញ នៅក្នុងរយៈពេល១៥ឆ្នាំខាងមុខ រហូតទៅដល់ឆ្នាំ២០៣២ សម្រាប់ការប្រើប្រាស់ដីនៅក្នុងឃុំត្បែង គឺត្រូវបានគិតគូរយ៉ាងយកចិត្តទុកដាក់ ដើម្បីដោះស្រាយ និងឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋដូចដែលបានរៀបរាប់ខាងលើ ជាពិសេសនោះ គឺការដោះស្រាយការបែងចែកការប្រើប្រាស់ដីធ្លី ដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ តាមគោលការណ៍របស់រាជរដ្ឋាភិបាល និងដោយឈរលើស្មារតីនៅក្នុងការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន សម្រាប់ការប្រើប្រាស់ដីធ្លីនៅក្នុងរដ្ឋបាលឃុំ។ បញ្ហាដែលត្រូវដោះស្រាយខាងលើនេះ យើងសង្កេតឃើញថាមានការដោះស្រាយដី សម្រាប់តែការពង្រីកប្រព័ន្ធស្រោចស្រពនិងប្រព័ន្ធផ្លូវប៉ុណ្ណោះ ហើយការដោះស្រាយនេះត្រូវបានសម្រេចចិត្តកំណត់យកទៅលើដីស្រែ ទៅតាមទីតាំងដែលសមស្របអាចមានលទ្ធភាពនាំទឹកទៅស្រោចស្រព លើផ្ទៃដីស្រែបានគ្រប់គ្រាន់ ដែលនឹងនាំឱ្យមានការប្រែប្រួលពីបរិមាណផ្ទៃដីស្រែមួយភាគតូច ទៅជាដីសម្រាប់ការរៀបចំធ្វើប្រព័ន្ធប្រឡាយស្រោចស្រព គឺមានន័យថា៖ មានការថយចុះផ្ទៃដីស្រែ ដែលជាមូលដ្ឋានដ៏រឹងមាំនៃការអភិវឌ្ឍឃុំត្បែងធ្វើឱ្យមានការថយចុះផលិតផលស្រូវ ដែលនឹងនាំឱ្យមានការបាត់បង់ប្រាក់ចំណូល ប៉ះពាល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ តែបរិមាណផ្ទៃដីសម្រាប់ប្រព័ន្ធស្រោចស្រពមានការកើនឡើង ដែលជាតម្រូវការចាំបាច់ សម្រាប់ការដោះស្រាយនៅក្នុងការស្រោចស្រពដំណាំកសិកម្មមិនអាចខ្វះបាន ដើម្បីធានាចីរភាពនៃផលិតកម្មកសិកម្មសម្រាប់ការអភិវឌ្ឍឃុំ ។

តារាង 37៖តារាងប្រើប្រាស់ដីនាពេលអនាគត

ប្រភេទដីប្រើប្រាស់ដី	ផ្ទៃដីបច្ចុប្បន្ន (ហិកតា)	ផ្ទៃដី១៥ឆ្នាំក្រោយ (ហិកតា)	បម្រែបម្រួល (ហិកតា)
ក.ដីលំនៅឋាន ភូមិ	**៣៨៤,៧៦**	**៣៨៤,៧៦**	**0**
- ដីលំនៅឋានភូមិក្រៅតំបន់ការពារ	១៨៨,០៨	១៨៨,០៨	0
- ដីលំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប	១៩៥,៩២	១៩៥,៩២	0
- ដីលំនៅឋានភូមិក្នុងគម្របព្រៃឈើឆ្នាំ២០០២	0,៧៦	0,៧៦	0
ខ.ដីស្រែវស្សា	**៨២៥៦,៥**	**៨២៥៦,៥**	**0**
- ដីស្រែវស្សាក្រៅតំបន់ការពារ	៦៦៩៧,៦៧	៦៦៩៧,៦៧	0
- ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប	១១១៣	១១១៣	0
- ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ២០០២	៤៤៥,៨៣	៤៤៥,៨៣	0
គ.ដីស្រែប្រាំងនិងស្រែវស្សា	**២២៧៦,០៣**	**២២៧៦,០៣**	0
- ដីស្រែប្រាំងនិង ស្រែវស្សាក្នុងតំបន់១ ជុំវិញបឹងទន្លេសាប	១៧៤១,២៣	១៧៤១,២៣	0
- ដីស្រែប្រាំងនិង ស្រែវស្សាក្នុងតំបន់២ ជុំវិញបឹងទន្លេសាប	៥៣៤,៨០	៥៣៤,៨០	0

ឃ.ដីចម្ការ	**២៣៩១,១៣**	**២៣៦១,១១**	**-៣០,០២**
- ដីចម្ការក្រៅតំបន់ការពារ	១៤៦២,០៨	១៤៦២,០៨	0
- ដីចម្ការក្នុងតំបន់១ជុំវិញបឹងទន្លេសាប	៥,៧៥	៥,៧៥	0
- ដីចម្ការក្នុងគម្របព្រៃឈើឆ្នាំ២០០២	៩២៣,៣០	៨៩៣,២៨	-៣០,០២
ង.ព្រៃល្បោះ	**១៧៧,៣១**	**១៧៧,៣១**	**0**
ច.ព្រៃដាំឡើងវិញ	0	**៣០,០២**	**៣០,០២**
ឆ.ស្ទឹងមានទឹកតាមរដូវ	**៦៣១,០៥**	**៦៣១,០៥**	**0**
ជ.ស្រះ	**២២,៥៩**	**២២,៥៩**	0
- ស្រះក្រៅតំបន់ការពារ	១៤,០៩	១៤,០៩	0
- ស្រះក្នុងតំបន់១ជុំវិញបឹងទន្លេសាប	៨,៥០	៨,៥០	0
ក្រឡាផ្ទៃសរុបនៅក្នុងឃុំ	**១៤១៣៩,៣៧**	**១៤១៣៩,៣៧**	0

តារាង 38៖តារាងផែនការផ្នែកហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត

ប្រភេទហេដ្ឋារចនាសម្ព័ន្ធ	ប្រវែង/ចំនួន ឆ្នាំ២០១៧(ម)	ប្រវែង/ ចំនួន ១៥ឆ្នាំ(ម)	បំរែបំរួល(ម)
ផ្លូវក្រាលកៅស៊ូ	៧០១២,០០	៤៩៧៥៤,៦១	៤២៧៤២,៦១
ផ្លូវចាក់បេតុង	១៣៥៦,២២	១៣៥៦,២២	0
ផ្លូវក្រាលគ្រួសក្រហម	៤៨៣៩៨,២៦	៣៨៥១៥,២៩	៣២៨៥៩,៦៤
ផ្លូវលំដីសឬផ្លូវរទេះ	១១៨៨០៤,៥៨	៨៥៩៤៤,៤៤	៣២៨៥៩,៦៤
ប្រឡាយមេ	១៣៧៦៨,៣៨	១៣៧៦៨,៣៨	0
ប្រឡាយរង	៣៣៣៩,៦៨	៩៧០៤,៣៧	៦៣៦៤,៦៩
ប្រឡាយតូច	២៤២៤៦,៥៧	២៤២៤៦,៥៧	២៧០៣៥,៦១
ចំនួនស្ពានថ្ម/ប្រវែង	២កន្លែង	៣កន្លែង	១កន្លែង
ចំនួនទ្វារស្ទាក់ទឹក	១៨	៣៣	១៥
ចំនួនលូកាត់ផ្លូវ	២៩	១១៤	៨៥

តារាង 39៖ តារាងផែនការផ្នែកសេវាកម្មនាពេលអនាគត

ហេដ្ឋារចនាសម្ព័ន្ធ	ចំនួនក្នុងឆ្នាំ២០១៧	ចំនួនសម្រាប់១៥ឆ្នាំក្រោយ	បំរែបំរួល
សាលាមតេយ្យ	០៦អគារ ៦បន្ទប់	០៩អគារ ៤៦បន្ទប់	០៣អគារ ៤០ បន្ទប់
សាលាបឋមសិក្សា	១២អគារ ៨៩បន្ទប់	១៦ អគារ ៩៦ បន្ទប់	០១ អគារ ០៧ បន្ទប់
សាលាអនុវិទ្យាល័យ	០១ អគារ ១៥បន្ទប់	០៣ អគារ ៣៧ បន្ទប់	០២អគារ ២២ បន្ទប់
សាលាវិទ្យាល័យ	០១អគារ ១៥បន្ទប់	០៣អគារ ៣៨ បន្ទប់	០២អគារ ២៣បន្ទប់
មណ្ឌលសុខភាព	០១អគារ	០២អគារ	១អគារ

៣.២.២.ផែនទីប្រើប្រាស់ដីអនាគត

ការកំណត់ប្រភេទការប្រើប្រាស់ដី នាពេលអនាគតនៅក្នុងឃុំត្បែង គឺជាការសម្រេចចិត្តមួយដ៏ត្រឹមត្រូវបំផុត ដោយធ្វើការពឹងផ្អែកទាំងស្រុងទៅលើការវិភាគដីដ៏សមស្របមួយ តាមរយៈការវាយតម្លៃបែបសាមញ្ញ លើធនធានដី រយៈកម្ពស់ ទីជម្រាល ធនធានទឹក ការកាន់កាប់ដី និងសក្តានុពលនៃការប្រើប្រាស់ដីនៅក្នុងឃុំត្បែងនាពេលបច្ចុប្បន្ន ដោយយកផែនទីប្រើប្រាស់ដីធ្លីបច្ចុប្បន្ន ធ្វើជាមូលដ្ឋាន សម្រាប់នៅក្នុងការគិតគូរពិចារណាដូចមានរំលេចឱ្យឃើញ នៅក្នុងតារាងប្រើប្រាស់ដីពេលអនាគតខាងលើនេះ ព្រមទាំងនៅក្នុងផែនទីប្រើប្រាស់ដីនាពេលអនាគតដូចខាងក្រោមនេះ ដែលសមស្របអាចទទួលយកបាន និងអាចប្រើប្រាស់មានប្រសិទ្ធភាពតាមរយៈការបង្ហាញយ៉ាងពិស្តារពីជម្រើសដ៏ល្អសម្រាប់ការប្រើប្រាស់ដីនាពេលអនាគតរបស់ឃុំនេះ។ ទន្ទឹមនឹងនោះផែនទីប្រើប្រាស់ដីនាពេលអនាគតខាងក្រោម ក៏មានការអត្ថាធិប្បាយលម្អិតទៅលើតំបន់ប្រើប្រាស់ដីនីមួយៗ ដែលបានកំណត់នៅលើផែនទីនេះផងដែរ។

ផែនទី 12៖ ផែនទីប្រើប្រាស់ដីអនាគត



៣.២.៣.សេចក្តីអត្ថាធិប្បាយ

បើផ្អែកតាមផែនទីប្រើប្រាស់ដីអនាគតខាងលើ បានបង្ហាញឱ្យឃើញពីប្រភេទនៃការប្រើប្រាស់ដីនៅក្នុងឃុំត្បែង ដូចខាងក្រោម៖

ក.ដីលំដីលំនៅឋាន ភូមិ

ដីលំនៅឋានភូមិ គឺជាដីដែលត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានមានលាយសួនដំណាំ និងឈើហូបផ្លែនៅជុំវិញ។ នាពេលអនាគតដីលំនៅឋានភូមិនៅក្នុងឃុំត្បែង មានទំហំផ្ទៃដីសរុបចំនួន ៣៨៤,៧៦ហិកតា ដែលភាគច្រើនស្ថិតនៅតាមបណ្តោយជាប់ផ្លូវជាតិលេខ៦ ហើយមានចំនួនតិចតួចស្ថិតនៅភាគខាងជើង និងខាងត្បូងផ្លូវជាតិលេខ៦ ដែលក្នុងបច្ចុប្បន្ននេះត្រូវបានប្រើប្រាស់ជាដីលំនៅឋាន ភូមិ ដោយពុំមានការពង្រីកបន្ថែមសម្រាប់ការដោះស្រាយនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ ២០៣២ នោះឡើយ ដោយសារបច្ចុប្បន្នដីលំនៅឋាន នៅមានភាពទូលាយ ដែលត្រូវបានប្រើប្រាស់ទំហំដីប្រមាណជា ០,១៣ ហិកតា ក្នុងមួយគ្រួសារ អាចធ្វើការដោះស្រាយសម្រាប់ការសាងសង់លំនៅឋានរហូតដល់ឆ្នាំ ២០៣២ បាន ដោយនឹងត្រូវប្រើប្រាស់ទំហំដីថយចុះតិចតួចសល់ប្រមាណជា ០,១០ ហិកតា ក្នុងមួយគ្រួសារ។ ដីលំនៅឋានភូមិពឹងផ្អែកលើប្រភពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និងស្រោចស្រពដំណាំរួមផ្សំនៅជុំវិញលំនៅឋាន បានមកពីអណ្តូង ត្រពាំង និងស្រះទឹក ហើយត្រូវនាំទឹកមកប្រើប្រាស់ដោយម៉ូទ័របូម និងស្នប់សប់ដៃ។ នាពេលអនាគត ទីតាំងដីលំនៅឋាន ភូមិ ដែលមានស្រាប់នាពេលបច្ចុប្បន្ននេះនឹងត្រូវរក្សាទុកជាដីសម្រាប់សាងសង់លំនៅឋានដដែល ដោយសារតែទីតាំងដីទាំងនេះ មានស្ថានភាពជាដីខ្ពស់មិនលិចទឹកនៅរដូវវស្សានិងស្ថិតនៅជាប់ផ្លូវសំខាន់ៗនៅក្នុងឃុំងាយស្រួលក្នុងការចេញចូលប្រកបរបររកស៊ីរបស់ប្រជាពលរដ្ឋ សមស្របសម្រាប់ការតាំងលំនៅឋាននិងជាជម្រកដ៏កក់ក្តៅសម្រាប់ជីវិតរស់នៅរបស់ប្រជាពលរដ្ឋ។ ដីលំនៅឋាន ភូមិនាពេលអនាគត ស្ថិតនៅតាម ០៣ តំបន់ ផ្សេងគ្នា ដូចជា ក្រៅតំបន់ការពារ តំបន់១ ជុំវិញបឹងទន្លេសាប និងក្នុងគម្របព្រៃឈើឆ្នាំ ២០០២ ដូចខាងក្រោម៖

-ដីលំនៅឋានភូមិក្រៅតំបន់ការពារ

ដីលំនៅឋានភូមិក្រៅតំបន់ការពារមានទំហំផ្ទៃដីចំនួន ១៨៨,០៨ហិកតា ភាគច្រើនស្ថិតនៅភាគខាងជើងផ្លូវជាតិលេខ៦ ជាដីលំនៅឋាន ភូមិ ស្ថិតនៅក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប ដែលមានភូមិចំនួន ០៩ ដូចជា ភូមិឈើទាល ភូមិភ្លង ភូមិអូរអំបែង ភូមិតាអាំ ភូមិបឹងអណ្តែង ភូមិត្រាច ភូមិស្រង៉ៃ ភូមិត្បែង ក និងភូមិត្បែង ខ ព្រមទាំងភូមិចំនួន ០៤ ទៀត ស្ថិតនៅតាមបណ្តោយសងខាងជាប់ផ្លូវជាតិលេខ៦ ដែលមួយផ្នែកខាងជើងផ្លូវជាតិស្ថិតនៅក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប។ ដីលំនៅឋាន ភូមិទាំងអស់ ជាតំបន់ទំនាបខ្ពស់ មានប្រភេទដីខ្សាច់សុទ្ធពណ៌ស ដីខ្សាច់លាយពណ៌ប្រផេះ ដីកណ្តេង ដីពពាយកណ្តុរ និងដីឥដ្ឋពណ៌ប្រផេះខ្លាញ់ក្តាម ហើយជាដីដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ (ដីកម្មសិទ្ធិឯកជន) ។

-ដីលំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប

ដីលំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានទំហំផ្ទៃដីចំនួន ១៩៥,៩២ ហិកតា ស្ថិតនៅភាគខាងត្បូងផ្លូវជាតិលេខ៦ ចូលទៅក្នុងមានភូមិ ០២ គឺភូមិពោធិ៍ និងភូមិត្រាំខ្លា ។ ដីលំនៅឋាន ភូមិទាំងអស់ គឺជាតំបន់ទំនាបខ្ពស់ មានប្រភេទដីខ្សាច់សុទ្ធពណ៌ស ដីខ្សាច់លាយពណ៌ប្រផេះ ដីកណ្តេង ដីពពាយ កណ្តុរ និងដីឥដ្ឋពណ៌ប្រផេះខ្លាញ់ក្តាម ហើយជាដីដែលកាន់កាប់ដោយប្រជាពលរដ្ឋ (ដីកម្មសិទ្ធិឯកជន) ។

- ដីលំនៅឋានភូមិក្នុងគម្របព្រៃឈើឆ្នាំ២០០២

ដីលំនៅឋានភូមិក្នុងគម្របព្រៃឈើឆ្នាំ ២០០២ ស្ថិតនៅភាគខាងជើងនៃឃុំ នៅក្នុងភូមិឈើទាល ដែលមានទំហំផ្ទៃដីសរុបចំនួន ០,៧៦ ហិកតា។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំត្បែង នៃរបាយការណ៍វិភាគប្រព័ន្ធកេស្រ្ត-បរិស្ថាន ដីលំនៅឋានភូមិក្នុងគម្របព្រៃឈើឆ្នាំ ២០០២ គឺជាតំបន់ទំនាបមធ្យម មានប្រភេទដីខ្សាច់លាយឥដ្ឋពណ៌ប្រផេះ ។ ដីភូមិនេះ ស្ថិតនៅក្នុងគម្របព្រៃឈើឆ្នាំ២០០២ ជាដីសាធារណៈរបស់រដ្ឋ ដែលបច្ចុប្បន្នប្រជាពលរដ្ឋបានប្រើប្រាស់តាំងលំនៅឋានរស់នៅ ។

ខ.ដីស្រែវស្សា

ដីស្រែវស្សានៅក្នុងឃុំត្បែង នាពេលអនាគតមានទំហំផ្ទៃដីសរុបចំនួន ៨២៥៦,៥០ហិកតា ដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាដីស្រែវស្សា ដោយពុំមានការពង្រីកដីបន្ថែម សម្រាប់ការដោះស្រាយទៅនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២ នោះឡើយ។ ដីស្រែវស្សាទាំងនេះមានមួយផ្នែកនៅក្បែរៗជាប់នឹងដីលំនៅឋានភូមិ ក្រោយពីច្រូតកាត់ស្រូវរួច ប្រជាពលរដ្ឋនៅក្នុងឃុំតែងនាំគ្នាដាំដំណាំរួមផ្សំថែមទៀតរួមមានដូចជា ពោត សណ្តែក ឪឡឹក និងបន្លែគ្រប់មុខជាដើម។ នាពេលអនាគតទីតាំងដីទាំងអស់នេះនឹងត្រូវរក្សាទុកជាដីស្រែវស្សាដូចបច្ចុប្បន្នដដែល ដោយសារទីតាំងដីនេះមានស្ថានភាពជាដីទាបលិចទឹកនៅរដូវវស្សា សមស្របសម្រាប់ដំណាំស្រូវផ្តល់ផលិតផលផ្គត់ផ្គង់ដល់ការបរិភោគ សម្រាប់ជីវិតរស់នៅរបស់មនុស្ស និងនៅសល់លក់ទៅទីផ្សារនៅក្នុង និងក្រៅស្រុក ដើម្បីបង្កើនប្រាក់ចំណូលជាតិនិងគ្រួសារ។ ដីស្រែវស្សា នាពេលអនាគត ស្ថិតនៅតាម ០៣តំបន់ ផ្សេងគ្នាមានដូចជាៈ ក្រៅតំបន់ការពារ តំបន់១ ជុំវិញបឹងទន្លេសាប និងក្នុងគម្របព្រៃឈើឆ្នាំ ២០០២ ដូចខាងក្រោមៈ

-ដីស្រែវស្សាក្រៅតំបន់ការពារ

ដីស្រែវស្សាក្រៅតំបន់ការពារមានទំហំផ្ទៃដីសរុបចំនួន ៦ ៦៩៧,៦៧ ហិកតា ភាគច្រើនស្ថិតនៅខាងជើងផ្លូវជាតិលេខ៦ ។ ដីស្រែវស្សាទាំងនេះ ជាតំបន់ទំនាប មានប្រភេទដីខ្សាច់លាយឥដ្ឋពណ៌ប្រផេះ គឺជាដីកម្មសិទ្ធិឯកជន ដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ។ ដីស្រែទាំងនេះមានមួយផ្នែកនៅក្បែរៗជាប់នឹងដីលំនៅឋាន ភូមិ ក្រោយពីច្រូតកាត់ស្រូវរួចប្រជាពលរដ្ឋក្នុងនៅឃុំតែងនាំគ្នាដាំដំណាំរួមផ្សំថែមទៀតរួមមានដូចជា ពោត សណ្តែក ឪឡឹក និងបន្លែគ្រប់មុខជាដើម។ល។ ហើយដីទាំងនេះមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀងនិងស្ទឹងព្រៃប្រស់។

-ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប

ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីសរុបចំនួន ១ ១១៣ ហិកតា ស្ថិតនៅភាគខាងត្បូងផ្លូវជាតិលេខ៦។ ដីស្រែវស្សាទាំងនេះជាតំបន់ទំនាប មានប្រភេទដីខ្សាច់លាយឥដ្ឋពណ៌ប្រផេះ ជាដីកម្មសិទ្ធិឯកជនត្រូវបានកាន់កាប់ដោយប្រជាពលរដ្ឋ។ ដីស្រែនេះមានមួយផ្នែកនៅក្បែរៗជាប់នឹងដីលំនៅឋានភូមិ ក្រោយពីច្រូតកាត់ស្រូវរួច ប្រជាពលរដ្ឋនៅក្នុងឃុំតែងនាំគ្នាដាំដំណាំរួមផ្សំថែមទៀតរួមមានដូចជា ពោត សណ្តែក ឪឡឹក និងបន្លែគ្រប់មុខជាដើម។ ហើយដីទាំងនេះមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និងស្ទឹងព្រៃប្រស់។

- ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ២០០២

ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ ២០០២ មានទំហំផ្ទៃដីសរុបចំនួន ៤៤៥,៨៣ ហិកតា ដែលមានចំនួន ០៤ ទីតាំង ស្ថិតនៅភាគខាងជើងនៃឃុំ ក្នុងនោះមាន ០៣ ទីតាំង ស្ថិតនៅក្នុងភូមិឈើទាល និង ០១ ទីតាំង ទៀតស្ថិតនៅក្នុងភូមិក្លង។ ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ ២០០២ គឺជាតំបន់ទំនាបខ្ពស់ និងមធ្យម មានប្រភេទដីខ្សាច់សុទ្ធពណ៌ស និងដីខ្សាច់លាយពណ៌ប្រផេះ។ ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ ២០០២ ជាដីសាធារណៈរបស់រដ្ឋ ដែលបច្ចុប្បន្ននេះ ត្រូវបានប្រជាពលរដ្ឋប្រើប្រាស់ជាដីស្រែ ដែលមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និងស្ទឹងព្រៃប្រស់។

គ.ដីស្រែប្រាំងនិងស្រែវស្សា

ដីស្រែប្រាំងនិងស្រែវស្សានៅក្នុងឃុំត្បែងនាពេលអនាគត មានទំហំផ្ទៃដីសរុបចំនួន ២២៧៦,០៣ហិកតា ដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាដីស្រែប្រាំងនិងស្រែវស្សា ដោយពុំមានការពង្រីកបន្ថែមសម្រាប់ការដោះស្រាយទៅនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២នោះឡើយ។ នាពេលអនាគតទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីស្រែដូចបច្ចុប្បន្នដដែល ដោយសារទីតាំងដីនេះមានស្ថានភាពជាដីទាបលិចទឹកនៅរដូវវស្សា សមស្របសម្រាប់ដំណាំស្រូវផ្តល់ផលិតផលផ្គត់ផ្គង់ដល់ការបរិភោគសម្រាប់ជីវិតរស់របស់មនុស្ស និងនៅសល់លក់ទៅទីផ្សារក្នុងនិងក្រៅស្រុកដើម្បីបង្កើនប្រាក់ចំណូលជាតិ និងគ្រួសារ។ ដីស្រែវស្សា នាពេលអនាគតមានទីតាំងស្ថិតនៅតាមពីរតំបន់ផ្សេងគ្នាដូចខាងក្រោម៖

- ដីស្រែប្រាំង និងស្រែវស្សាក្នុងតំបន់១ ជុំវិញបឹងទន្លេសាប

ដីស្រែប្រាំងនិង ស្រែវស្សានៅក្នុងតំបន់១ជុំវិញបឹងទន្លេសាប មាននៅផ្នែកខាងត្បូងផ្លូវជាតិលេខ៦ ដែលលាតសន្ធឹងពីផ្លូវជាតិទៅភាគខាងត្បូងនៃឃុំស្របទៅនឹងស្ទឹងព្រៃប្រស់ និងមានផ្ទៃដីចំនួន ១៧៤១,២៣ហិកតា។ ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប ជាតំបន់ទំនាបលិចទឹកទន្លេសាប និងស្ទឹងព្រៃប្រស់ មានប្រភេទដីកណ្តោង ដីពពាយកណ្តុរ និងដីឥដ្ឋពណ៌ប្រផេះខ្លាញ់ក្តាម ហើយត្រូវបានកាន់កាប់ដោយប្រជាពលរដ្ឋ (ដីកម្មសិទ្ធិឯកជន)។ ដីស្រែប្រាំងនិង ស្រែវស្សានៅក្នុងតំបន់១ជុំវិញបឹងទន្លេសាបនេះ មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និងស្ទឹងព្រៃប្រស់ ។

- ដីស្រែប្រាំង និងស្រែវស្សាក្នុងតំបន់២ ជុំវិញបឹងទន្លេសាប

ដីស្រែប្រាំងនិង ស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប ស្ថិតនៅភាគខាងត្បូងនៃឃុំ ដែលមានទំហំផ្ទៃដីសរុបចំនួន ៥៣៤,៨០ ហិកតា ។ ដីស្រែប្រាំងនិងស្រែវស្សានេះ ជាតំបន់ទំនាបលិចទឹកបឹងទន្លេសាបមានប្រភេទដីកណ្តោង ដីពពាយកណ្តុរ និងដីឥដ្ឋពណ៌ប្រផេះខ្លាញ់ក្តាម ហើយជាដីសាធារណៈរបស់រដ្ឋ ប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមអាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ ។ ដីស្រែប្រាំងនិង ស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និងស្ទឹងព្រៃប្រស់។

ឃ.ដីចម្ការ

ដីចម្ការនៅក្នុងឃុំត្បែង នាពេលអនាគត មានទំហំផ្ទៃដីសរុបចំនួន ២ ៣៩១,១៣ ហិកតា ដែលនាពេលបច្ចុប្បន្ននេះ ត្រូវបានប្រើប្រាស់ជាដីចម្ការ ដោយពុំមានការពង្រីកបន្ថែម សម្រាប់ធ្វើការដោះស្រាយទៅនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២ នោះឡើយ ។ នាពេលអនាគតទីតាំងដីនេះ នឹងត្រូវរក្សាទុកជាដីចម្ការដូចបច្ចុប្បន្នដដែល ដោយសារទីតាំងដីនេះ មានស្ថានភាពដីទំនាបខ្ពស់សមស្រប សម្រាប់ដំណាំចម្ការផ្តល់ផលិតផលផ្គត់ផ្គង់ដល់លក់ទៅទីផ្សារនៅក្នុងនិងក្រៅស្រុក ដើម្បីបង្កើនប្រាក់ចំណូលជាតិ និងគ្រួសារ។ ដីចម្ការ នៅពេលអនាគតមានទីតាំងស្ថិតនៅតាមបីតំបន់ផ្សេងគ្នាដូចខាងក្រោម៖

-ដីចម្ការក្រៅតំបន់ការពារ

ដីចម្ការក្រៅតំបន់ការពារមានទំហំផ្ទៃដីសរុបចំនួន ១ ៤៦២,០៨ ហិកតា ស្ថិតនៅខាងជើងផ្លូវជាតិលេខ៦ ដីចម្ការទាំងនេះ ជាតំបន់ទំនាបខ្ពស់ មានប្រភេទដីខ្សាច់សុទ្ធពណ៌ស ដីខ្សាច់លាយឥដ្ឋពណ៌ប្រផេះ ជាដីកម្មសិទ្ធិឯកជន ដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ និងមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង។

-ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប

ដីចម្ការក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីចំនួន ៥,៧៥ ហិកតា ស្ថិតនៅភាគខាងត្បូងផ្លូវជាតិលេខ៦។ ដីចម្ការទាំងនេះ ជាតំបន់ទំនាបខ្ពស់ មានប្រភេទដីខ្សាច់សុទ្ធពណ៌ស និងដីខ្សាច់លាយឥដ្ឋពណ៌ប្រផេះ ហើយជាដីកម្មសិទ្ធិឯកជនដែលត្រូវបានកាន់កាប់ដោយប្រជាពលរដ្ឋ និងមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង។

-ដីចម្ការក្នុងគម្របព្រៃឈើឆ្នាំ២០០២

ដីចម្ការក្នុងគម្របព្រៃឈើឆ្នាំ ២០០២ មានទំហំផ្ទៃដីសរុបចំនួន ៩២៣,៣០ហិកតា ដែលមាន ៥ ទីតាំង ស្ថិតនៅភាគខាងជើងនៃឃុំក្នុងភូមិតាអាំ និងភូមិក្លូង ។ ដីចម្ការក្នុងគម្របព្រៃឈើឆ្នាំ ២០០២ ជាតំបន់ទំនាបខ្ពស់ និងមធ្យម ដែលមានប្រភេទដីខ្សាច់សុទ្ធពណ៌ស និងដីខ្សាច់លាយពណ៌ប្រផេះ ហើយជាដីសាធារណៈរបស់រដ្ឋ។ ដីចម្ការទាំងនេះ បច្ចុប្បន្នត្រូវបានប្រជាពលរដ្ឋកំពុងប្រើប្រាស់ជាដីចម្ការ ហើយភាគច្រើនជាដំណាំស្វាយចន្ទី និងមានតិចតួចជាដំណាំស្វាយកែវល្មៀត ព្រមទាំងទទួលបានប្រភពទឹកស្រោចស្រពតែពីទឹកភ្លៀងប៉ុណ្ណោះ ។

ង.ព្រៃល្បោះ

នាពេលអនាគតនៅក្នុងឃុំត្បែង មានដីព្រៃល្បោះចំនួន ០១ កន្លែង ស្ថិតនៅចុងភាគខាងជើងនៃឃុំជាប់ព្រំប្រទល់ឃុំនីពេជ្រ ដែលមានទំហំផ្ទៃដីសរុប ៧២៩,៦៧ ហិកតា ។ ដីព្រៃល្បោះនេះ គឺជាតំបន់ទំនាបខ្ពស់ មានប្រភេទដីខ្សាច់សុទ្ធពណ៌ស និងជាដីសាធារណៈរដ្ឋ ។ នាពេលអនាគត តំបន់នេះ នឹងត្រូវរក្សាទុកជាដីព្រៃល្បោះដដែល ដើម្បីផ្តល់ឈើសម្រាប់ប្រើប្រាស់ផ្សេងៗ រក្សាទុកដើមឈើកម្រ សម្រាប់មនុស្សជំនាន់ក្រោយ ធ្វើឱ្យដីក្នុងតំបន់នោះមានជីជាតិ ផ្តល់ឧស្ម័នអុកស៊ីសែនទៅមនុស្ស និងស្រូបយកឧស្ម័នកាបូនិក ជាជម្រកសត្វព្រៃ ជួយផ្តល់ខ្យល់អាកាសបរិសុទ្ធ ជួយទប់ទល់នឹងខ្យល់ព្យុះ ទឹកជំនន់ ជួយទាក់ទាញទឹកភ្លៀង និងរក្សាលំនឹងអាកាសធាតុ ។

ច.ព្រៃដាំឡើងវិញ

នាពេលអនាគត នៅក្នុងឃុំត្បែង មានព្រៃដាំឡើងវិញចំនួន ៣០,០២ ហិកតា ស្ថិតនៅចុងភាគខាងជើងនៃឃុំជាប់នឹងព្រំប្រទល់ឃុំនីពេជ្រក្នុងតំបន់ព្រៃល្បោះ។ ដីព្រៃដាំឡើងវិញ ជាតំបន់ទំនាបខ្ពស់ មានប្រភេទដីខ្សាច់សុទ្ធពណ៌ស ដែលជាដីសាធារណៈរដ្ឋ ។ នាពេលអនាគត ទីតាំងដីនេះ នឹងត្រូវធ្វើការដាំដើមឈើឡើងវិញ ដើម្បីផ្តល់ឈើសម្រាប់ប្រើប្រាស់ផ្សេងៗ រក្សាទុកដើមឈើកម្រ សម្រាប់មនុស្សជំនាន់ក្រោយ ធ្វើឱ្យដីនៅក្នុងតំបន់នោះមានជីជាតិ ផ្តល់ឧស្ម័នអុកស៊ីសែនទៅមនុស្ស ស្រូបយកឧស្ម័នកាបូនិក ជាជម្រកសត្វព្រៃ ជួយផ្តល់ខ្យល់អាកាសបរិសុទ្ធ ជួយទប់ទល់នឹងខ្យល់ព្យុះ និងទឹកជំនន់ ជួយទាក់ទាញទឹកភ្លៀង និងជួយរក្សាលំនឹងអាកាសធាតុ។ល។

ឆ.ស្ទឹង

ឃុំត្បែងមានស្ទឹងព្រៃប្រស់ ០១ខ្សែ ទំហំផ្ទៃដីសរុប ៦៣១,០៥ ហិកតា ជាដីសាធារណៈរបស់រដ្ឋ ដែលជាប្រភពទឹកដ៏សំខាន់សម្រាប់ស្រោចស្រពដំណាំស្រូវ និងដំណាំផ្សេងៗទៀត របស់ប្រជាពលរដ្ឋនៅក្នុងឃុំ ព្រមទាំងជាប្រភពធនធានជលផលផងដែរ។ ស្ទឹងនេះហូរកាត់តាមព្រំប្រទល់រវាងឃុំត្បែង និងឃុំត្រពាំងឫស្សីពីជើងទៅត្បូងចាក់ចូលទៅបឹងទន្លេសាប ដែលអាចផ្តល់ទឹកប្រើប្រាស់បានតែក្នុងរដូវវស្សាប៉ុណ្ណោះ។ នាពេលអនាគត ស្ទឹងនេះនឹងត្រូវការពារ និងថែរក្សាទុកប្រើប្រាស់ សម្រាប់ជាប្រភពទឹកស្រោចស្រពដំណាំកសិកម្ម និងប្រើប្រាស់ច្រើនយ៉ាងក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល ព្រមទាំងជាប្រភពធនធានជលផល សម្រាប់ជាអាហារផ្តល់ប្រូតេអ៊ីនជាប្រយោជន៍យ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ។

ជ.ស្រះ

នៅក្នុងឃុំត្បែង មានស្រះទឹកចំនួន ១៦កន្លែង ដែលនៅក្នុងនោះ ស្រះសហគមន៍ មានចំនួន ៣ កន្លែង គឺ ស្រះសហគមន៍វីឡឡៃត្បែង ស្រះសហគមន៍តារាម និងស្រះសហគមន៍ត្រាច ក្រៅពីនោះជាស្រះឯកជន ដែលភាគច្រើន ស្ថិតនៅលាយឡំជាមួយនឹងតំបន់លំនៅឋាន និងតំបន់ស្រែវស្សា ហើយត្រូវបានប្រើប្រាស់សម្រាប់ការបរិភោគ ស្រោចស្រពដំណាំផ្សេងៗនិងជាប្រភពធនធានជលផលផងដែរ ដែលមានផ្ទៃដីចំនួន ២២,៥៩ហិកតា។ នាពេលអនាគត ស្រះទឹកទាំងនេះនៅតែរក្សាទុកជាស្រះ ដែលជាប្រភពទឹកស្រោចស្រពនិងប្រើប្រាស់ច្រើនយ៉ាងក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល និងជាប្រភពធនធានជលផល ព្រមទាំងជាអាហារផ្តល់ប្រូតេអ៊ីន ជាប្រយោជន៍យ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ។

៣.៣.ដំណោះស្រាយផ្សេងៗ ក្នុងករណីខ្វះខាតដីធ្លី

ជាការពិតក្នុងពេលបច្ចុប្បន្ននេះ យើងបានរកឃើញថា នៅក្នុងឃុំត្បែងមានប្រជាពលរដ្ឋក្រីក្រ ខ្វះខាតដីលំនៅឋាន ភូមិចំនួន ៦៥គ្រួសារ និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារពិតប្រាកដចំនួន ១៤០គ្រួសារ ដូចបានអធិប្បាយនៅក្នុងជំពូកទី១ នៃរបាយការណ៍នេះ ដែលប្រជាពលរដ្ឋមួយចំនួនកំពុងរស់នៅលើដីចិញ្ចើមផ្លូវ ដីចំណីប្រឡាយ និងមួយចំនួនទៀតរស់នៅក្នុងខ្ទមលើដីរបស់អ្នកដទៃ ដែលពួកគាត់កំពុងស៊ីឈ្នួលធ្វើការឱ្យគេដើម្បីចិញ្ចឹមជីវិត។ ដូច្នេះ ដើម្បីដោះស្រាយដីសម្រាប់សង់លំនៅឋាន និងដីសម្រាប់កសិកម្មជាលក្ខណៈគ្រួសារដែលអាចផ្តល់ឱកាសឱ្យពួកគាត់មានជម្រកសម្រាប់រស់នៅសមរម្យនិងបង្កើតឱកាសការងារ ដើម្បីទទួលបានប្រាក់ចំណូលជូនពួកគាត់បាន អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ត្រូវខិតខំដោះស្រាយតាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ចនៅថ្នាក់ក្រោមជាតិ ដែលត្រូវផ្តួចផ្តើមឡើងដោយក្រុមប្រឹក្សាឃុំត្បែង។ ដីធ្លីដែលត្រូវដោះស្រាយជូនពួកគាត់ ដូចបានធ្វើការវិភាគដោះស្រាយនៅក្នុងជំពូក២ នៅត្រង់ចំណុច ២.១.៣ ខាងលើ គឺដីសម្រាប់លំនៅឋានមានទំហំ **១៦,២៥**ហិកតា និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារមានទំហំ **២៨០** ហិកតា។

៣.៤.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

និរន្តរភាពនៃការប្រើប្រាស់ដី គឺជាការធានាឱ្យបាននូវគោលដៅ និងអត្ថប្រយោជន៍នៃការប្រើប្រាស់ដីទាំងនោះ ដែលការធានាទាំងអស់នេះ ត្រូវតែកើតមានឡើងជាបន្តបន្ទាប់ជារៀងរហូត ដោយពុំមានឈប់ឈរ។ និរន្តរភាព គឺជាចំណុចស្នូលសម្រាប់ការប្រើប្រាស់ដីនៅគ្រប់តំបន់គោលដៅទាំងអស់តាមរយៈការកំណត់កត្តាចាំបាច់នានា សម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធភាព និងធានាឱ្យមាននិរន្តរភាព។

៣.៤.១.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍ សេដ្ឋកិច្ចសង្គម ព្រមទាំងថែរក្សាការពារបរិស្ថាន និងធនធានធម្មជាតិប្រកបដោយចីរភាព។ ដោយធានាបានការផ្គត់ផ្គង់សេចក្តីត្រូវការ និងការទទួលខុសត្រូវចំពោះផលប្រយោជន៍របស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ន និងបន្តទៅដល់កូនចៅ របស់ពួកគាត់ទៅជំនាន់ក្រោយទៀតបាននោះ ត្រូវតែយកចិត្តទុកដាក់ដល់ការគ្រប់គ្រងទៅលើការប្រើប្រាស់សេវាកម្ម និងលើវិស័យទាំងអស់នៅក្នុងឃុំដែលបានកំណត់រួចតាមរយៈការខិតខំប្រឹងប្រែងអនុវត្តឱ្យសម្រេចបានទៅលើកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

ក.ការគ្រប់គ្រងប្រព័ន្ធកសិកម្ម

បើពិនិត្យទៅលើលក្ខណៈភូមិសាស្ត្រ និងសក្តានុពលនៃធនធានដែលមាននៅក្នុងឃុំត្បែង ដែលក្រុមការងារ បានធ្វើការសិក្សាស្រាវជ្រាវរកឃើញនោះ ត្រូវបានកំណត់យ៉ាងច្បាស់ថា ឃុំមានគោលដៅអភិវឌ្ឍទៅថ្ងៃអនាគតពឹងផ្អែកទៅលើវិស័យកសិកម្មជាចម្បង ដែលនៅក្នុងនោះបានផ្តោតសំខាន់ទៅលើដំណាំស្រូវ និងចម្ការដំណាំឧស្សាហកម្ម។ ដូចនេះ ឃុំត្បែងនឹងមានតួនាទីសំខាន់មួយ ក្នុងការធ្វើឱ្យសម្រេចបាននូវគោលនយោបាយជំរុញផលិតកម្មស្រូវ និងនាំចេញអង្ករ ព្រមទាំងគោលនយោបាយ អភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ របស់រាជរដ្ឋាភិបាល ដែលត្រូវចាំបាច់ទាមទារឱ្យមានការគ្រប់គ្រងប្រព័ន្ធកសិកម្ម នៅក្នុងមូលដ្ឋានឱ្យបានរឹងមាំ និងមាននិរន្តរភាពទៅថ្ងៃអនាគត ដោយត្រូវយកចិត្តទុកដាក់ជំរុញផលិតកម្មស្រូវ និងដំណាំឧស្សាហកម្ម ដើម្បីបង្កើនទិន្នផលស្រូវ និងដំណាំឧស្សាហកម្មឱ្យបានខ្ពស់អស់ពីសក្តានុពល ដើម្បីមានលទ្ធភាពនាំស្រូវចេញបានច្រើនសល់ពីការហូបចុក ដើម្បីឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋ និងអាចមានលទ្ធភាពនាំផលិតផលដំណាំឧស្សាហកម្មចេញផងដែរ។

ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍឃុំត្បែងដូចខាងលើ ត្រូវមានការគ្រប់គ្រងដីស្រែ និងដីចម្ការក្នុងឃុំឱ្យបានច្បាស់លាស់ ដោយរាល់ការសម្រេចចិត្តប្តូរមុខងារប្រើប្រាស់ដី ពីកសិកម្មទៅបម្រើឱ្យការសាងសង់ និងបម្រើឱ្យការប្រើប្រាស់ផ្សេងទៀត ត្រូវតែមានការចូលរួមពីប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ប្រកបទៅដោយតម្លាភាព ដោយអនុលោមតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងត្រូវមានការផ្សព្វផ្សាយជាសាធារណៈ។ ទន្ទឹមនឹងការគ្រប់គ្រងដីស្រែត្រូវគិតគូរពីទឹកស្រោចស្រព ដោយធ្វើយ៉ាងណា អាចធ្វើស្រែបង្កើនរដូវ ឱ្យបានពីរដងនៅក្នុងមួយឆ្នាំ ដោយតាមរយៈការស្តារស្រះចំនួន ៨ កន្លែង ទំហំ ១៥,៣៤ហិកតា សម្រាប់ជាប្រភពទឹកស្រោចស្រព និងការស្តារប្រព័ន្ធប្រឡាយចាស់ និងថ្មីចំនួន១៩ខ្សែ ប្រវែង ៣ ៩០៩០ ម៉ែត្រ ដែលក្នុងនោះមានប្រឡាយមេ ២ខ្សែ ប្រវែង១៣ ៧៦៨ ម៉ែត្រ ប្រឡាយរង ២ខ្សែ ប្រវែង ១៧ ៨៣៨ ម៉ែត្រ និងប្រឡាយតូចៗចំនួន ១៥ ខ្សែ ប្រវែង១៧ ៤៨៤ ម៉ែត្រ សម្រាប់ជាមធ្យោបាយក្នុងការនាំទឹកទៅស្រោចស្រពដីស្រែទាំងអស់បានគ្រប់គ្រាន់។ បន្ទាប់ពីកត្តាដី និងទឹក នៅមានកត្តាបច្ចេកទេសក្នុងការដាំដុះបន្ថែមទៀត ដោយត្រូវគិតគូរជំរុញការធ្វើស្រែ តាមបែបប្រពលវប្បកម្មទំនើប ដូចដែលមានលើកឡើងតាមការវិភាគក្នុងជំពូកទី២ ត្រង់ចំណុចការផ្តល់ឱកាសដោយបច្ចេកវិទ្យាទំនើប ដែលកត្តានេះ នឹងលើកទឹកចិត្តឱ្យយុវជនចូលរួមក្នុងការងារកសិកម្មបានច្រើនផងដែរ ព្រោះយុវជនតែងតែគិតថាការធ្វើស្រែ នាំឱ្យមានការនឿយហត់ ប្រឡាក់ប្រឡូកដីភក់ មិនស្អាតបាត ដែលជាការយល់ខុស តាមពិតការធ្វើស្រែចម្ការតាមបច្ចេកទេសទំនើប កសិករក៏អាចស្លៀកពាក់ស្អាតបាត និងពាក់ក្រវ៉ាត់កប្រើប្រាស់កុំព្យូទ័រនៅក្នុងបន្ទប់ម៉ាស៊ីនត្រជាក់បានដូចគ្នា។ ការគ្រប់គ្រងប្រព័ន្ធកសិកម្មនៅឃុំត្បែង មិនមែនយកចិត្តទុកដាក់តែលើការជំរុញផលិតកម្មកសិកម្ម ដូចខាងលើប៉ុណ្ណោះទេ តែត្រូវខិតខំពង្រឹងការប្រមូលគ្នាចងក្រងជាសហគមន៍កសិករ ដើម្បីជ្រើសរើសតំណាងអាចទៅចូលរួមតស៊ូមតិក្នុងការចចាររកទីផ្សារ ក៏ដូចជាមួយឈ្មួញ ដោយធានាការធ្វើស្រែចម្ការបានទិន្នផលខ្ពស់ មានគុណភាពតាមស្តង់ដារ តម្រូវការទីផ្សារ និងធានាតម្លៃក្នុងទីផ្សារផងដែរ។

តាមការគណនា ដែលផ្អែកទៅលើការការគិតគូរនៅក្នុងជំពូក២ ត្រង់ចំណុច ១២.៣. អាចឱ្យយើងរំពឹងទុកអំពីបរិមាណផលស្រូវនាំចេញនាពេលអនាគតក្នុងអំឡុងពេល១៥ឆ្នាំខាងមុខដូចខាងក្រោមៈ

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ប្រជាពលរដ្ឋកើនឡើងដល់ ២ ១៨០៨ នាក់

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ដីស្រែវស្សាមាន ៨២៥៦,៥ ហិកតា

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ដីស្រែប្រាំង និងស្រែវស្សាមាន ២២៧៦,០៣ ហិកតា

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំណត់ទិន្នផលស្រូវវស្សាជាមធ្យមចំនួន ៤ តោន/ហ.ត ដីស្រែប្រាំង និងស្រែវស្សាមានចំនួន ៥ តោន/ហ.ត

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំណត់ធ្វើស្រែវស្សាបាន ១ដង/ឆ្នាំ ដីស្រែប្រាំង និងស្រែវស្សាបាន ២ដង/ឆ្នាំ

-ដូច្នេះក្នុងកំឡុងពេល១៥ឆ្នាំ(២០១៧-២០៣២)ផលិតផលស្រូវទទួលបានក្នុងមួយឆ្នាំជាមធ្យមៈ

-ស្រូវវស្សាស្មើនឹង ៨២៥៦,៥ ហិកតា x ៤តោន/ហិកតា x ១ដង = ៣៣០២៦តោន/ឆ្នាំ

-ដីស្រូវប្រាំងនិងស្រែវស្សាស្មើនឹង ២២៧៦,០៣ហិកតា x ៥ តោន/ហិកតា x ២ដង

=២២៧៦០,៣០តោន/ឆ្នាំ

-ទិន្នផលស្រូវសរុបស្មើរនឹង ៣៣០២៦តោន + ២២៧៦០,៣០តោន = ៥៥៧៨៦,៣០ តោន/ឆ្នាំ

-ប្រជាពលរដ្ឋ១នាក់ ត្រូវការអង្ករសម្រាប់ហូបក្នុងមួយឆ្នាំមានចំនួន ១៤៣ គីឡូក្រាម ដែលបើគិតជាស្រូវត្រូវការចំនួន ២២៤ គីឡូក្រាម (ផ្អែកតាមរបាយការណ៍ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ)

-ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខត្រូវការបរិមាណស្រូវសម្រាប់ផ្គត់ផ្គង់ការហូបចុកក្នុងមួយឆ្នាំជាមធ្យម

២ ១៨០៨ នាក់ x ២២៤ គីឡូក្រាម = ៤ ៨៨៤ ៩៩២ គីឡូក្រាម/ឆ្នាំ ស្មើនឹង ៤ ៨៨៤,៩៩ តោន/ឆ្នាំ

-ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខត្រូវការបរិមាណពូជស្រូវក្នុងមួយឆ្នាំជាមធ្យម ៖

-ស្រូវវស្សាស្មើនឹង ៨២៥៦,៥ ហិកតា x ៣០០ គីឡូក្រាម = ២៤៧៦,៩៥ តោន/ឆ្នាំ

-ដីស្រែប្រាំង និងស្រែវស្សាស្មើនឹង ២២៧៦,០៣ ហិកតា x ៣០០ គីឡូក្រាម

= ៦៨២,៨១ តោន/ឆ្នាំ

-ពូជស្រូវសរុបស្មើរនឹង ២៤៧៦,៩៥ តោន + ៦៨២,៨១ តោន = ៣១៥៩,៧៦ តោន/ឆ្នាំ

-ដូច្នេះក្នុងអំឡុងពេល១៥ឆ្នាំខាងមុខ ផលិតផលស្រូវទទួលបានសម្រាប់ការនាំចេញក្នុងមួយឆ្នាំជាមធ្យម

៥៥៧៨៦,៣០ តោន/ឆ្នាំ - ៤ ៨៨៤,៩៩ តោន/ឆ្នាំ - ៣១៥៩,៧៦ តោន/ឆ្នាំ = ៤៧៧៤១,៥៥ តោន/ឆ្នាំ

-តែបើគិតជាអង្ករវិញអាចនាំចេញបានក្នុងមួយឆ្នាំជាមធ្យមៈ

៤៧៧៤១,៥៥ តោន/ឆ្នាំ x ៦០ % = ២៨៦៤៤,៩៣ តោន/ឆ្នាំ

ខ.ការគ្រប់គ្រងព្រៃឈើ ជលផល និង ធនធានសំខាន់ៗផ្សេងៗទៀត

នៅពេលអនាគត ទោះបីនៅក្នុងឃុំត្បែង បានកំណត់រក្សាទុកតំបន់ប្រើប្រាស់ដី សម្រាប់ព្រៃល្បោះនិងព្រៃដាំឡើងវិញហើយក៏ដោយ ក៏ឃុំនៅមានដីតាមដងផ្លូវ ដងស្ទឹង បឹង ប្រឡាយទឹក ទីធ្លាសាលាឃុំ សាលារៀន មណ្ឌលសុខភាព វត្តអារាម និងតាមលំនៅឋានជាដើម ដែលត្រូវធ្វើការជំរុញការដាំដើមឈើថែមទៀតដែរ ដើម្បីឱ្យមានដើមឈើពណ៌បៃតងនៅពាសពេញទូទាំងឃុំ បម្រើផលប្រយោជន៍ដូចអ្វី ដែលបានលើកឡើងក្នុងជំពូក២ នៃរបាយការណ៍នេះ ហើយត្រូវបន្តថែទាំដើមឈើទាំងនោះឱ្យបានគង់វង្ស និងលូតលាស់បានល្អ។ ដូច្នេះ ដើម្បីគ្រប់គ្រងធានានិរន្តរភាពព្រៃឈើទាំងនេះ អាជ្ញាធរមានសមត្ថកិច្ចទាំងអស់ ជាពិសេសនោះក្រុមប្រឹក្សាឃុំត្បែង ត្រូវមានវិធានការទប់ស្កាត់ការបាត់បង់ព្រៃឈើដូចមានរៀបរាប់ខាងក្រោមៈ

- ជំរុញការចុះបញ្ជីដីរដ្ឋ
- ត្រូវបង្កើនការគោរពច្បាប់ដើម្បីការពារព្រៃឈើ
- ត្រូវដាក់ទោសចំពោះជនប្រព្រឹត្តបទល្មើសកាប់បំផ្លាញព្រៃឈើ
- ផ្សព្វផ្សាយពីផលប្រយោជន៍នៃព្រៃឈើ
- បណ្តុះបណ្តាលឱ្យប្រជាពលរដ្ឋមានស្មាតីម្ចាស់ការដាំដើមឈើ និងថែរក្សាព្រៃឈើ។

ដោយឡែកមច្ឆាជាតិ ដែលជាធនធានជលផលនៅក្នុងឃុំត្បែង បានកំណត់ ស្ទឹងព្រៃប្រស់ បឹង និងស្រះជាប្រភពធនធានទាំងនេះ តែទៅថ្ងៃអនាគតខាងមុខក៏ត្រូវខិតខំយកចិត្តទុកដាក់ នៅក្នុងការចិញ្ចឹមត្រីថែមទៀតដើម្បីបានផលគ្រប់គ្រាន់អាចផ្តល់ជាប្រភពប្រូតេអ៊ីនសាច់ដ៏សំខាន់ សម្រាប់ប្រជាពលរដ្ឋនៅក្នុងឃុំនេះ។ ចំពោះស្ថានភាពសមស្របក្នុងឃុំគួរចិញ្ចឹមត្រីតាមបែបចិញ្ចឹមក្នុងស្រះខ្នាតតូច ស្រះចិញ្ចឹមត្រីតាមគ្រួសារ និងកសិដ្ឋានចិញ្ចឹមត្រីក្នុងស្រែ ដែលជាទម្រង់មួយនៃការបង្កើនបរិមាណត្រី ដោយអាចបង្កើនផលិតភាពជលផលតាមប្រពលវប្បកម្ម(តាមវាលស្រែ) ហើយមានប្រយោជន៍ក្នុងការប្រើត្រី សម្រាប់ទប់ទល់ទៅសត្វល្អិត និងដង្កូវហ្វូងក្នុងស្រែដែលបំផ្លាញផលដំណាំផងដែរ។ ដូច្នេះ ដើម្បីធានាឱ្យមានការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាពតទៅអនាគត អាជ្ញាធរមានសមត្ថកិច្ចជាពិសេសក្រុមប្រឹក្សាឃុំត្រូវមានវិធានទប់ស្កាត់ការបំផ្លាញធនធានជលផលនេះដូចខាងក្រោម៖

- ត្រូវគ្រប់គ្រង និងអភិរក្សធនធានជលផលឱ្យបានល្អ
- លុបបំបាត់ការធ្វើនេសាទលើសកម្រិត
- ថែរក្សា ការពារព្រៃលិចទឹកជាជម្រកត្រីពង
- ជំរុញការធ្វើវារីវប្បកម្មតាមគ្រប់រូបភាព
- ទប់ស្កាត់ការប្រើឧបករណ៍ឆក់ និងសារជាតុពុលគ្រប់ប្រភេទទៅលើធនធានជលផលគ្រប់ប្រភេទ

ចំណែកធនធានសំខាន់ៗក្រៅពីការរៀបរាប់ខាងលើនេះ នៅក្នុងឃុំពុំមានឃើញធនធានអ្វីផ្សេង ដែលគួរឱ្យកត់សម្គាល់ឡើយ។

៣.៤.២.គម្រោងគាំទ្រចាំបាច់ សម្រាប់គាំទ្រនិរន្តរភាព

ដើម្បីមានមធ្យោបាយគ្រប់គ្រាន់ ធ្វើឱ្យសម្រេចបាននូវការគ្រប់គ្រងប្រព័ន្ធកសិកម្ម និងធនធានសំខាន់ៗសម្រាប់ការគាំទ្រដល់និរន្តរភាពនៃការអភិវឌ្ឍ និងអភិរក្សដីធ្លីនិងធនធានធម្មជាតិក្នុងឃុំត្បែងចាំបាច់ត្រូវបង្កើតឱ្យមានគម្រោងគាំទ្រជាអាទិភាពមួយចំនួនដូចខាងក្រោម៖

- សាងសង់ផ្លូវថ្មីនិងកែលម្អផ្លូវដែលមានស្រាប់
- ជម្រុញការថែទាំជាប្រចាំ
- ពង្រឹងការគ្រប់គ្រងដីចំណីផ្លូវ
- សាងសង់ និងកែលម្អប្រព័ន្ធលូឱ្យបានត្រឹមត្រូវតាមបច្ចេកទេស
- អប់រំណែនាំអ្នកប្រើប្រាស់ពីមូលហេតុដែលបង្កឱ្យខូចថ្នល់
- ដាក់បង្គោលនិងស្លាកសញ្ញាចរាចរណ៍
- សាងសង់សំណង់ធារាសាស្ត្រ
- ស្តារឡើងវិញប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់
- រៀបចំនិងពង្រឹងសហគមន៍ប្រើប្រាស់ទឹក
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម
- បណ្តុះបណ្តាលផលិតជីកំប៉ុស្ត
- បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី
- បណ្តុះបណ្តាលពីការដាំដំណាំស្រូវ
- តបណ្តាញទឹកស្អាតឱ្យដល់គ្រប់ភូមិ

- តបណ្តាញអគ្គិសនីឱ្យដល់គ្រប់ភូមិ
- បង្កើតសហគមន៍កសិករ ដើម្បីជំរុញការអនុវត្តន៍ភូមិ១ ផលិតផល១
- ដោះស្រាយដីសម្បទានសង្គមកិច្ច
- ជំរុញធ្វើប័ណ្ណក្រីក្រឱ្យដល់ស្ត្រីគ្រប់រូប
- ផ្តល់អាហាររូបត្ថម្ភដល់ស្ត្រី និងកុមារ
- ផ្សព្វផ្សាយពីការចាក់វ៉ាក់សាំងការពារជម្ងឺដល់ស្ត្រីមានផ្ទៃពោះ និងកុមារ
- ពង្រឹងសេវាថែទាំសុខភាព និងព្យាបាលជម្ងឺជូនដល់ប្រជាពលរដ្ឋឱ្យបានល្អប្រសើរឡើង
- ផ្សព្វផ្សាយពីច្បាប់ភូមិបាល ច្បាប់ផលផលជូនដល់ប្រជាពលរដ្ឋ

៣.៥.សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់២០៣២)

ផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំត្បែង នៅក្នុងឆ្នាំ២០១៧នេះ បានឱ្យដឹងថា ឃុំត្បែង ជាឃុំមួយក្នុងចំណោមឃុំ ១១ របស់ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ មានភូមិចំនួន១៥ ដែលមានទំហំផ្ទៃដីសរុបចំនួន ១៤ ១៣៩,៣៧ ហិកតា។ នៅក្នុងឆ្នាំ២០១៧ ឃុំត្បែងមានប្រជាជនចំនួន២៨៧០គ្រួសារ និងមានប្រជាជនសរុបចំនួន ១៥៦៤០នាក់ ក្នុងនោះស្ត្រី ៨៧១០នាក់ ហើយមានដង់ស៊ីតេប្រជាជនជាមធ្យម ១០៧,៨នាក់/គ.ម២។ ឃុំត្បែង មានសណ្ឋានភាពដី ជាវាលទំនាបលិចទឹកនៅរដូវវស្សា ហើយជាប្រភេទខ្សាច់សុទ្ធពណ៌ស ដីខ្សាច់លាយពណ៌ប្រផេះ ដីខ្សាច់លាយតដ្ឋពណ៌ប្រផេះ ដីកណ្តោង ដីពពាយកណ្ដុរ តដ្ឋពណ៌ប្រផេះខ្លាញ់ក្តាម ត្រូវបានប្រើប្រាស់ជាដីស្រែប្រាំង និងស្រែវស្សា ដែលបានផ្តល់នូវមុខរបរយ៉ាងសំខាន់ដល់ប្រជាពលរដ្ឋភាគច្រើនរហូតដល់ប្រមាណ ៨៥,៤ភាគរយ។ ទន្ទឹមនេះឃុំត្បែង មានប្រឡាយមេ ២ខ្សែ ប្រឡាយរង ៣ខ្សែនិងប្រឡាយតូច ១៩ខ្សែ។ បន្ថែមលើនេះក្នុងឃុំមានផ្លូវជាតិលេខ៦ ឆ្លងកាត់ ជាការផ្តល់ឱកាសឱ្យឃុំត្បែងអាចទាញយកប្រយោជន៍ពីការអភិវឌ្ឍនៅតាមផ្លូវនេះបាន ហើយឃុំក៏នៅមានផ្លូវផ្សេងៗទៀតគ្រប់គ្រាន់អាចភ្ជាប់ទំនាក់ទំនងពីភូមិមួយទៅភូមិមួយក្នុងឃុំ និងអាចភ្ជាប់ទំនាក់ទំនងទៅឃុំ និងស្រុកផ្សេង រួមទាំងទីរួមខេត្តកំពង់ធំបានដោយងាយស្រួល។ ចំពោះកំណើនប្រជាជនវិញបានរកឃើញថា នៅក្នុងរយៈពេល១៥ឆ្នាំទៅមុខរហូតដល់ឆ្នាំ២០៣២ នឹងមានចំនួនប្រជាជនកើនឡើងរហូតទៅដល់ ២១ ៨០៨នាក់ ដែលនឹងត្រូវយកចិត្តទុកដាក់គិតគូររកដំណោះស្រាយអំពីការប្រើប្រាស់ដី ដើម្បីឆ្លើយតបបានទៅនឹងតម្រូវការរបស់ប្រជាជន។ ទន្ទឹមនឹងនេះ ក៏បានរកឃើញអំពីបញ្ហាប្រឈមមួយចំនួនលើសកម្មភាពនៃការអភិវឌ្ឍឃុំត្បែងបច្ចុប្បន្នផងដែរ ដូចជា ការធ្វើស្រែ ដែលមានសក្តានុពលក្នុងការអភិវឌ្ឍឃុំ មិនទាន់ទទួលបានផលស្រូវសមស្របអស់លទ្ធភាពនៅឡើយ ដោយសារដីស្រែទាំងនេះកាន់តែខ្សត់ជីជាតិ ខ្វះខាតទឹកស្រោចស្រពសម្រាប់ផ្គត់ផ្គង់ទៅដល់ការធ្វើស្រែបង្កើនរដូវ ខ្វះចំណេះដឹងពីបច្ចេកទេសនៃការដាំដុះ ខ្វះចំណេះដឹងពីបច្ចេកទេសការប្រើប្រាស់ជីគីមី និងថ្នាំពុលកសិកម្ម ប្រព័ន្ធប្រឡាយដែលមានស្រាប់បានរាក់ ខ្វះកម្លាំងពលកម្មដោយសារការចំណាកស្រុកច្រើន គឺបាត់កម្លាំងពលកម្មជិតពាក់កណ្តាលនៃកម្លាំងពលកម្មដែលមាន និងតម្លៃកសិផលមិនមានស្ថេរភាពដោយសារឈ្មួញជាអ្នកកំណត់តម្លៃ។ល។ ទន្ទឹមនឹងការរកឃើញបញ្ហាមួយចំនួនលើសកម្មភាពអភិវឌ្ឍឃុំ ក៏បានរកឃើញថា ជាទូទៅការប្រើប្រាស់ដីនៅក្នុងឃុំត្បែងបច្ចុប្បន្នបានចំទិសដៅ និងមានភាពសមស្រប ដូចជា ការប្រើប្រាស់ដីសម្រាប់ដីលំនៅឋាន ដីកសិកម្ម ប្រព័ន្ធផ្លូវគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រជាដើម ដែលទៅថ្ងៃអនាគត ក៏នៅតែរក្សាមុខងារប្រើប្រាស់ដីទាំងនោះឱ្យនៅដដែល។ បន្ថែមពីលើនេះ ក៏បានរកឃើញវិធីដោះស្រាយបញ្ហាផ្សេងៗទៀតផងដែរសម្រាប់អនាគត ដូចជា ត្រូវសាងសង់បន្ទប់រៀនបន្ថែម ពង្រឹងការផ្តល់សេវាសុខាភិបាលឱ្យបានល្អប្រសើរ ជំរុញឱ្យប្រជាពលរដ្ឋហូបទឹកស្អាត និងប្រើប្រាស់បង្គន់អនាម័យ ជួសជុលផ្លូវ ស្ពានប្រឡាយទឹក ដាំដើមឈើនៅតាមទីសាធារណៈ ជំរុញការចិញ្ចឹមត្រីនៅតាមស្រែ

ជាពិសេស ការដោះស្រាយដីសម្រាប់លំនៅឋានក្នុងភូមិ ដែលមានស្រាប់ដែលបច្ចុប្បន្ននៅទូលាយអាចផ្គត់ផ្គង់ការសាងសង់លំនៅឋានបាន។ ដើម្បីដោះស្រាយនឹងកំណើនប្រជាជន ត្រូវពង្រឹងការធ្វើស្រែឱ្យបាន ២ ដងក្នុងមួយឆ្នាំនិងធ្វើស្រែតាមបែបប្រពលវប្បកម្ម ដើម្បីបង្កើនទិន្នផលស្រូវឱ្យបានខ្ពស់អស់សក្តានុពល សម្រាប់ផ្គត់ផ្គង់ការហូបចុក និងអាចមានលទ្ធភាពនាំស្រូវចេញបានចំនួន ៤៧ ៧៤១,៥៥ តោន/ឆ្នាំ ដើម្បីជួយផ្គត់ផ្គង់ដល់ជីវភាពរបស់ប្រជាពលរដ្ឋក្នុងឃុំឱ្យបានកាន់តែប្រសើរឡើង ស្របទៅនឹងកំណើនប្រជាពលរដ្ឋ ព្រមទាំងជួយជំរុញកំណើនសេដ្ឋកិច្ចនៅក្នុងឃុំ។ ការរកឃើញភាពសមស្រប និងជម្រើសនៃការប្រើប្រាស់ដីនៅក្នុងឃុំត្បែងនាពេលអនាគត បានមកពីការវាយតម្លៃដ៏ត្រឹមត្រូវដោយផ្អែកលើធនធានដី រយៈកម្ពស់ដី ទីជម្រាល ធនធានទឹក ការកាន់កាប់ដី និងសក្តានុពលនៃការប្រើប្រាស់ដីនៅក្នុងឃុំនេះ ដើមដើម្បីធានាថាការប្រើប្រាស់ដីនៅក្នុងឃុំត្បែងទៅអនាគតប្រកបដោយចីរភាព និងសមធម៌។

ដូច្នេះ ដើម្បីសម្រេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីនៅក្នុងឃុំត្បែង ស្របទៅតាមស្ថានភាពដីជាក់ស្តែង និងសក្តានុពលធម្មជាតិ សម្រាប់ការគាំទ្រកិច្ចអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព និងសមធម៌ រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដើម្បីអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការ របស់ប្រជាពលរដ្ឋនាពេលអនាគត ដូចបានរកឃើញមានចែងលម្អិតនៅក្នុងរបាយការណ៍បច្ចេកទេសនេះ រដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ជាពិសេសក្រុមប្រឹក្សាឃុំ ដែលជាតំណាងប្រជាពលរដ្ឋនៅក្នុងឃុំត្បែង ហើយមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅនៅក្នុងឃុំ ត្រូវខិតខំអនុវត្តតាមផែនការប្រើប្រាស់ដីនៅក្នុងឃុំត្បែង ដែលបានអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការរួច ដោយបញ្ជៀបទៅនិងផែនការអភិវឌ្ឍឃុំឱ្យបាន ប្រកបដោយប្រសិទ្ធិភាពខ្ពស់បំផុត ដើម្បីធានាភាពជោគជ័យនៃផែនការនេះ។

លេខៈ......៣០១/១៣......

បានពិនិត្យ និង សូមគោរពជូន

លោកអភិបាលនៃគណៈអភិបាលស្រុក និង ជាប្រធានគណៈកម្មាធិការ

រៀបចំដែនដី និងនគរូបនីយកម្មស្រុកកំពង់ស្វាយ មេត្តាពិនិត្យ និង សម្រេច។

ថ្ងៃ......ខែ......ឆ្នាំ......ព.ស ២៥៦៤

ត្បែង ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០២០

មេឃុំត្បែង

ទឹម ថៃ

លេខ៖ ១៣៧៦ /២០២០

បានពិនិត្យ និង សូមគោរពជូន

ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និង ជាប្រធានគណៈកម្មាធិការ

រៀបចំដែនដី និង នគរូបនីយកម្មខេត្តកំពង់ធំ មេត្តាពិនិត្យ និង សម្រេចដ៏ខ្ពង់ខ្ពស់ ។

ថ្ងៃ សុក្រ ១១រោច ខែ កត្តិក ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

កំពង់ស្វាយ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០២០

អភិបាលនៃគណៈអភិបាលស្រុក និង ជាប្រធាន

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកកំពង់ស្វាយ

អ៊ុន បុត្ត

លេខ៖ ៥៤៥៥ /២០២១

បានឃើញ និងឯកភាពសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ

ថ្ងៃ ព្រហស្បតិ៍ ... ខែ ភទ្របទ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

កំពង់ធំ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០២១

អភិបាលនៃគណៈអភិបាលខេត្ត និងជា

ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ

សុខ លូ

ឯកសារឧបសម្ព័ន្ធ

ផែនទីហេដ្ឋារចនាសម្ព័ន្ធ ឃុំត្បែង



ផែនទីប្រព័ន្ធធារាសាស្ត្រ ឃុំត្បែង



ផែនទីប្រើប្រាស់ដីសាមញ្ញ ឃុំត្បែង




ផែនទីគម្រោងវិនិយោគ ឃុំត្បែង
សញ្ញាសម្គាល់
ព្រំប្រទល់ និងទីតាំងរដ្ឋបាល
សាលាឃុំ
ភូមិ
ព្រំប្រទល់រដ្ឋបាលឃុំ
ហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន
វត្ត
សាលារៀន
ស្ពាន
ទ្វារទឹក
ផ្លូវចាក់កៅស៊ូ
ផ្លូវចាក់បេតុង
ផ្លូវគ្រួសក្រហម ឬក្រាលថ្ម
ផ្លូវដីស ឬផ្លូវរទេះ
ប្រឡាយមេ
ប្រឡាយរង
ប្រឡាយតូច
ប្រភេទប្រើប្រាស់ដីបច្ចុប្បន្ន
ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ
ដីកសិកម្ម
ដីព្រៃ/គម្របព្រៃ
ផ្ទៃទឹក និងខ្សែទឹក
គម្រោងវិនិយោគ
ជួសជុលផ្លូវចាក់បេតុង
ជួសជុលផ្លូវគ្រួសក្រហម
ជួសជុលផ្លូវដីស
សាងសង់ផ្លូវដីស
ស្តារប្រឡាយមេ
ជីកប្រឡាយរង
ស្តារប្រឡាយតូច
ជីកប្រឡាយតូច
ប្រព័ន្ធភូគោល
ចំណោលផែនទី : UTM
តំបន់ទី : 48N
ទិន្នន័យយោង : WGS 1984
អេលីបសូអ៊ីត : WGS 1984
ប្រភពទិន្នន័យ
-ទីតាំងវិនិយោគ ប្រភពពីផែនការអភិវឌ្ឍឃុំរយៈពេល៥ឆ្នាំនិងអាជ្ញាធរមូលដ្ឋាន
-ទិន្នន័យទីតាំង និងព្រំប្រទល់រដ្ឋបាលប្រភពពីនាយកដ្ឋានភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (២០១៥)
-ទិន្នន័យសំខាន់ៗផ្សេងទៀត ប្រភពពីមន្ទីរ/ស្ថាប័នពាក់ព័ន្ធជុំវិញខេត្ត
បញ្ជាក់
-ព័ត៌មានដែលបង្ហាញនៅលើផែនទីនេះ គឺផ្អែកលើទិន្នន័យដែលបានបង្កើតឡើងដោយថ្នាក់ជាតិនិងត្រូវបានកែសម្រួលដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន
-ព្រំប្រទល់រដ្ឋបាលទាំងនោះ មិនអាចចាត់ទុកជាផ្លូវការ និងខ្សែបន្ទាត់ព្រំដែននៃផែនទីនេះ ពុំមានតម្លៃជាផ្លូវការអន្តរជាតិឡើយ
-ផែនទីនេះត្រូវបានបោះពុម្ពនៅ ខែ.................................. ឆ្នាំ២០.......
មាត្រដ្ឋាន ១: ៧០ ០០០
០ ២ ៤
គីឡូម៉ែត្រ
គាំទ្រដោយ
ADB
GAFSP
អនុវត្តដោយ
470000 mE
472000
474000
476000
478000
480000
482000
484000
486000
488000 mE
1424000 mN
1422000
1420000
1418000
1416000
1414000
1412000
1410000
1408000 mN

ឯកសារឧបសម្ព័ន្ធ



សកម្មភាពក្រុមការងារចូលរួមប្រជុំទទួលការណែនាំពីនីតិវិធីរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ពីប្រធានគ្រប់គ្រងគម្រោងរបស់ក្រុមហ៊ុន



សកម្មភាពប្រមូលទិន្នន័យនៅតាមមន្ទីរជុំវិញខេត្តរបស់ក្រុមការងារក្រុមហ៊ុន SBK

កិច្ចប្រជុំពិភាក្សាអំពីផែនទីប្រើប្រាស់ដីបច្ចុប្បន្នឃុំត្បែង

សកម្មភាពក្រុមការងារចុះទីវាលស្រង់ទិន្នន័យបំពេញបន្ថែមលើ
ផែនទីប្រើប្រាស់ដីបច្ចុប្បន្នដែលមានស្រាប់ឃុំត្បែង

សកម្មភាពចូលរួមត្រួតពិនិត្យ ណែនាំការអនុវត្តគម្រោងរបស់អង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ(NIO)

កិច្ចប្រជុំក្រុមប្រឹក្សាឃុំ ដើម្បីពិនិត្យ និងឯកភាពទៅលើ សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំត្បែង

កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកកំពង់ស្វាយ ដើម្បីពិនិត្យ និងឯកភាពទៅលើសេចក្ដីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំត្បែង





ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



សកម្មភាពផ្សព្វផ្សាយជាសាធារណៈសេចក្ដីព្រាងផែនការប្រើប្រាស់ដីនៅឃុំត្បែង

កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ
ដើម្បីពិនិត្យ និងឯកភាពទៅលើ សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំត្បែង

ឯកសារយោង

ឯកសារយោង

១.ឯកសារព័ត៌មានស្ថានភាពឃុំត្បែងស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៣ របស់មន្ទីរផែនការខេត្ត
២.ឯកសារព័ត៌មានស្ថានភាពឃុំត្បែងស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៤ របស់មន្ទីរផែនការខេត្ត
៣.ឯកសារព័ត៌មានស្ថានភាពឃុំត្បែងស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៥ របស់មន្ទីរផែនការខេត្ត
៤.ឯកសារព័ត៌មានស្ថានភាពឃុំត្បែងស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៦របស់មន្ទីរផែនការខេត្ត
៥.ឯកសារព័ត៌មានស្ថានភាពឃុំត្បែងស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៧ របស់មន្ទីរផែនការខេត្ត
៦.ផែនការអភិវឌ្ឍឃុំរយៈពេលប្រាំឆ្នាំ(២០១៨-២០២២)របស់ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ
៧.កម្មវិធីវិនិយោគឃុំត្បែង ឆ្នាំ២០១៧ របស់ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ
៨.របាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ_បរិស្ថាន ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ឆ្នាំ២០១៧